ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- គេហទំព័រ ជាមួយនឹងការអប់រំយុវជនពីប្រវត្តិសាស្ត្រ
- អតីតពេទ្យទាហានផ្តល់សក្ខីកម្មអំពីការវាយប្រហារទាហានខ្មែរក្រហម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២០៥ ខែមករា ឆ្នាំ២០១៧

ស្វែងរកការពិត

លេខ២០៥ ខែមករា ឆ្នាំ២០១៧

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ គេហទំព័រ ជាមួយនឹងការអប់រំយុវជនពីប្រវត្តិសាស្ត្រ ........................ ១

**ផ្នែកឯកសារ**

◆ កំណត់ហេតុរបស់ យ៉ាម ប៉ាំឡាត់ អតីតទាហាន ............................ ២

◆ បំផុសចលនារៀនសូត្រលក្ខន្តិកៈបក្សឲ្យជាប់ដើម្បី ............................ ៦

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ភាពយន្តឯកសារ "កុំស្មានបងភ្លេច" នឹងបញ្ចាំង ............................ ១៩

◆ ខ្ញុំមិនមានការភ័យខ្លាចទេ ទោះបីជារស់នៅអតីតតំបន់ ............................ ២៥

◆ សុខចិត្តរៀបការដើម្បីរក្សាជីវិតកូន ............................ ២៦

◆ អ្វីដែលខ្ញុំប្រាថ្នាចង់បាន គឺ សន្តិភាព ............................ ២៧

◆ ដំណើរជីវិតឆ្លងកាត់របបខ្មែរក្រហម ............................ ២៩

◆ ការបាត់បង់ព្រៃឈើនៅតែជាការបារម្ភ ............................ ៣៣

◆ សួស វណ្ណា ហៅ យឿន អតីតកងទ័ពជើងទឹក ............................ ៣៥

◆ បាត់ដំណឹងឪពុកម្ដាយ និងប្អូនៗ សូន្យឈឹង ............................ ៣៨

◆ ក្លាយជាអ្នកទោសដោយសារតែការសង្ស័យ ............................ ៤២

**ផ្នែកច្បាប់**

◆ អតីតពេទ្យទាហានផ្ដល់សក្ខីកម្មអំពីការវាយប្រហារ ............................ ៤៦

**វេទិកាពិភាក្សាសាធារណៈ**

◆ ថ្ងៃដែលចងចាំ ............................ ៥៤

**ទំព័រស្រាវជ្រាវរកក្រួសារ**

◆ គេរងរំណែលដេះដងសល់ពីរបបខ្មែរក្រហម ............................ ៥៥

◆ "សល់មួយគ្រាប់" ............................ ៥៩



ប្រជាជនចូលរួមស្ដាប់ការប្រកាសសាលដីកាស្ថាពររបស់អង្គជំនុំជម្រះតុលាការកំពូលទាក់ទងសំណុំរឿង០០២វគ្គ១ ដែលមានជនជាប់ចោទ នួន ជា និង ខៀវ សំផន ដោយមានការរៀបចំផ្សាយបន្ដផ្ទាល់ដោយក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅវត្តថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង កន្លងទៅ។

## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ** ៖ ទូន សិរីរតនា, ខាន់ ម៉ារី, ព្រឿន បញ្ញារី, មាស សុខជា, ផល សំណាង, គិត ស្រីពៅ, លីអូនី គីដេស្តី, សៀវ សុផុន, ហែម សុវណ្ណារិទ្ធិ **អ្នកនិពន្ធនិងស្រាវជ្រាវ** ៖ ទាវ សារៈមុន្នី **អ្នកបកប្រែ** ៖ ឯម សីលា និង ឈឹម អមរ័ត្ន **និពន្ធនាយកទូទៅ** ៖ ឆាំង យុ **ជំនួយការនិពន្ធនាយក** ៖ សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ** ៖ សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ** ៖ ផេង ពង្ស និង សន ល័ក្ខ **Email: dccam@online.com.kh,**

**Homepage: www.d.dccam.org, www.cambodiatribunal.org, www.cambodiasri.org, www.truthcambodia.com**

# គេហទំព័រ ជាមួយនឹងការអប់រំយុវ័យពីប្រវត្តិសាស្ត្រ កម្ពុជាប្រជាធិបតេយ្យ

*ថ្ងៃទី៧ ខែមករា ឆ្នាំ២០១៧នេះ ជាខួបលើកទី៣៨ នៃថ្ងៃជ័យជម្នះលើរបបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) មជ្ឈមណ្ឌលឯកសារកម្ពុជានឹងដាក់ឲ្យដំណើរការគេហទំព័រថ្មីរបស់ខ្លួនដែលមានអាសយដ្ឋាន www.khmerrougehistory.org ឲ្យ*



*សាធារណជនប្រើប្រាស់ និងស្វែងរកព័ត៌មាននានាដែលទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។*

*ការដាក់ឲ្យដំណើរការគេហទំព័រថ្មីចំថ្ងៃ៧ ខែមករា នេះ ដើម្បីជាការបង្ហាញអំពីការមិនចុះចាញ់ ឬមិនចុះញ៉មដាច់ខាត ចំពោះមុខរបបវាលពិឃាត ។ ជាមួយគ្នានេះ ការបង្កើតគេហទំព័រ www.khmerrougehistory.org ដើម្បីជាប្រភពឯកសារសម្រាប់សាធារណជនជាតិ និងអន្តរជាតិអាចធ្វើការសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដោយយើងបានដាក់ឯកសារទាំងអស់នៅលើគេហទំព័រនេះដែលមានលក្ខណៈងាយស្រួលក្នុងការស្វែងរក និងងាយយល់សម្រាប់សាធារណជនក្នុងការអាន ជាពិសេសសម្រាប់សិស្ស និស្សិតខ្មែរប្រមាណ៧០ភាគរយ ដែលកើតក្រោយរបបខ្មែរក្រហម ។ សាធារណជននឹងប្រើប្រាស់គេហទំព័រនេះតាមរយៈទូរសព្ទដៃ (smartphone) ដោយមានភ្ជាប់ជាមួយនឹងកម្មវិធី Application តាមទូរសព្ទទៀតផង ។*

*គេហទំព័រ www.khmerrougehistory.org ធ្វើឡើងជាពីរភាសា គឺ ខ្មែរ និងអង់គ្លេស ហើយចែកចេញជាបីផ្នែកសំខាន់៖*

- *ផ្នែកទី១ ៖ ការសង្ខេបព្រឹត្តិការណ៍សំខាន់ៗចាប់តាំងពីថ្ងៃកកើតដំបូងនៃរបបខ្មែរក្រហមរហូតដល់ដំណើរការនៃតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម*
- *ផ្នែកទី២ ៖ ពន្យល់ពាក្យដែលមានប្រើប្រាស់ក្នុងរបបខ្មែរក្រហម និង*
- *ផ្នែកទី៣ ៖ រៀបរាប់អំពីជីវប្រវត្តិរបស់កម្មាភិបាលខ្មែរក្រហម ព្រមទាំងអ្នករស់រាន និងបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម ។*

*គេហទំព័រថ្មីនេះ បានប្រមូលផ្តុំនូវឯកសារគ្រប់ប្រភេទ មានបទសម្ភាសន៍ជាសំឡេង វីឌីអូ រូបភាពដ៏កម្រ ខ្សែភាពយន្តប្រវត្តិសាស្ត្រ សៀវភៅ និងសំណៅឯកសារផ្សេងៗ សរុបជាង១លានឯកសារ នឹងដាក់ឲ្យសាធារណជនសិក្សាស្វែងយល់ ។*



*គេហទំព័រ www.khmerrougehistory.org ត្រូវបានចំណាយពេលរៀបចំអស់រយៈពេលជិត៣ឆ្នាំ ដោយគម្រោងស្តីអំពីការសិក្សាអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្រោមជំនួយឧបត្ថម្ភពីទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិរបស់អាមេរិក (USAID) និងអង្គការអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយអាល្លឺម៉ង់ DW Akademie ។*

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# កំណត់ហេតុរបស់ឈ្មោះ យ៉ាម ប៉ាឡាត់ អតីតទាហានរបស់ស័ក្តិ៥

*ដកស្រង់ចេញពីឯកសារលេខ D៤១២៧៤*

យ៉ាម ប៉ាឡាត់ គឺជាឈ្មោះអ្នកទោសរបស់អង្គការម្នាក់ មានអាយុ២៦ឆ្នាំ ជនជាតិព្នង មានស្រុកកំណើតនៅភូមិរំបាង ឃុំណាំប៉ាក់ ស្រុកអណ្តូងពេជ ខេត្តរតនគិរី ។ ឪពុកម្តាយរបស់ ប៉ាឡាត់ ត្រូវបានអង្គការចាប់ខ្លួននៅឆ្នាំ១៩៧០ និងបានបាត់ខ្លួនរហូតតាំងពីពេលចាប់ខ្លួនមក ។ ចំណែក ប៉ាឡាត់ ផ្ទាល់វិញ ក៏ត្រូវអង្គការចាប់ខ្លួននៅចុងឆ្នាំ១៩៧៧ដែរ ដោយចោទប្រកាន់ថាបានធ្វើសកម្មភាពប្រឆាំងនឹងអង្គការបដិវត្តន៍ ។ នៅពេលចាប់ខ្លួន ប៉ាឡាត់ បានហើយ ដំបូងយកទៅឃុំនៅមន្ទីរសន្តិសុខពាយ័ព្យអស់រយៈពេលជាងពីរខែ បន្ទាប់មកក៏បានបញ្ជូនមកមន្ទីរឃុំឃាំងស-២១ តែម្តង ។ ឯកសាររបស់ ប៉ាឡាត់ មានចំនួន១៨ទំព័រ សរសេរដោយដៃ មិនមែនជាឯកសារប្រភេទចម្លើយសារភាពទេ តែជាកំណត់ហេតុរបស់អ្នកសួរចម្លើយឈ្មោះ វុធ (ពួកទី៣) និងឈ្មោះ អ៊ួន (នៅក្រុមក្តៅ) ។ ឯកសារកំណត់ហេតុនេះ ត្រូវបានធ្វើចប់នៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៧៨ ។ ខាងក្រោម គឺជាការដកស្រង់ទាំងស្រុងពីឯកសារកំណត់ហេតុរបស់ ប៉ាឡាត់ ៖

### ប្រវត្តិ និងសកម្មភាពចាប់ពីឆ្នាំ១៩៧០ រហូតដល់ថ្ងៃអង្គការចាប់ខ្លួន

នៅក្នុងឆ្នាំ១៩៧០ ឪពុករបស់ យ៉ាម ប៉ាឡាត់ ឈ្មោះ យ៉ាម បានធ្វើជាគិញឲ្យមេឃុំឈ្មោះ តែម នៅឃុំណាំប៉ាក់ ស្រុកអណ្តូងពេជ ខេត្តរតនគិរី ដោយមេឃុំ តែម ឲ្យប្រាក់ក្នុងមួយខែ៣០០



គ្រែសម្រាប់ឲ្យអ្នកទោសដេកនៅក្នុងបន្ទប់ឃុំឃាំងនៃមន្ទីរសន្តិសុខស-២១ ហើយដើម្បីការពារអ្នកទោសដែលមានបំណងលួចរត់គេចខ្លួន ឆ្មាំគុកបានដាក់ខ្នោះជើងអ្នកទោសភ្ជាប់ទៅគ្រែថែមទៀត ។ (រូបថតៈ សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង)

វៀល ។ បន្ទាប់ពីធ្វើគិញបានបីខែមក យ៉ាម ដែលជាឪពុករបស់ ប៉ាឡាត់ បានអប់រំកូនប្រុសរបស់ខ្លួន (ប៉ាឡាត់) ឲ្យធ្វើគិញដើម្បីស៊ើបយកការណ៍ពីខ្មែរក្រហម ។ ក្រោយមក យ៉ាម បាននាំ ប៉ាឡាត់ ដែលជាកូនឲ្យទៅស្គាល់មេឃុំ តែម ដើម្បីបើកប្រាក់ខែ ។ នៅក្នុងពេលនោះដែរ តែម បានប្រាប់ឲ្យ ប៉ាឡាត់ ទាក់ទងខ្មែរយរយៈរបស់ខ្លួនចំនួនបីនាក់ មានឈ្មោះ ចា ណាស់, ត្រាង និង យឹន អ្នកទាំងបីជាប្រជាជននៅភូមិរំបាងដើម្បីធ្វើសកម្មភាពជាមួយគ្នា ។ ក្រោយមកប្រហែលជាមួយខែ យ៉ាម បានឲ្យ ប៉ាឡាត់ ទាក់ទងភ្ជាប់ខ្មែរជាមួយឈ្មោះ កិ, ចា ម៉ាយ, តា ហឹង, ខុន និង វ៉ា ដើម្បីធ្វើសកម្មភាពដើរស៊ើបប្រជាជនណាដែលស្អប់ តែម ហើយមករាយការណ៍ឲ្យខ្លួន ។

ក្រោយពីទទួលបានការណែនាំពីឪពុក ប៉ាឡាត់ បានទៅទាក់ទងអ្នកទាំងប្រាំដែលមានឈ្មោះដូចខាងលើ ដើរធ្វើសកម្មភាពឃោសនាបំផុសប្រជាជនឲ្យស្អប់ខ្មែរក្រហម ហើយឃោសនាមិនឲ្យប្រជាជនរត់ចូលក្នុងព្រៃដោយលើកឡើងថា ចូលព្រៃមានការលំបាក វេទនា និងអត់ឃ្លាន ។ កន្លះខែក្រោយមក អង្គការបានជម្លៀសប្រជាជនក្នុងឃុំណាំប៉ាក់ ឲ្យចូលទៅនៅក្នុងព្រៃក្បែរភ្នំ ដែលពេលនោះ យ៉ាម, ប៉ាឡាត់ និងបក្ខពួកក៏ទៅជាមួយដែរ មានចម្ងាយពីភូមិរំបាង១០គីឡូម៉ែត្រ ។ រយៈពេលដែលទៅនៅក្នុងព្រៃ ប៉ាឡាត់ បានទាក់ទងជាមួយឪពុក និងបក្ខពួករបស់ខ្លួន ធ្វើចលនាបំផុសប្រជាជនពីការអត់ឃ្លានលំបាក និងបំផុសឲ្យប្រជាជនរត់មកខាងខ្មាំងវិញជាបន្តបន្ទាប់ ។ នៅព្រៃបានដប់ថ្ងៃ យ៉ាម បានលួចចេញមកទាក់ទងជាមួយមេឃុំ តែម ហើយអ្នកទាំងពីរបាននាំទាហានចំនួន១០០នាក់ សំដៅកៀរប្រជាជនពីក្នុងព្រៃទាំងអស់ឲ្យមកនៅក្បែរបន្ទាយប៉ុសពោយវិញ ។ ប្រាំថ្ងៃក្រោយមក ពេលអស់អង្ករ ប៉ាឡាត់ និងឪពុកម្តាយបានចេញទៅយកស្រូវនៅភូមិរំបាង ដែលជាភូមិចាស់របស់ខ្លួន និងជាភូមិកំពុងមានការប្រទាញប្រទង់គ្នា ចាប់តាំងពីប្រជាជនចេញទៅនៅក្នុងព្រៃ ។ ពេលនោះ ប៉ាឡាត់ និងឪពុកម្តាយត្រូវបានកងឈ្លបបដិវត្តន៍ចាប់ខ្លួនបានបញ្ជូនមកក្រោយ ។ ពេលដើរបានពាក់កណ្តាលផ្លូវ ប៉ាឡាត់ បានរត់គេចយករួចខ្លួនម្នាក់ឯងមកភូមិប៉ុសពោយវិញ និងបានរាយការណ៍ឲ្យមេឃុំ តែម ពីរឿងខ្មែរក្រហមចាប់ឪពុកម្តាយរបស់ខ្លួន ។

នៅក្នុងឆ្នាំ១៩៧០ ដដែល ប៉ាឡាត់ បានទៅស៊ីឈ្នួលឲ្យពេទ្យម្នាក់ឈ្មោះ ចឹយ នៅបកែវ ។ នៅទីនោះ ប៉ាឡាត់ បានជួបខ្មែរចាស់របស់ខ្លួនពីរនាក់មកស៊ីឈ្នួលគេដែរ ។ បន្ទាប់មក ចា ម៉ាយ បានហៅខ្មែររបស់ខ្លួនចំនួន៧នាក់ មកប្រជុំនៅផ្ទះរបស់ឈ្មោះ លឹុន មានឈ្មោះ ចា ម៉ាយ, វ៉ា, ប៉ាឡាត់, លឹុន, កា ញុច, កំព្រែ និង វិត ។ ការប្រជុំនេះ គឺមានគោលបំណងចង់ឲ្យខ្មែរយរយៈទាំងអស់បានស្គាល់គ្នា និងទាក់ទងគ្នាធ្វើសកម្មភាពជាបន្តទៀត ។ ក្រោយពេលប្រជុំហើយ ប៉ាឡាត់ និងបក្ខពួកបានដើរឃោសនា បំផុសប្រជាជនឲ្យស្អប់ខ្មែរក្រហម មិនឲ្យប្រជាជនចូលព្រៃ ដោយលើកហេតុផលពីការលំបាកវេទនា ។ ក្រៅពីនេះ ប៉ាឡាត់ និងបក្ខពួក បានតាមដានខ្មែរក្រហមនៅតាមភូមិប្រជាជនបកែវ និងកសាងកម្លាំងថ្មីបានបីនាក់មានឈ្មោះ ធុក ឡូញ, ថាំង យាង និង វ៉ាន់ ។

ឆ្នាំ១៩៧១ ស័ក្តិ៤ ឈ្មោះ ទូច នៅបន្ទាយបកែវ បានចាប់ ប៉ាឡាត់ ឲ្យធ្វើជាទាហាន និងបានបញ្ជូនមកបន្ទាយតាំងគោក ដែលស្ថិតនៅក្រោមបញ្ជារបស់ស័ក្តិ៣ឈ្មោះ អោក និងស័ក្តិ៤ ទូច ។ ស័ក្តិ៣ អោក បានចាត់តាំង ប៉ាឡាត់ ឲ្យធ្វើគិញ ហើយមកបង្កប់ខ្លួនក្នុងជួរប្រជាជននៅប៉ៃលិន ដើម្បីតាមដានសកម្មភាពរបស់ខ្មែរក្រហម និងអ្នកដែលលួចផ្តល់ជាស្រូវ-អង្ករឲ្យទៅខាងព្រៃ ។ ពេលមកដល់ប៉ៃលិន ប៉ាឡាត់ បានជួន ចា ម៉ាយ ដែលជាខ្មែរចាស់ បានមកធ្វើជាកម្មករជីកត្បូងនៅប៉ៃលិននេះដែរ ។ ចាប់ពីពេលនោះមក ប៉ាឡាត់, វ៉ា និង ចា ម៉ាយ បានទាក់ទងគ្នាជាខ្មែរយរយៈរហូតមក ហើយនៅចុងឆ្នាំ១៩៧១ ប៉ាឡាត់ បានកសាងកម្លាំងបានបីនាក់ ។

ឆ្នាំ១៩៧២ ប៉ាឡាត់, ចា ម៉ាយ និង វ៉ា បាននាំគ្នាទៅរាយការណ៍ឲ្យស័ក្តិ៣ អោក នៅបន្ទាយតាំងគោកអំពីកម្លាំងដែលក្រុមរបស់ខ្លួនកសាងបាន និងបានរាយការណ៍ពីមូលដ្ឋានរបស់បដិវត្តន៍ដែលពួកខ្លួនក្តាប់បានតាមរយៈប្រជាជនដែលចេញចូល ។ បន្ទាប់មក ស័ក្តិ៣ អោក បានចាត់ឲ្យ ប៉ាឡាត់ ចូលបង្កប់ខ្លួនក្នុងជួរបដិវត្តន៍ និងបានណែនាំឲ្យទាក់ទងខ្មែរចាស់ម្នាក់ឈ្មោះ គូ (ជាលេខាស្រុកប៉ៃលិននៅឆ្នាំ១៩៧២) ដែលកំពុងបង្កប់ខ្លួននៅក្នុងជួរបដិវត្តន៍ ហើយស័ក្តិ៣ អោក ក៏បានណែនាំ ប៉ាឡាត់ ឲ្យតាមដានយោធាបដិវត្តន៍ តាមដានមូលដ្ឋានសេដ្ឋកិច្ច និងឲ្យកសាងកម្លាំង

ថែមទៀត ហើយឲ្យរាយការណ៍មកខ្លួនវិញ តាមរយៈខ្មែរចាស់របស់ខ្លួននៅប៉ៃលិន ។ នៅពាក់កណ្ដាលឆ្នាំ១៩៧២ ប៉ាំឡាត់ បានចូលបង្កប់ខ្លួនក្នុងជួរបដិវត្តន៍ ស្របពេលនោះដែរ អង្គការបានជម្លៀសប្រជាជនឲ្យទៅនៅភូមិតាអែម ហើយ ប៉ាំឡាត់ និងបងម្នាក់ក៏បានចូលមកនៅក្នុងតំបន់រំដោះ ។ បន្ទាប់មក ប៉ាំឡាត់ ក៏ត្រូវបានអង្គការជ្រើសរើសឲ្យចូលមកនៅមន្ទីរស្រុកប៉ៃលិន ។ រយៈពេលប្រាំថ្ងៃក្រោយមក គូ ដែលជាលេខាស្រុកបានឲ្យយុវជនទាំងដប់នាក់ដែលទើបបានជ្រើសរើសធ្វើប្រវត្តិរូប ។ ពេលនោះ ប៉ាំឡាត់ បានប្រាប់ គូ ថា ខ្លួនធ្លាប់ធ្វើទាហានប្រាំបួនខែ ដោយស័ក្ដិ៣ អោក ចាប់បង្ខំឲ្យធ្វើ ។ ពេលនោះ គូ បានដក់ ប៉ាំឡាត់ ទុក ហើយចាត់ឲ្យធ្វើជានីរសារស្រុកប៉ៃលិន ឯយុវជនចំនួន៩នាក់ទៀត គូ ឲ្យដាក់ឲ្យទៅជាយោធាទាំងអស់ ។ បន្ទាប់មក គូ បាន ហៅ ប៉ាំឡាត់ មកជួបស្ងាត់ៗតែពីរនាក់ ហើយបានសួរបញ្ជាក់ចំៗ សង្កត់ពីរឿងធ្វើទាហានថាបានទាក់ទងជាមួយនរណាខ្លះ? ហើយចេញពីទាហានមានគោលបំណងយ៉ាងម៉េចខ្លះ? ហើយមុនចូលព្រៃមានការទាក់ទងជាមួយខ្មែរចាស់នៅប៉ៃលិនទេ? ពេលនោះ ប៉ាំឡាត់ ក៏បានឆ្លើយតាមត្រង់ប្រាប់ទៅ គូ វិញថា ខ្លួនជាខ្មែរចាត់តាំងរបស់ស័ក្ដិ៣ អោក នៅបន្ទាយតាំងគោក ហើយបានទទួលការចាត់តាំងឲ្យមកបង្កប់ខ្លួនក្នុងជួរបដិវត្តន៍ និងមានខ្មែររយៈទាក់ទងបីនាក់នៅប៉ៃលិននេះមានឈ្មោះ វិល, ហ៊ិត និង វិត និងឲ្យមកទាក់ទងជាមួយឈ្មោះ គូ ដែលជាខ្មែរចាស់របស់របស់ខ្លួន (ស័ក្ដិបី អោក) តែរកឈ្មោះ គូ មិនទាន់ឃើញទេ (ពេលនោះ ប៉ាំឡាត់ មិនទាន់ស្គាល់ គូ នៅឡើយទេ) ។ ក្រោយពេលស្ដាប់សេចក្ដីរាយការណ៍របស់ ប៉ាំឡាត់ នឹងដឹងថាជាខ្មែរចាត់តាំងរបស់ស័ក្ដិ៣ អោក ហើយ គូ ក៏បានអប់រំ ប៉ាំឡាត់ ឲ្យធ្វើសកម្មភាពប្រឆាំងបដិវត្តន៍បន្តទៀត ដោយបានណែនាំឲ្យស្គាល់ខ្មែររយៈរបស់ខ្លួនពីរនាក់ទៀត មានឈ្មោះ អ៊ួម និង សឿន និងបន្តធ្វើសកម្មភាពបំផុសប្រជាជនឲ្យរត់ចេញពីតំបន់រំដោះចូលតំបន់ខ្មាំង និងតាមដានរកកន្លែងសំខាន់ៗរបស់បដិវត្តន៍ ។

នៅចុងឆ្នាំ១៩៧២ គូ បានចាត់ ប៉ាំឡាត់, អ៊ួម និង សឿន ឲ្យទៅទាក់ទងខ្មែររយៈចាស់របស់ខ្លួនបីនាក់ទៀត មានឈ្មោះ រះ, វិន និង ហួវ ដើម្បីរួមគ្នាធ្វើសកម្មភាពនៅក្នុងមន្ទីរស្រុកប៉ៃលិន គឺដើរបំផុសប្រជាជនឲ្យរត់ពីតំបន់រំដោះចូលក្នុងតំបន់ខ្មាំង និងតាមដានរកមើលមន្ទីរសំខាន់ៗរបស់បដិវត្តន៍ ។ តមកទៀត គូ បានណែនាំ ប៉ាំឡាត់, អ៊ួម និង សឿន ឲ្យស្គាល់ខ្មែរចាស់បួននាក់ទៀត មានឈ្មោះ ហ៊ា អនុលេខាស្រុកប៉ៃលិនឆ្នាំ១៩៧២, ពៅ សមាជិកគណៈស្រុកប៉ៃលិនឆ្នាំ១៩៧២, ដេវ កម្មាភិបាលអប់រំប្រជាជននៅតំបន់ប្រទាញប្រទង់ឆ្នាំ១៩៧២ និងឈ្មោះ សុង កម្មាភិបាលអប់រំប្រជាជននៅតំបន់ប្រទាញប្រទង់ឆ្នាំ១៩៧២ ងាយស្រួលទាក់ទងគ្នាពេលធ្វើសកម្មភាព ហើយបើមានសកម្មភាពអ្វី ត្រូវរាយការណ៍ឲ្យឈ្មោះទាំងបួនខាងលើ ។

ដើមឆ្នាំ១៩៧៣ គូ បានដក ប៉ាំឡាត់ ឲ្យឈប់ធ្វើជានីរសារ ហើយឲ្យមកធ្វើយោធានៅស្រុកប៉ៃលិន តែនៅរក្សាការទាក់ទងខ្មែររយៈចាស់ដដែល ។ រយៈពេលមកនៅយោធាស្រុក ប៉ាំឡាត់ មិនបានកសាងកម្លាំងបន្ថែមទេ ។ នៅដើមឆ្នាំ១៩៧៤ អង្គការក៏បានដក ប៉ាំឡាត់ ឲ្យមកនៅយោធាតំបន់៣ ។ នៅទីនោះបានមួយថ្ងៃ ឈ្មោះ ដេវ (អ្នកទទួលខុសត្រូវកន្លែងដឹកត្បូង) ក៏បានមកយក ប៉ាំឡាត់ ឲ្យទៅដឹកត្បូងនៅបឡាង តំបន់១ បន្ទាប់មក គូ បានប្រាប់ ប៉ាំឡាត់ ឲ្យទៅទាក់ទងឈ្មោះ យុត ដែលជាខ្មែរចាស់របស់ខ្លួន ។ នៅពាក់កណ្ដាលឆ្នាំ១៩៧៤ អង្គការបានដក ប៉ាំឡាត់, អ៊ួម និង សឿន ឲ្យមកនៅខាងដឹកជញ្ជូនភាគពាយ័ព្យតំបន់៣ ។ ពេលនោះ ប៉ាំឡាត់ បានជួបខ្មែរចាស់ម្នាក់ឈ្មោះ សុង មាននាទីក្ដាប់ខាងដឹកជញ្ជូនភាគ ។ លុះដល់ចុងឆ្នាំ១៩៧៤ សុង បានប្រាប់ ប៉ាំឡាត់, អ៊ួម និង សឿន ឲ្យទៅទាក់ទងជាមួយខ្មែររបស់ខ្លួនពីរនាក់ឈ្មោះ ឡាប់ និង គឹម ធ្វើសកម្មភាពយកឡានដាក់ទទឹងផ្លូវ និងដាក់គ្រាប់បែកដើម្បីកាត់ផ្លូវដឹកជញ្ជូន ។

ខែមេសា ឆ្នាំ១៩៧៥ អង្គការបានដក ប៉ាំឡាត់ និងក្រុមឲ្យមកនៅវរសេនាតូចលេខ២៧ កងពលទី១ នៅពេលនោះ ប៉ាំឡាត់ មាននាទីជាអនុក្រុម ។ នៅអង្គភាពវរសេនាតូចលេខ២៧នេះ ប៉ាំឡាត់ បានមកទាក់ទងឈ្មោះ ផែន ប្រធានកងតូចក្នុងឆ្នាំ១៩៧៥ និងឈ្មោះ គុង ជាមេពួកនៅវរសេនាតូចលេខ២៧ ក្នុងឆ្នាំ១៩៧៥ តាមការណែនាំរបស់ សុង ដើម្បីធ្វើសកម្មភាពនៅក្នុងកង ។ បន្ទាប់ពីបានស្គាល់គ្នាហើយ សុង បានចាត់ឲ្យអ្នកទាំងបី (ប៉ាំឡាត់ ផែន និង គុង) ឲ្យធ្វើសកម្មភាព គឺ ១) នៅពេលជួបខ្មាំងមិនឲ្យបាញ់ខ្មាំង, ២) ឲ្យយកខ្មែរលួសទៅចងកាត់ទទឹងផ្លូវ និងទី៣)

ចាំគប់អ្នកដំណើរតាមផ្លូវ ។ នៅខែកក្កដា ប៉ាឡាត់ ត្រូវបានអង្គការផ្លាស់ឲ្យទៅនៅវរសេនាតូចលេខ៣៣ ដោយមាននាទីជាអនុក្រុម ។ ពេលនោះ ផែន និង តុង ក៏បានប្រាប់ឲ្យ ប៉ាឡាត់ ធ្វើការទាក់ទងខ្សែរយៈពីរនាក់ផ្សេងទៀតឈ្មោះ រឿម មេពួកវរសេនាតូច៣៣ និង ម៉ិក មេក្រុមវរសេនាតូច៣៣ ។ ចំណែក សុង នៅពេលនោះក៏ត្រូវបានអង្គការដក់ពីដឹកជញ្ជូនឲ្យមកក្តាប់ខាងសន្តិសុខភាគពាយ័ព្យ ហេតុនេះ ប៉ាឡាត់ បាននៅជាប់ជាមួយ សុង រហូតមក ។

ខែមិថុនា ឆ្នាំ១៩៧៦ អង្គការបានដក ប៉ាឡាត់ ឲ្យទៅធ្វើស្រែនៅភូមិកំពីង ឃុំអូរប្រាសាទ ស្រុកមង្គលបូរី (ក្នុងឯកសារសរសេរឃុំអូរប្រាសាទ ស្រុកអង្គលបូរី) តំបន់៣ តែស្ថិតនៅក្នុងអង្គភាពវរសេនាតូច៣៣ដដែល ហើយបានទទួលនាទីជាអនុសេនាតូច ។ នៅពេលនោះដែរ សុង បានប្រាប់ ប៉ាឡាត់ ឲ្យទាក់ទងជាមួយ ឈ្មោះ លាង អនុកងធំធ្វើស្រែ (ចាប់ខ្លួនហើយ) , សេង អនុកងធំធ្វើស្រែ (ចាប់ខ្លួនហើយ) , ឡុំ ប្រធានកងតូច (ចាប់ខ្លួនហើយ) , លី យុទ្ធជនធ្វើស្រែដែលជាខ្សែរយៈចាស់របស់ខ្លួន ហើយបានដើរធ្វើសកម្មភាពបំផ្លិចមិនឲ្យប្រជាជនខិតខំធ្វើការងារ ។ បន្ទាប់មក នៅចុងឆ្នាំ១៩៧៦ ប៉ាឡាត់ និងបក្ខពួកបានកសាងកម្លាំងបានចំនួនបួននាក់ថែមទៀតមានឈ្មោះ ម៉ៅ យុទ្ធជនធ្វើស្រែ (ចាប់ខ្លួនហើយ) , ឈ្មោះ ផា មេពួកនៅធ្វើស្រែ (ចាប់ខ្លួនហើយ) , ឈ្មោះ វី យុទ្ធជនធ្វើស្រែ (ចាប់ខ្លួនហើយ) និង ឈ្មោះ ខាន់យុទ្ធជនធ្វើស្រែ (ចាប់ខ្លួនហើយ) ។ ក្រោយពីកសាងកម្លាំងទាំងអស់នេះបានហើយ ប៉ាឡាត់ រួមជាមួយកម្លាំងក្បត់ដែលកសាងបានទាំងចាស់ទាំងថ្មីទាំងអស់បានដើរធ្វើសកម្មភាពរួមគ្នា បំផុសមហាជន មិនឲ្យធ្វើការងាររហូតដល់ខែសីហា ឆ្នាំ១៩៧៧ ត្រូវបានអង្គការចាប់ខ្លួនតែម្តង (នៅឆ្នាំ១៩៧៧ នេះដែរ ប៉ាឡាត់ ត្រូវបានអង្គការចាត់តាំងឲ្យធ្វើជាប្រធានការដ្ឋានសន្តិសុខភាគពាយ័ព្យ) ។ **ឆេង ខ៉េង**



អ្នកទោសដែលត្រូវបានចាប់បញ្ជូនមកឃុំឃាំងនៅអតីតមន្ទីរសន្តិសុខស-២១ (គុកទួលស្លែង) ។ អ្នកទោសទាំងអស់ត្រូវបានឆ្មាំគុកវាយធ្វើទារុណដើម្បីសួរយកចម្លើយមុននឹងយកទៅសម្លាប់ចោល ។ (រូបថតៈ សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង)

# បំផុសចលនារៀនសូត្រលក្ខន្តិកៈបក្សឱ្យជាប់ដើម្បីពង្រឹង ពង្រីកឯកភាពផ្ទៃក្នុងបក្សឱ្យកាន់តែខ្លាំងក្លាបម្រើ ភារកិច្ចបដិវត្តន៍សង្គមនិយម និងការពារប្រទេស

*ដកស្រង់ចេញពីឯកសារទង់បដិវត្តន៍លេខ៧ ខែកក្កដា ឆ្នាំ១៩៧៦ D២១៤១៦*

***អំពីសភាពការណ៍ និងសំណូមពរដែលនាំឲ្យយើងយកចិត្តទុកដាក់រៀនសូត្រលក្ខន្តិកៈរបស់បក្ស***

*១) តាមពិសោធនៃបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យរបស់យើងកន្លងមក យើងបានរៀបចំលក្ខន្តិកៈរបស់យើងបានត្រឹមត្រូវនៅឆ្នាំ១៩៦០ ។ ជំនាន់នោះ ខ្មាំងនៅកាន់អំណាច ហើយវាធ្វើទុក្ខបុកម្នេញយើង ។ យើងមិនបានរៀនសូត្រលក្ខន្តិកៈបានត្រឹមត្រូវទេ ។ លបរៀនបានបន្តិចបន្តួច ។ រហូតដល់ឆ្នាំ១៩៧០ ហើយ ក៏ការយល់ដឹងលក្ខន្តិកៈរបស់បក្ស ក្នុងក្របខណ្ឌបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ក៏នៅមានការខ្វះខាតច្រើន ។ ការយល់ដឹងអំពីលក្ខន្តិកៈរបស់បក្ស បានស្តួចស្តើងណាស់ ។ បើយល់លក្ខន្តិកៈស្តួចស្តើង ការយល់ដឹងមាគ៌ាយុទ្ធសាស្ត្រ-យុទ្ធវិធី មាគ៌ាផ្សេងៗរបស់បក្ស ក្នុងក្របខណ្ឌបដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យក៏ខ្វះខាត ។ បច្ច័យគឺមួយផ្នែកយើងឯកភាពគ្នា មួយផ្នែកទៀត ក៏មិនសូវឯកភាពគ្នា ។ មិនជ្រួតជ្រាបមាគ៌ាក្នុងន័យអនុវត្ត ។*

*រហូតដល់ឆ្នាំ៦២-៦៣-៦៤ យើងបកស្រាយលក្ខន្តិកៈបក្សតាមម្នាក់ៗ ។ ជួនកាលយកការយល់ដល់តាមលក្ខន្តិកៈបក្សបរទេស មកធ្វើជាលក្ខន្តិកៈរបស់ខ្លួន ។ ដូច្នេះជំហរបក្សរបស់ម្នាក់ៗមិនសូវរឹងទេ ។ ឯកភាពផ្ទៃក្នុងតាមមាគ៌ា តាមគោលជំហររបស់*



*កម្មាភិបាលខ្មែរក្រហមចូលរួមវគ្គរៀនសូត្រ អប់រំ បំពាក់បំប៉នទ្រឹស្តីនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា*

បក្សមិនសូវរឹងទេ ។

ក្រោយឆ្នាំ១៩៧០ យើងបើកសាលាទូទាំងប្រទេស ផ្សាយលក្ខន្តិកៈបានធំទូលាយ ។ តាមរយៈនេះ ឯកភាពផ្ទៃក្នុងបក្ស បានរឹងមាំបណ្តើរៗ តែក៏នៅមានការខ្វះខាតច្រើន ។ ការខ្វះខាតនេះហើយ នាំឲ្យឯកភាពមិនទាន់ខ្លាំងក្លា ។ តែមិនទាន់ឯកភាពក្នុងឋានៈម្ចាស់ការ ក្នុងឋានៈវាយសម្រុក ។

ឥឡូវ យើងមានលក្ខណៈសម្បត្តិខុសពីពេលមុនច្រើនណាស់ ។ដូច្នេះហើយ យើងត្រូវយកចិត្តទុកដាក់រៀនសូត្រលក្ខន្តិកៈរបស់បក្សរបស់យើង ចាប់ពីដើមទីនៃបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយម ។ ដូច្នេះ វាខុសពីរយៈកាលបដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យ ។ បើយើងចាប់ផ្តើមរៀន និងយល់លក្ខន្តិកៈពីដើមទីយ៉ាងនេះ យើងជ្រួតជ្រាបមាគ៌ារបស់បក្ស ឯកភាពផ្ទៃក្នុងបក្សកាន់តែខ្លាំង ។ ភាសាតែមួយ មាគ៌ាតែមួយ លាក់ការណ៍តែមួយសរសៃញាក់តែមួយ ។ នេះជាសំណូមពរ ជាហេតុផលដែលនាំឲ្យយើងរៀនលក្ខន្តិកៈរបស់បក្ស ។ ឆ្នាំនេះក៏រៀន ឆ្នាំក្រោយក៏រៀនជាបន្តបន្ទាប់ ។ យកចលនាដាក់ស្តែងមកពិនិត្យការខុសត្រូវ ក្នុងការក្តាប់ន័យអនុវត្តលក្ខន្តិកៈរបស់បក្ស ។ ធ្វើយ៉ាងនេះ ខ្លាំងក្លាណាស់ ។ យើងឯកភាពគ្នាជាធ្លុងមួយ ឯកភាពជាមាគ៌ា ជាយុទ្ធសាស្ត្រ មាគ៌ាជាយុទ្ធវិធី ជាមាគ៌ាប្រយុទ្ធ ។

២) បក្សយើង កំណត់មាគ៌ាជាយុទ្ធសាស្ត្រថ្មី របស់យើង គឺបន្តបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម ។ និយាយរួមចលនាលឿនណាស់ បើនិយាយក្នុងក្របខណ្ឌប្រទេសយើង ដែលយើងធ្លាប់ធ្វើមក ។ បើពិនិត្យជាចលនាក្នុងក្របខណ្ឌសកលលោក ក៏យើងលឿនដែរ ។

យើងកសាងសង្គមនិយមបានរហ័ស ការពារប្រទេសបានល្អ ក្នុងរយៈប្រាំមួយខែនេះ ។ ប៉ុន្តែពិនិត្យទិដ្ឋភាពមួយទៀតជាសត្យានុម័តិ និងជាអត្តនោម័តិ ។ ជាសត្យានុម័តិ មារសត្រូវ វាចង់បំផ្លិចបំផ្លាញបដិវត្តន៍យើង កុំឲ្យទៅជាគំរូបាន ទៅជាឧទាហរណ៍បាន ។ វាចង់មកយាយី សង្កត់សង្កិនបដិវត្តន៍យើងពីព្រោះវាឃើញចលនាបដិវត្តន៍យើងមានពន្លក មានជាភេទដែលខ្លាំងក្លា ។ នេះជាទិដ្ឋភាពលំបាកដែលយើងត្រូវឃើញ ។ ទិដ្ឋភាពយាយី វានៅជាប្រចាំ ។ បំផ្លាញយើងតាមវិធីគ្រប់បែបយ៉ាង ។ បំផ្លាញពីក្រៅបំផ្លាញពីក្នុង ។ តែពីក្រៅវាយយើងមិនបានទេ ។ ទាល់តែវាយពីក្នុង ។ ដើម្បីវាយពីក្នុងបាន ទាល់តែវាយមាគ៌ា ធ្វើឲ្យមាគ៌ាប្រឡូកប្រឡល់នៅក្នុងផ្ទៃក្នុងបក្ស ផ្ទៃក្នុងកងទ័ព ផ្ទៃក្នុងប្រជាជនយើង ដើម្បីងាយបំបែក ។ គេបញ្ចូលមាគ៌ារបស់គេ បញ្ចូលទស្សនៈរបស់គេ បញ្ចូលមាគ៌ាចាត់តាំងរបស់គេ តាមវិធីផ្សេងៗ ពិសេសវិធីសម្ងាត់ ។ នេះជាសភាពការណ៍ដែលនាំឲ្យយើងត្រូវពង្រឹងគោលជំហរ ឯកភាពមាគ៌ារបស់យើង ។ ឯកភាពជាធ្លុងមួយ បានខ្លាំងចូលមិនចុះ ។ ឬបើវាបន្លំចូល បក្ស កងទ័ព ប្រជាជន កម្មករ-កសិករយើងវាយកម្ទេចបាន ។ ដើម្បីឯកភាព ទាល់តែរៀនសូត្រពាក់ព័ន្ធក្នុងចលនាជាបន្តបន្ទាប់ ។ ធ្វើយ៉ាងនេះ បានមាគ៌ាតែមួយគោលជំហរតែមួយ ។ លក្ខន្តិកៈជាឯកសារប្រមូលផ្តុំមាគ៌ាទាំងអស់ ។ ឃើញយ៉ាងនេះ បានយើងរៀនសូត្រលក្ខន្តិកៈ រៀនជាសមូហភាពរៀនជាឯកជន ។

ពិតមែនតែយើងកសាងសង្គមនិយមបានរហ័ស បានល្អក្នុងរយៈប្រាំមួយខែនេះ តែយើងមិនទាន់ជ្រួតជ្រាបមាគ៌ារបស់បក្ស បានណែនាំនៅឡើយទេ មិនទាន់ខំរៀនសូត្រលក្ខន្តិកៈបក្សឲ្យបានហ្មត់ចត់ទេ ។ មិនទាន់ជ្រួតជ្រាបលាក់ការណ៍នៃលក្ខន្តិកៈឲ្យបានល្អទេ ។

ឧទាហរណ៍ យើងចាប់អារម្មណ៍ពីវិន័យរបស់បក្សមិនទាន់ជ្រៅជ្រះទេ ។ សូម្បីតែក្នុងរយៈប្រាំមួយខែនេះ ការប៉ះពាល់វិន័យរបស់បក្សក៏មានច្រើន ។ មួយផ្នែកក៏គោរព មួយផ្នែកទៀតក៏មិនគោរព ។ ស្មានតែបុគ្គលរបស់ខ្លួន ធំជាងវិន័យរបស់បក្ស ធ្វើអីខ្លួនមិនបាន ។ ជួនណា អ្នកខ្លះហ៊ានប្រឆាំងបក្ស ដោយមិនគិតពីវិន័យរបស់បក្ស ហ៊ានប្រព្រឹត្តខុសសីលធម៌ជាខ្សែសង្វាក់ ដោយមិនគិតពីវិន័យរបស់បក្ស ។

ដូច្នេះ ចាំបាច់ត្រូវរៀនសូត្រលក្ខន្តិកៈបក្ស ។ រៀនសូត្រជាបុគ្គល រៀនសូត្រជាសមូហភាព ដកពិសោធក្នុងចលនាឲ្យទៅជាសរសៃញាក់ ។

បើយើងជ្រួតជ្រាបលក្ខន្តិកៈបក្ស ខ្មាំងចូលមិនចុះទេ ។ សមូហភាពក៏ខ្លាំង បុគ្គលក៏ខ្លាំង ។ អនុវត្តភារកិច្ចបដិវត្តន៍ខ្លាំងក្លា ។ បើយើងពិនិត្យការដាក់ស្តែងរបស់យើង យើងឃើញ ។ ជួនណាយើងដក់ពីរឿងបីគោនមួយហិកតា យើងភ្លេចកសាងបក្ស ។ តែ

*បើរៀនលក្ខន្តិកៈទៅ នាំឲ្យយើងឃើញថា ត្រូវពង្រឹងពង្រីកបក្ស ។ អំពីលាក់ការណ៍ និងគោលជំហរនយោបាយជាមូលដ្ឋានរបស់បក្ស ក្នុងរយៈកាលថ្មីនៃបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយម*

***សំណួមពរៈ*** *យើងរៀនសូត្រផ្នែកនេះ ដើម្បីក្ដាប់កម្មវិធីនយោបាយរបស់បក្សទាំងមូល ។ គោលការណ៍រួមទាំងអស់របស់បក្សនៅក្នុងផ្នែកនេះ ។ កម្មវិធីទូទៅរបស់បក្ស សរុបទាំងអស់នៅក្នុងនេះ ។ គោលជំហរជាមូលដ្ឋាននៅក្នុងនេះ ។*

## ១) បក្សបដិវត្តន៍យើង មានឈ្មោះជាបក្សកុម្មុយនីស្តកម្ពុជា

*ខនេះមានន័យច្រើនៈ*

*១.បក្សយើងដាក់ឈ្មោះយ៉ាងនេះ គឺដើម្បីឲ្យជ្រះស្រឡះពីបក្សឯទៀត កុំឲ្យជំពាក់ជំពិនជាមួយបក្សឯទៀត ហើយម្យ៉ាងទៀត សមស្របទៅតាមការរីកចម្រើននៃចលនាបដិវត្តន៍របស់យើងផង ។*

*២.យើងបានដាក់ឈ្មោះជា បក្សកុម្មុយនីស្តកម្ពុជា ដោយមហាសន្និបាតសម្រេច ។ ដូច្នេះ បក្ខជនទាំងអស់ ត្រូវឈរលើបក្សកុម្មុយនីស្តកម្ពុជា កុំឈរលើបក្សអ្វីដែលក្រៅពីបក្សកុម្មុយនីស្តកម្ពុជា ។ ដាច់ខាតត្រូវប្រយុទ្ធនឹងមារសត្រូវណាដែលចង់ប្រែក្លាយបក្សកុម្មុយនីស្តកម្ពុជា ចង់បំផ្លិចបំផ្លាញបក្សកុម្មុយនីស្តកម្ពុជា ពីព្រោះក្នុងសកលលោកសព្វថ្ងៃ គេកំពុងតែបង្កើតជាបក្សមួយបក្សពីរ ។ ត្រូវឈរលើបក្សកុម្មុយនីស្តកម្ពុជាដាច់ខាត នៅក្នុងបក្ស នៅក្នុងកងទ័ព នៅក្នុងប្រជាជន ។*

*ឈរលើគោលជំហរបក្សកុម្មុយនីស្តកម្ពុជា ត្រូវឈរលើលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា មិនមែនឈរលើគោលជំហរលក្ខន្តិកៈបក្សបរទេសណាទេ ។*

*កន្លងមក មានគេចង់បង្កើតបក្សមួយផ្សេង ពិសេសពីឆ្នាំ៦៦ ដែលយើងកំណត់យកមាគ៌ាឯករាជ្យ ម្ចាស់ការ ។ ឆ្នាំ៦៨-៦៩ គេត្រៀមខ្លាំងទៀត ។ តែយើងឯកភាពគ្នាទៅ គេជ្រៀតចូលមិនចុះ ។ តទៅមុខទៀត គេនឹងបន្តជ្រៀតចូលទៀត ។ ដូច្នេះ យើងត្រូវឈរលើគោលជំហរបក្សកុម្មុយនីស្តកម្ពុជា ។ អ្វីដែលខុសពីលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា បក្ខជន និងកម្មាភិបាលរបស់បក្ស ត្រូវប្រឆាំងដាច់ខាត ។*

## ២) បក្សកុម្មុយនីស្តកម្ពុជា ជាបក្សរបស់វណ្ណៈកម្មករ

*១.ជាបក្សរបស់វណ្ណៈកម្មករ មិនមែនជាបក្សរបស់វណ្ណៈកសិករ របស់អនុធន បញ្ញាជន នាយទុន សក្ដិភូមិទេ ។ ដូច្នេះបក្សយើងត្រូវមានធាតុពិត ជាវណ្ណៈកម្មករ មិនត្រូវមានធាតុជាវណ្ណៈផ្សេងៗទៀតទេ ។ វណ្ណៈផ្សេងៗទៀតដូចជាវណ្ណៈសក្ដិភូមិ នាយទុន សុទ្ធតែមានកម្មសិទ្ធិ ។ វណ្ណៈអនុធន បញ្ញាជន ក៏មានកម្មសិទ្ធិ ។ វណ្ណៈកសិករ មានកម្មសិទ្ធិតិចជាងគេ តែក៏នៅជំពាក់ជំពិននឹងកម្មសិទ្ធិដែរ ។ មានតែវណ្ណៈកម្មករទេ ដែលអធន ។*

*ឯធាតុពិតរបស់វណ្ណៈកម្មករ វាខុសពីធាតុពិតវណ្ណៈផ្សេងទៀត ។ វណ្ណៈកម្មករ មានធាតុពិតបីយ៉ាងៈ*

- *ធាតុលះបង់ៈ គ្មានកម្មសិទ្ធិអ្វីទាំងអស់ ។ ទ្រាំទ្រ ពុះពារមោះមុត ។ ជំហរនេះខុសពីជំហរវណ្ណៈផ្សេងៗទៀត ។*

*យើងចង់កសាងគោលជំហរអធននេះ បានវាជ្រះស្រឡះ គ្មានជំពាក់ជំពិនអ្វីទាំងអស់ ។*

- *គោលជំហរចាត់តាំង គោលជំហរសមូហភាពខ្ពស់ៈ ដូច្នេះមានធាតុពិត វិន័យអង្គការខ្ពស់បំផុត ។ វណ្ណៈដទៃទៀតសេរី ។*
- *ធាតុពិតពលកម្មៈ ម្ចាស់ដីអត់ពលកម្ម នាយទុនអត់ពលកម្ម អនុធនកសិករកណ្ដាល ពលកម្មដែរ តែដើម្បីកម្មសិទ្ធិឯកជន ហើយកម្លាំងទ្រាំទ្រ មិនដល់កម្មករទេ ។ កម្មករទ្រាំទ្រជាងគេ ធ្វើពលកម្មច្រើនជាងគេ ច្នៃប្រឌិតជាងគេដើម្បីបម្រើសមូហភាព បម្រើសង្គម ។*

*ដូច្នេះ ជាធាតុចម្រើនជាងគេបំផុត លើគ្រប់ផ្នែក ។ យើងម្នាក់ៗ ជាសមាជិករបស់បក្ស ត្រូវខំកសាងខ្លួន ទៅតាមគោលជំហរនេះ ។ គោលជំហរលះបង់ គោលជំហរសមូហភាព វិន័យអង្គការ គោលជំហរពលកម្ម ច្នៃប្រឌិត ។*

- *បក្សកុម្មុយនីស្តកម្ពុជា បន្តដឹកនាំបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម តទៅទៀត ដោយផ្ដាច់មុខដាច់ខាត និងគ្រប់ផ្នែក ។*

*ដូច្នេះ ចូលបក្ស ត្រូវដឹកនាំបដិវត្តន៍ ។ ដូច្នេះនៅស្ងៀមមិនបានទេ ។ ត្រូវតែដឹកនាំមហាជន ។ ដឹកនាំតាមមាគ៌ាបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយម ។ ដូច្នេះត្រូវមានធាតុដឹកនាំ និងមានសកម្មភាពដឹកនាំមហាជន ដោយផ្ដាច់មុខដាច់ខាត និងគ្រប់*

ផ្នែក ។ បក្ខជនយើងសកម្មប្រយុទ្ធបានបក្សយើងប្រកាន់នាទីជាបញ្ញាការបាន ។ យើងកសាងបក្សយើង តាមទិសនេះបណ្ដើរៗ ប្រកាន់នាទីដឹកនាំនយោបាយ សតិអារម្មណ៍ ចាត់តាំង ។ ដឹកនាំដោយធ្វើគំរូជាក់ស្ដែងឲ្យមហាជន ។

បើចូលមកក្នុងបក្សហើយ មិនប្រកាន់នាទីដឹកនាំមហាជន ធ្វើធម្មតាយករួចខ្លួននោះ មិនមានធាតុពិតរបស់បក្សទេ ។

**ដឹកនាំគ្រប់ផ្នែកៈ** យើងម្នាក់ៗ មិនអាចដឹកនាំគ្រប់ផ្នែកបានភ្លាមទេ ។ តែត្រូវខំបណ្ដើរៗ ។ តែត្រូវមានទស្សនៈគោលជំហរដឹកនាំគ្រប់ផ្នែក ឲ្យរឹងមាំជានិច្ច ។

២.ធាតុពិតរបស់បក្ស

◆ ជាអង្គការខ្ពស់បំផុតរបស់វណ្ណៈកម្មករៈ គ្មានអង្គការណាខ្ពស់ជាងនេះទៀតទេ ។ ដូច្នេះ ម្នាក់ៗ គោរពអង្គការខ្ពស់បំផុត បុគ្គលក៏អីចឹង សមូហភាព អង្គភាពតូច-ធំ ក៏អីចឹង ។ កុំឲ្យអង្គភាពមួយតូចក្ដី ធំក្ដី វាធំជាងបក្ស ។ កុំឲ្យបុគ្គលមួយ ទោះជាឋានៈណាក៏ដោយ មានស្នាដៃយ៉ាងណាក៏ដោយ វាធំជាងបក្ស ។ កន្លងមក និយាយរួម មិនមានបញ្ហាអីទេ ។ តែជួនកាលបុគ្គលមិនគោរពបក្ស ហើយដាក់លក្ខខណ្ឌលើបក្សទៅទៀត ។ ដូច្នេះខុសពីខ្លឹមសារលក្ខន្តិកៈ ។

◆ ជាកងទ័ពស្រួចៈ គឺមោះមុត អង់អាចក្លាហានបំផុត ។ ប្រៀបធៀបនឹងមហាជនត្រូវខ្លាំងក្លាជាងគេ ។ ទ្រាំទ្រលំបាកជាងគេខាងសម្ភារ ខាងផ្លូវកាយ ខាងផ្លូវចិត្ត ខាងផ្លូវមនោសញ្ចេតនា ។ ប្រយុទ្ធក៏ត្រូវស្រួចជាងគេ ។

បច្ចុប្បន្ននេះ នៅមានបក្ខជន និងកម្មាភិបាលយើងមួយចំនួនខ្សោយជាងមហាជន ។ ប្រយុទ្ធក៏ខ្សោយជាងមហាជន ។ បក្ខជន និងកម្មាភិបាលទាំងនេះ ត្រូវតែខិតខំឲ្យទាន់ចលនា ។ បើមិនដូច្នោះទេ ចលនាមហាជននឹងជម្រុះចោលហើយ ។

◆ ជាអគ្គបញ្ញាការៈ គឺគ្រប់គ្រង និងចាត់ចែងការងារបដិវត្តន៍ទាំងអស់ ដូច្នេះចូលបក្សមិនមែននៅស្ងៀមទេ ។ ត្រូវសកម្មប្រយុទ្ធ ។ អគ្គបញ្ញាការ គឺគ្រប់គ្រងខាងនយោបាយ សតិអារម្មណ៍ ចាត់តាំង មិនមែនបញ្ញាអាជ្ញាទេ ។

◆ ធាតុពិត ជាប់ជិតស្និទ្ធនឹងមហាជនៈ បានន័យថា មានមហាជននៅជាមួយបក្ស ។ គណៈកម្មាធិការបក្សមួយ នៅក្នុងអង្គភាពមួយ បើគ្មានមហាជននៅជាមួយ មិនខ្លាំងទេ ។ នៅជាមួយ ក្នុងន័យសតិអារម្មណ៍នៅជាមួយ នយោបាយនៅជាមួយ ចាត់តាំងនៅជាមួយ ។ ដើម្បីមហាជននៅជាមួយ លុះត្រាតែធ្វើការងារសតិអារម្មណ៍ នយោបាយ ចាត់តាំងល្អ មាគ៌ាត្រឹមត្រូវ ដឹកនាំត្រឹមត្រូវ ។

### ៣) គោលជំហរជាយុទ្ធសាស្ត្រថ្មី បច្ចុប្បន្នរបស់បក្ស

១.ត្រូវបន្តធ្វើបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមនៅកម្ពុជា ហើយឈានទៅកុម្មុយនីស្តនៅកម្ពុជា ។ បក្ខជនត្រូវធ្វើបដិវត្តន៍សង្គមនិយម ។ បើមិនធ្វើ មិនបំពេញភារកិច្ចនេះទេ ។ បើប្រឆាំងនឹងបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយម គឺប្រឆាំងនឹងបក្ស ។

**ឈានទៅកុម្មុយនីស្តនិយមៈ** កុំឈប់តាមផ្លូវ កុំងាកចេញពីផ្លូវនេះ ។ ត្រូវទៅរហូត គេមិនទៅ ក៏យើងត្រូវតែទៅ ។ នេះជាគោលជំហរដែលត្រូវកសាង ។

កន្លងមក ធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ មានការលំបាកច្រើន ។ លំបាកខ្មាំងរាតត្បាត ទារុណកម្ម លំបាកសម្ភារ លំបាកមនោសញ្ចេតនា ។ ដូច្នេះ បុគ្គលខ្លះជ្រុះ ។ តែមហាជនគេទៅ ។

បច្ចុប្បន្ននេះ ធ្វើបដិវត្តន៍សង្គមនិយម ក៏មានការលំបាក ។ ពីព្រោះ បដិវត្តន៍សង្គមនិយម ជាការតស៊ូវណ្ណៈជ្រាលជ្រៅនៅក្នុងបក្ស នៅក្នុងកងទ័ព នៅក្នុងជួរបដិវត្តន៍ទាំងមូល ក្នុងសហជីពកម្មករ ក្នុងសហករណ៍កសិករ និងក្នុងសង្គមជាតិទាំងមូល ។ ពីព្រោះខ្មាំងវាវាយយើងជាប់ ។ តទៅមុខទៀត វាវាយទៀត ។ តែយើងត្រូវតែទៅ ។ យើងមិនថយក្រោយទេ ។ យើងត្រូវបន្តបដិវត្តន៍សង្គមនិយម ហើយបន្តឲ្យខ្លាំង ។ ជួបឧបសគ្គយ៉ាងណាក៏ដោយ ជាអត្តនោម័តិក្ដី ជាសត្យានុម័តិក្ដី ត្រូវពុះពារដើរទៅមុខទៀត ។ បញ្ហាលំបាកមានជាធម្មតា ។

ឧទាហរណ៍ៈ នៅឆ្នាំ៧២-៧៣ បក្សជាទូទៅឯកភាព ។ តែកម្មាភិបាលមួយចំនួនតិចតួច ថាយើងវាយមិនឈ្នះទេ ត្រូវតែចរចា ។ នេះជាទស្សនៈផ្ទុយមួយ ។ ពេលនោះបើយើងវាយទៅជួបឧបសគ្គ ពេលនោះត្រូវប្រយុទ្ធរវាងមាគ៌ាពីរហើយ ។ តើក្នុងកាលៈទេសៈនេះ យើងត្រូវឈរលើជំហរណា?

ឥឡូវក៏ដូច្នេះ បន្តបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម បើមិនដាច់ខាត ជួបឧបសគ្គទៅ នាំឲ្យបែកគំនិតហើយ ។

ត្រូវជឿជាក់ដាច់ខាត ជួបឧបសគ្គយ៉ាងម៉េច ត្រូវប្រយុទ្ធ

ដាច់ខាត ។

២.ក្នុងក្របខណ្ឌបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម ត្រូវការពារប្រទេស

**៤) បក្សប្រកាន់យកលទ្ធិម៉ាក្ស-លេនីន ធ្វើជាមូលដ្ឋាននៃទស្សនៈរបស់ខ្លួន**

១.លទ្ធិម៉ាក្ស-លេនីនជាអ្វី? ជាចលនាតស៊ូវណ្ណៈ រវាងវណ្ណៈជិះជាន់ និងវណ្ណៈដែលត្រូវគេជិះជាន់ ។

ឈរលើចលនាតស៊ូវណ្ណៈនេះ ដកពិសោធជាបណ្ដើរៗ ដកពិសោធជានយោបាយ ជាសតិអារម្មណ៍ ជាបច្ចេកទេស ជាយុទ្ធសាស្ត្រ ជាយុទ្ធវិធី ធ្វើម៉េចឲ្យវណ្ណៈត្រូវគេជិះជាន់ឈ្នះវណ្ណៈជិះជាន់ ។ ដូច្នេះ លទ្ធិម៉ាក្ស-លេនីន នៅទីណាក៏មាន ឲ្យតែមានការតស៊ូវណ្ណៈ ។ នៅទូទាំងប្រទេសក៏មាន នៅក្នុងសហករណ៍ក៏មាន ។ ឯកសារម៉ាក្សលេនីន ចេញមកពីចលនាតស៊ូ ។ ឯកសារដែលយើងដកពិសោធជាបន្តបន្ទាប់ពីចលនាយើង ជាឯកសារម៉ាក្ស-លេនីន ។ ដូច្នេះបក្សយើង និយាយរួម គណៈកម្មាធិការបក្សមួយៗ បំពាក់លទ្ធិម៉ាក្ស-លេនីន ជាបន្តបន្ទាប់ ។

ការប្រយុទ្ធតស៊ូវណ្ណៈ បច្ចុប្បន្ននេះ វាមានរូបភាពខុសពីមុន ។ បញ្ហានៅត្រង់យើងរកឃើញ ឬមិនឃើញ ដើម្បីដោះស្រាយទំនាស់តទៅមុខទៀត ។

ការបំផ្លិចបំផ្លាញដំណាំ ការមិនថែទាំ ទុកដាក់ចប កាំបិតពូថៅ ការមិនថែទាំគោក្របី ទុកឲ្យគោក្របីស្គម ជាទិដ្ឋភាពថ្មីនៃទំនាស់វណ្ណៈ នៅក្នុងសហករណ៍ ជាទិដ្ឋភាពនៃទំនាស់ និងរបបសមូហភាពនៃវណ្ណៈអធន ។ បើយើងរកមិនឃើញធាតុពិតនៃទំនាស់នេះ យើងដោះស្រាយទំនាស់មិនបានទេ ។

ឧទាហរណ៍ៈ គោស្គម យើងមិនតស៊ូពង្រីងពង្រឹកគោលជំហរ សតិអារម្មណ៍សមូហភាព គោលជំហរថែរក្សារបស់សហករណ៍ យើងអាចបែរមកវាយរបបសមូហភាពវិញ ថាមកពីរបបសមូហភាពបានជាគោស្គម ។ ដូច្នេះ វាយរបបឯង ។ ការពិត គោស្គមមិនមកពីរបបសមូហភាពទេ ។ គោស្គមនៅក្នុងសហករណ៍ណា គឺមកពីបដិវត្តន៍សង្គមនិយមមិនទាន់ចូលជ្រៅនៅក្នុងសហករណ៍នោះ ។

ស្មារតីសមូហភាព ពុះពារប្រយុទ្ធ លះបង់ ការពាររបបសមូហភាព ក៏ជាឯកសារម៉ាក្ស-លេនីន សម្បូរណាស់នៅក្នុងសហករណ៍ ។ ឯកសារម៉ាក្ស-លេនីន បច្ចុប្បន្នច្រើនជាងគេនៅក្នុងសហករណ៍ ។ ឯកសារបរទេសជាបន្ទាប់ទេ ។

២.លោកទស្សនៈ និងជីវទស្សនៈរបស់បក្ស គឺលោកទស្សនៈ និងជីវទស្សនៈអធន ។

នៅក្នុងអង្គភាពមួយៗ សមមិត្តណាមានកម្មសិទ្ធិតិច មិនស្មុគស្មាញទេ ហើយដឹកនាំបានល្អ គ្រប់គ្រងអង្គភាពបានល្អ ។

កម្មាភិបាលណា បក្ខជនណា មានលោកទស្សនៈជាប់កម្មសិទ្ធិឯកជន សមមិត្តនោះមានការស្មុគស្មាញច្រើន ដឹកនាំមិនបានល្អទេ ។

ដូច្នេះ ត្រូវកសាងបក្សយើង កសាងបុគ្គលយើង តាមលោកទស្សនៈអធន ។ យកពិសោធពីចលនាផ្ទាល់ខ្លួន ពីចលនារួមមកកសាង ។

៣.បក្សកុម្មុយនីស្តកម្ពុជា ប្រឆាំងដាច់ខាតនឹងគំនិតនិយម ពិសោធនិយម គម្ពីរនិយម និងសេរីនិយម ។

គំនិតនិយមក៏មិនរីកចម្រើន ។ ពិសោធនិយម គឺអភិរក្ស ។ គម្ពីរនិយម គឺយកតែពាក្យធំៗរបស់ម៉ាក្ស មកនិយាយ មិនពិនិត្យជាក់ស្ដែង ។ សេរីនិយម គឺមិនតស៊ូវណ្ណៈ ។

ឧទាហរណ៍ៈ ក្នុងសង្គ្រាមបដិវត្តន៍៥ឆ្នាំ យើងធ្វើរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ជារូបភាពចាត់តាំង គឺសក្ដិភូមិ ។ តែបក្សយើងធ្វើរណសិរ្សជាយុទ្ធវិធី តែខ្លឹមសារជាក់ស្ដែង យើងតស៊ូវណ្ណៈនៅក្នុងរណសិរ្ស ពង្រីងពង្រឹកសម្ព័ន្ធភាពកម្មករ-កសិករ គាស់រំលើងវណ្ណៈជិះជាន់ ។ ត្រង់នេះយើងមិនសេរីទេ ។ បើសេរី យើងមិនរៀបចំសម្ព័ន្ធភាពកម្មករ-កសិករ មិនតស៊ូវណ្ណៈទេ ទុកឲ្យវណ្ណៈជិះជាន់ វាពង្រីងពង្រឹកកម្លាំងវា ។ នេះគឺសេរី ។ ហើយយើងមិនគម្ពីរនិយម ។ យើងបញ្ចប់រណសិរ្សរួបរួមជាតិកម្ពុជាដោយស្រួលចំពេលវេលា ។ យើងដោះស្រាយបញ្ហានេះតាមលទ្ធិម៉ាក្ស-លេនីនត្រឹមត្រូវ ។

តើយើងឆ្វេងឬទេ? យើងមិន «ឆ្វេង» យើងមិនស្ដាំ ។ យើងធ្វើត្រឹមត្រូវ ។ បើឈ្នះភ្លាម យើងបញ្ចប់រណសិរ្សភ្លាម យើងឆ្វេង ។ តែយើងបញ្ចប់នេះ គឺត្រឹមត្រូវ មិនឆ្វេង មិនស្ដាំ ។ បើយើងទុកយូរពន្យារពេល គឺស្ដាំ ពីព្រោះបើទុកយូរ នាំឲ្យយើងមិនម្ចាស់ការ ។

ឧទាហរណ៍មួយទៀតៈ គេថា យើងដើរពីរបីជំហាន ។

តើយើង «ឆ្វេង» ឬ«ស្តាំ» ។ យើងពិនិត្យឡើងវិញ យើងឃើញថា យើងដើរលឿនមែន តែតាមមាគ៌ាត្រឹមត្រូវ ។ យើងឈរលើការតស៊ូវណ្ណៈ យើងមិនឈរលើបច្ចេកទេសទេ ។ យើងមិនរត់តាមសម្ភារដូចនាយទុនទេដូចប្រទេសខ្លះទៀតទេ ។ យើងមិនពឹងផ្អែកលើបច្ចេកទេសចក្រពត្តិដូចប្រទេសខ្លះឯទៀតទេ ។

### ៥) បក្សកុម្មុយនីស្តកម្ពុជា ប្រកាន់ខ្ជាប់ និងដាច់ខាតនូវទស្សនមហាជន និងមាគ៌ាមហាជន

១.ទស្សនៈមហាជនៈ ទស្សនៈមហាជន គឺការយល់អំពីមហាជនមានកម្លាំង មានអនុភាពខ្លាំងក្លា ។ យើងត្រូវជឿជាក់យ៉ាងនេះ ។ យើងត្រូវជឿជាក់លើមហាជន មហាជនក្នុងបក្ស មហាជនក្រៅបក្ស មហាជនក្នុងអង្គភាពមួយ ។ មហាជនក្នុងកងទ័ព មហាជនក្នុងកម្មករ-កសិករ ។

តែ ដើម្បីជឿជាក់ ជាកាលលំបាក ។ ជួនណា មានឧបសគ្គអី បាក់ទ័ព ។ បាក់ទ័ព មកពីមិនជឿលើមហាជន លើសមូហភាព ។ មកពីម្នាក់ៗគិតដោយឡែក ។ បើជឿ ប្រជុំគ្នាជាសមូហភាព ។ បើជឿលើមហាជនអីចឹង ដោះស្រាយអីចឹង ដោះស្រាយបាន ។

ឧទាហរណ៍ៈ ពេលយើងធ្វើសង្គ្រាម យើងជួបការលំបាកច្រើនណាស់ តែយើងជឿលើមហាជន យើងដោះស្រាយបាន ។ ដោះស្រាយស្បៀង ដោះស្រាយសម្លៀកបំពាក់ ដោះស្រាយគ្រាប់រំសេវ ។

ក្រោយពេលរំដោះ យើងលំបាកច្រើនដែរ លំបាកស្បៀង តែយើងជឿលើមហាជន ពឹងពាក់លើកម្លាំងមហាជន យើងដោះស្រាយបាន ។

រយៈកាលឥឡូវនេះ ធូរជាងមុន ។ តែបើយើងមានការលំបាក យើងដោះស្រាយជាសមូហភាព ដោយជឿលើមហាជនក្នុងក្របខណ្ឌគណៈភាគ ក្របខណ្ឌគណៈតំបន់ ក្របខណ្ឌតូច ក្របខណ្ឌធំ គឺដោះស្រាយបាន ។ តទៅមុខទៀត ក៏ដូច្នេះ ។

បក្ខជនម្នាក់ៗ កម្មាភិបាលម្នាក់ៗ គណៈកម្មាធិការមួយៗ បក្សទាំងមូល ត្រូវមានគោលជំហរនេះ ។ បើគ្មានគោលជំហរនេះ មានបញ្ហាអី មុខជាច្របូកច្របល់ ។ ច្របូកច្របល់ខាងនយោបាយ ខាងសតិអារម្មណ៍ ខាងទស្សនៈ ខាងចាត់តាំង ខាងវិធានការ ។

២.ត្រូវនៅជាប់នឹងមហាចលនាបដិវត្តន៍ របស់មហាជនកម្មករ-កសិករ ។

ជាប់ចលនាមានន័យថា ត្រូវក្តាប់ចលនានេះឲ្យបាន យល់ចលនានេះ ស្គាល់ដង្ហើមចលនានេះ ។ ជួនកាលចលនាវាលឿន យើងតាមមិនទាន់ ។ ជួនកាលចលនាវាយឺត យើងដាច់ពីចលនា យើងក្តាប់ចលនាមិនបាន មិនយល់ចលនា មិនដឹងមូលហេតុដែលរាំងរាចលនា មិនឃើញគន្លឹះដោះស្រាយ យើងជំរុញចលនាមិនបាន ។ ក្នុងសហករណ៍ក្តី ក៏ត្រូវជាប់ចលនា ។ កុំឃើញតែចំណុចល្អ ។ បើក្តាប់ចលនាមិនបាន វិភាគមិនត្រូវ វិធានការ មិនទាន់ពេលវេលាទេ ។ ក្នុងសហករណ៍ចលនាខ្លាំង ចលនាលើកភ្លឺក៏ខ្លាំង ចលនារកជីក៏ខ្លាំង ចលនាធ្វើស្រែក៏ខ្លាំង ។ នេះជាទិដ្ឋភាពល្អ ។ តែទិដ្ឋភាពមួយទៀត ខ្មាំងវាធ្វើសកម្មភាពបំផ្លាញបដិវត្តន៍ៈ វាបំផ្លាញបង្គី វាបំផ្លាញគោ វាបំផ្លាញចប ។ បើយើងក្តាប់មិនបាន យើងមិនដឹង យើងមិនយល់ ។ ចបវាចេះតែបាក់ យើងថាធ្វើចបមិនល្អ ។ តែខ្មាំងវាបំផ្លាញ យើងក្តាប់មិនបាន យើងគ្មានវិធានការទាន់ពេលវេលា ។ គិតតែពីសុំចបថែម ។ មិនគិតដោះស្រាយទំនាស់វណ្ណៈក្នុងសហករណ៍ មិនគិតតស៊ូវណ្ណៈ ក្នុងសហករណ៍ ។ គោស្លាប់ក៏អីចឹង ។ មិនតស៊ូវណ្ណៈ មិនបំប៉នគោលជំហរនយោបាយ-សតិអារម្មណ៍របស់មហាជន មិនបំប៉នគោ បែរជាមកវាយរបបសង្គមនិយមរបស់ឯង ។ មិនក្តាប់ចលនា មិនវិភាគចលនា ដើម្បីមានវិធានការឲ្យត្រូវ ឲ្យទាន់ពេលវេលា ។

ឧទាហរណ៍ៈ បើក្តាប់ចលនាមិនបាន មុខជាវិភាគបាតុភាពប្រឆាំងខ្លះៗ ថាវាខ្លាំងជាងចលនាឧបត្ថម្ភរបស់មហាជនដូចនេះ ច្បាស់ជាវិភាគថា មាគ៌ារបស់បក្សមិនត្រូវ ច្បាស់ជាមិនជឿមាគ៌ាឯង មិនជឿបក្សឯងវិញ ។

### ៦) បក្សកុម្មុយនីស្តកម្ពុជាចាត់តាំងឡើងតាមគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ

១.ខ្លឹមសារប្រជាធិបតេយ្យប្រមូលផ្តុំគឺៈ សមូហភាពដឹកនាំ បុគ្គលទទួលខុសត្រូវដោយឡែក ។

មានប្រជាធិបតេយ្យប្រមូលផ្តុំ បានបក្សជាអង្គភាពតែមួយ ។ ដូច្នេះបានជាគោលការណ៍នេះ យើងត្រូវយល់ ហើយត្រូវគោរព ។ បើម្នាក់ទីទៃៗ គឺគ្មានបក្សទេ គឺអនាធិបតេយ្យ គឺសេរី ។ បក្ខជនយើង ត្រូវរៀនសូត្រលាក់ការណ៍ ប្រជាធិបតេយ្យប្រមូលផ្តុំ ដើម្បីយល់ ដើម្បីក្តាប់បាន ដើម្បីភ្ញាក់រលឹក ។

២.មានអង្គការវិន័យ រឹងប៉ឹងតែមួយគត់ ។ គ្មានវិន័យសម្រាប់ថ្នាក់លើផ្សេង សម្រាប់បក្ខជនផ្សេងទេ ។ ត្រូវគោរពទាំងអស់គ្នា ។ តែសំខាន់ត្រូវគោរពដោយភ្ញាក់រលឹក ។ ដើម្បីភ្ញាក់រលឹកទាល់តែយល់ ។ ភ្ញាក់រលឹក បានមានស្មារតីប្រយុទ្ធ មិនស្ទាក់ស្ទើរ មិនស្តាយ ។ ស្មោះអស់ពីពោះពីពុង ។ ហ៊ានលះបង់អ្វីៗទាំងអស់ដើម្បីធ្វើបដិវត្តន៍លះបង់កម្មសិទ្ធិសម្ភារ កម្មសិទ្ធិមុខមាត់ បុណ្យស័ក្តិ អាជ្ញា ។

៣.ន័យអនុវត្តប្រជាធិបតេយ្យ-ប្រមូលផ្តុំរបស់បក្ស គឺន័យនយោបាយ សតិអារម្មណ៍ ចាត់តាំង ។ អនុវត្តមាគ៌ារបស់បក្ស គោលការណ៍របស់បក្ស ដោយភ្ញាក់រលឹក ។ សាមគ្គីភាព ឯកភាពផ្ទៃក្នុង វាកើតឡើងដាច់ខាត ដោយអនុវត្តគោលការណ៍ប្រជាធិបតេយ្យ ប្រមូលផ្តុំដោយភ្ញាក់រលឹក ។

៤.ត្រូវប្រុងប្រយ័ត្ន ឲ្យខ្ពស់ដល់កម្រិត ចំពោះគ្រប់សកម្មភាព និងគ្រប់កលល្បិចរបស់ខ្មាំង ។

ប្រុងប្រយ័ត្នក្នុងគណៈកម្មាធិការរបស់បក្ស ប្រុងប្រយ័ត្នក្នុងសាខា ។ ត្រូវចេះពិនិត្យសមាសភាពទីទៃពីបក្ស ដែលវាចូលបង្កប់នៅក្នុងបក្ស ។ ពិតមែនតែបក្ស បានសម្រិតសម្រាំងសមាសភាពអន្តរាយចេញពីបក្ស ជាបន្តបន្ទាប់មកហើយ តែបច្ចុប្បន្ននេះ ក៏នៅមានសមាសភាពមិនល្អ សមាសភាពដែលអន្តរាយ សមាសភាពដែលខ្មាំងបង្កប់នៅក្នុងបក្ស នៅក្នុងកងទ័ព នៅក្នុងជួរបដិវត្តន៍យើង ។ បក្ខជនយើងទាំងអស់ ត្រូវលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នឲ្យដល់កម្រិត ត្រូវចេះពិនិត្យ ត្រូវចេះតាមដាន ត្រូវចេះវិភាគសមាសភាពទាំងនេះ ។ យើងរៀនសូត្រលក្ខន្តិកៈ ដើម្បីម្ចាស់ការជាមុន បំពាក់បំប៉នជាមុន នៅក្នុងបក្សទាំងមូល ។ តាមពិសោធមក យើងក្តាប់ប្រវត្តិរូបបក្ខជនមិនបានណែន នាំឲ្យខ្មាំងជ្រៀតចូលបាន ។ ត្រូវក្តាប់ប្រវត្តិរូបឲ្យណែន ។

សារសំខាន់ខទី៦ នេះ គឺដើម្បីទប់ទល់ខ្មាំង កុំឲ្យវាជ្រៀតចូលបានផង ។

## ៧) ការទិតៀន ស្វ័យទិតៀន

នេះជាបញ្ហាចាស់ ។ ជាលាក់ការណ៍មួយដែលស័ក្តិសិទ្ធិក្នុងការកសាងបក្ស ។ បើមានរបបទិតៀន-ស្វ័យទិតៀនហ្មត់ចត់ ក្នុងគណៈកម្មាធិការក្តី ជាបុគ្គលក្តី ការរីកចម្រើនវាបានរហ័ស ។ បើគ្មានការទិតៀន-ស្វ័យទិតៀន នាំឲ្យធូររលុង ការរីកចម្រើនរបស់គណៈកម្មាធិការក៏ថមថយ របស់បុគ្គលក៏ថមថយ ។

ដូច្នេះហើយ បានជាបក្សបានកំណត់ឲ្យប្រជុំជីវភាពបក្សឲ្យបានទៀងទាត់ ។ បើប្រជុំទៀងទាត់ សាខាមួយៗ កសាងខ្លួនវាជាស្វ័យប្រវត្តិ ។ ផ្ទាល់ខ្លួនយើងម្នាក់ៗក៏ដូច្នេះ បើធូររលុងខាងប្រជុំជីវភាពយូរ គឺមិនចម្រើនទេ ។ បើប្រជុំទៀងទាត់ គឺចម្រើន ចម្រើនលឿន ចម្រើនយឺត គឺចម្រើន ។

## ៨) គោលជំហរឯករាជ្យ ម្ចាស់ការ

ខនេះ ជាខមួយសំខាន់ ។ ជាពិសោធរបស់បក្សយើងឃើញថាៈ បើមិនឯករាជ្យ ម្ចាស់ការ គឺរណបគេ ។ បើឯករាជ្យម្ចាស់ការគឺឈ្នះ ។

ដូច្នេះ យើងត្រូវឯករាជ្យ ម្ចាស់ការ ។ សំខាន់ត្រូវបំពាក់គោលជំហរឯករាជ្យ ម្ចាស់ការឲ្យរឹងមាំ ។ បើមានគោលជំហរឯករាជ្យ ម្ចាស់ការរឹងមាំហើយ ទើបយើងរកវិធីប្រយុទ្ធ រកមាគ៌ាសកម្មភាពឲ្យត្រឹមត្រូវ ដើម្បីប្រយុទ្ធឲ្យឈ្នះ ។

យើងត្រូវផ្សព្វផ្សាយ គោលជំហរឯករាជ្យ ម្ចាស់ការនៅក្នុងបក្ស ក្នុងអង្គការស្នូល ក្នុងបង្គោល ក្នុងមហាជនតទៅទៀត ។ យកពិសោធប្រវត្តិសាស្ត្ររបស់បក្សយើងមកអប់រំ ។ ជំនាន់វាយអាណានិគមនិយមបារាំង យើងមិនឯករាជ្យ ម្ចាស់ការ យើងបាតដៃទទេ ។ ក្រោយមក យើងឯករាជ្យ ម្ចាស់ការ យើងមានការលំបាកក៏ដោយ តែយើងដោះស្រាយបានជាបន្តបន្ទាប់ ។

## ៩) ភារកិច្ចបដិវត្តន៍ជាតិ និងអន្តរជាតិ

១.អត្តនោម័តិរបស់យើង រឹង និងរីកចម្រើន ជាកត្តាកំណត់ ។ សកលលោកចាំពិនិត្យមើលយើង ខំតាមដានចលនាយើង ហើយមានជំនឿមួយផ្នែកថា យើងធ្វើបាន ។ ១ឆ្នាំ ២ឆ្នាំ ៣ឆ្នាំទៀត យើងកាន់តែខ្លាំង យើងសាមគ្គីជាមួយបដិវត្តន៍សកលលោកបានកាន់តែខ្លាំងថែមទៀត ។ គោលការណ៍របស់បក្សយើង គឺត្រូវធ្វើបដិវត្តន៍ក្នុងប្រទេសយើងឲ្យបានល្អ ទើបរួមចំណែកជាមួយបដិវត្តន៍សកលលោកបានល្អ ។

២.យើងសាមគ្គីជាមួយបក្ស ម៉ាក្ស-លេនីន ជាមួយបដិវត្តន៍សកលលោក ដោយឈរលើគោលការណ៍ស្មើភាព ។ បើសាមគ្គីហើយរណបគេ យើងមិនព្រម ។ បើមិនស្មើភាពទេ យើងមិនសាមគ្គី ។ គោលជំហរនេះត្រូវរឹងប៉ឹង ។

**ជំពូកទី១**

**អំពីបក្ខជន**

*សំណួមពរៈ រៀនជំពូកទី ១ នេះគឺៈ*

*១.ដើម្បីក្តាប់ឲ្យជាប់ នូវគោលការណ៍ ស្តីអំពីបក្ខជន ពិសេស អំពីការពង្រីកបក្ខជន និងភារកិច្ចបក្ខជន ។*

*២.ត្រូវជ្រួតជ្រាបឲ្យជ្រៅជ្រះថែមទៀត អំពីវិន័យរបស់ បក្ស ចំពោះគ្រប់បក្ខជន ។*

***១) នៅក្នុងជំពូក១ នេះ មាន៤មាត្រា ។ មាត្រាទី១ ទី២ ទី៣ ជាលាក់ការណ៍ដើម្បីពង្រីកបក្ខជន ពង្រឹងបក្ខជន ។ ត្រូវឈរលើ គោលការណ៍នេះដាច់ខាត ត្រូវបំពាក់បំប៉នលើគោលការណ៍នេះ ដាច់ខាត ។ ត្រូវអប់រំបក្ខជន ឲ្យគេក្តាប់ជាប់គោលការណ៍នេះ ។***

*កន្លងមក ការបញ្ចូលបក្សមួយចំនួនច្រើន គឺត្រឹមត្រូវ ។ តែមួយចំនួនច្រើនគួរសមដែរ គឺបញ្ចូលខុស ពិសេសនៅឆ្នាំ៧០-៧១ ។ ដូច្នេះ សមាសភាពឱកាសនិយម វាចូលបានច្រើន ។ តែបក្សបិទទ្វារ សម្រិតសម្រាំងបានជាអតិបរមា ។*

*ដូច្នេះ តទៅមុខទៀត មុននឹងសម្រេចបញ្ចូលបក្ស ត្រូវបើក លក្ខន្តិកៈមើល ។*

*នៅក្នុងនេះ តាមពិសោធ ត្រូវក្តាប់ប្រវត្តិរូបឲ្យបាន ។ បើ ប្រវត្តិរូបមិនច្បាស់ ទោះជាល្អក៏ដោយ ក៏កុំអាលបញ្ចូល ។ ប្រយ័ត្ន ពួក សេ.អ៊ី.អា វាជ្រៀតចូល ។ សេ.អ៊ី.អា វាវាយបដិវត្តន៍ ដោយ បញ្ចូលថ្នាំតាមសរសៃឈាមរបស់បដិវត្តន៍ ។ ដូច្នេះត្រូវក្តាប់ប្រវត្តិ រូបឲ្យច្បាស់ ។*

***២) អំពីវិន័យរបស់បក្សៈ មាត្រា៤***

***ចំពោះវិន័យរបស់បក្ស ចង់សង្កត់លើចំណុចខ្លះ***

*ក) ត្រូវមានទស្សនៈច្បាស់លាស់ ចំពោះវិន័យរបស់បក្ស ។ ក្តាប់វិន័យ យល់សារសំខាន់របស់វិន័យ ការចាំបាច់របស់វិន័យ ។ វិន័យរបស់បក្ស ធ្វើឡើងដើម្បីសាមគ្គីភាព-ឯកភាពផ្ទៃក្នុងបក្ស ។ ទស្សនៈចំពោះវិន័យនេះ កន្លងមកនៅស្រាល ។*

*ហេតុអីបានជាមានវិន័យ? សារសំខាន់នៃវិន័យយ៉ាង ណា?*

*ទាល់តែមានវិន័យ បានសាមគ្គីភាព ឯកភាពផ្ទៃក្នុងបក្ស រឹង ។ វិន័យមិនមែនឈរលើបុគ្គលនេះ បុគ្គលនោះ គណៈកម្មាធិការ នេះ គណៈកម្មាធិការនោះទេ គឺឈរលើមាគ៌ា ។*

*យើងចង់បំផុសមហាជន ឲ្យកាន់តែយល់មាគ៌ា យល់សតិ អារម្មណ៍ យល់លាក់ការណ៍ចាត់តាំងរបស់បក្ស ដើម្បីមហាជនមាន កម្លាំង ជួយកសាងបក្ស ពង្រឹងពង្រីកបក្ស ។ ឲ្យគេយល់វិន័យរបស់ បក្ស ។ យល់សម្រាប់ខ្លួនគេ យល់សម្រាប់វិន័យបក្ខជន វិនិច្ឆ័យ កម្មាភិបាល ។ អនុវត្តសតិអារម្មណ៍ខុស គេមើលឃើញ ។ អនុវត្ត ចាត់តាំងខុស គេមើលឃើញ ពីព្រោះមាគ៌ាតែមួយ ។ ដូច្នេះ នាំឲ្យ បក្សយើងរឹង ។ ពីព្រោះកន្លងមក មានធ្ងន់ មានស្រាល ។ បើថ្នាក់ លើធ្វើខុសវិន័យ ជួនកាលមហាជនឃើញដែរ តែមិនហ៊ាននិយាយ ។ ជួនកាល មហាជនមិនឃើញ មកពីមិនយល់អំពីវិន័យរបស់បក្ស ។ ត្រូវអប់រំជាបន្តបន្ទាប់ ។*

*ខ) ត្រូវមានការអនុវត្តវិន័យ ដោយហ្មត់ចត់ ដើម្បីឲ្យបក្ស ខ្លាំង សាមគ្គីភាព ឯកភាពរឹងប៉ឹង ។ គោលការណ៍របស់បក្ស គឺទិតៀន ស្វ័យទិតៀនដើម្បីកសាង ។ នេះជាមូលដ្ឋាន ។ ប៉ុន្តែ បើ កសាងជាបន្តបន្ទាប់ហើយ មិនកែប្រែ មិនចម្រើន ត្រូវតែអនុវត្តវិន័យ បានមហាជនមានជំនឿ ហើយបក្សរឹងបាន យើងលំអគោលការណ៍ របស់បក្ស លំអមាគ៌ារបស់បក្សបាន ។*

*ប៉ុន្តែ ត្រូវប្រយ័ត្នប្រយែង "ឆ្វេង ស្តាំ" ។ មកដល់ថ្ងៃនេះ យើងច្រើនធូររលុងក្នុងការអនុវត្តវិន័យ ។ ក្នុងន័យនេះ យើង ស្តាំ ។ តែប្រយ័ត្នឆ្វេង គឺអនុវត្តវិន័យ ទទឹងទទែង មិនពិនិត្យពិច័យ ហ្មត់ចត់ ។*

*ទន្ទឹមនេះ ក្នុងការអនុវត្តវិន័យ ត្រូវមានវិធានការហ្មត់ចត់ ។ មុននឹងសម្រេចវិន័យមួយៗ ត្រូវតស៊ូមួយរយៈកាល កសាងមួយ រយៈកាល ។ បើសម្រេចវិន័យ ត្រូវមានវិធានការហ្មត់ចត់ការពារ ប្រតិកម្មប្រឆាំង ។*

*អនុវត្តវិន័យរបស់បក្សហ្មត់ចត់ មិនមែនធ្វើឲ្យបក្សខ្សោយ ទេ ។ គឺធ្វើឲ្យបក្សខ្លាំង ។ បើអនុវត្តវិន័យរបស់បក្សបានត្រឹមត្រូវ បំផុសមហាជនក៏បានលឿនទៀត ។*

**ជំពូកទី២**

*អំពីលក្ខណៈសម្បត្តិ១០យ៉ាង ដើម្បីជ្រើសរើសចូលក្នុង អង្គការដឹកនាំផ្សេងៗរបស់បក្ស ។*

*សំណួមពរៈ រៀនជំពូកទី២ គឺដើម្បីៈ*

១) ដើម្បីបំពាក់ទស្សនវិនិច្ឆ័យ ១០យ៉ាងរបស់បក្សឲ្យជ្រួតជ្រាប ដើម្បីវិនិច្ឆ័យខ្លួនឯង កសាងខ្លួនឯង តាមលក្ខណៈ១០យ៉ាងរបស់បក្ស ។

២) ដើម្បីវិនិច្ឆ័យសមមិត្តដទៃ ហើយនឹងកសាងសមមិត្តដទៃ ជ្រើសរើសសមមិត្តដទៃ តាមលក្ខណៈ១០យ៉ាងនេះ ។

កន្លងមក បក្សបានលើកលក្ខណៈ១០យ៉ាងនេះ ។ តែការជ្រួតជ្រាបនៅខ្វះខាត ។ ដូច្នេះ វិនិច្ឆ័យខ្លួនឯង មិនត្រឹមត្រូវ ។ ដូច្នេះ ស៊ូយកសាងខ្លួនមិនបាន ។ មិនដឹងជាមានអី ខ្វះអី កសាងអី ។

ម៉្យាងទៀតវិនិច្ឆ័យអ្នកដទៃ ជ្រើសរើសអ្នកដទៃ កសាងអ្នកដទៃ មិនទាន់បានត្រឹមត្រូវ ។ ដូនណាឃើញតែសមត្ថភាពនយោបាយ សមត្ថភាពបច្ចេកទេស តែមិនពិនិត្យជំហរនយោបាយ សតិអារម្មណ៍ ជំហរសាមគ្គី ។ ដូនណា វិនិច្ឆ័យតាមសភាពស្លូតបូត មិនពិនិត្យធាតុសកម្មប្រយុទ្ធរបស់បក្ស ។

ដូច្នេះ ត្រូវសិក្សារៀនសូត្រលក្ខណៈសម្បត្តិ១០យ៉ាង ។ ហើយក្នុង១០ខនេះ មាន៤ខសំខាន់ ។

**ខទី១ គឺគោលជំហរឯកភាព មាគ៌ាបក្សៈ**

ដូនណា សមមិត្តយើងមិនទាន់យល់អីទេ តែជឿជាក់លើមាគ៌ារបស់បក្ស ហើយអនុវត្តមាគ៌ារបស់បក្ស ។ អនុវត្តខុសអនុវត្តត្រូវ កែលម្អតាមមាគ៌ារបស់បក្ស ។

ប្រយ័ត្នបំផុត អនុវត្តមាគ៌ា ស្ដាំជាខ្សែសង្វាក់ ឬ "ឆ្វេង" ជាខ្សែសង្វាក់ ឬជុតឲ្យខ្លោច រោចឲ្យឆៅជាខ្សែសង្វាក់ ។

បញ្ហានេះ មានពីរប្រភេទ ។ ដូនណា "ឆ្វេង" ជាខ្សែសង្វាក់ ឬស្ដាំជាខ្សែសង្វាក់ដោយអចេតនា ។ នេះក៏គ្រោះថ្នាក់ ។ ប្រយ័ត្នបំផុត ខ្មាំងដែលវាបង្វែរមាគ៌ារបស់បក្សដោយចេតនា ។ នេះរឹតតែគ្រោះថ្នាក់ ។

**ខទី២ គោលជំហរសតិអារម្មណ៍អធនរបស់បក្សៈ**

បក្ខជន កម្មាភិបាល ដែលមានសតិអារម្មណ៍ត្រឹមត្រូវឯកភាពជាមួយបក្ស បានធានាអះអាង ជាបក្ខជនល្អ ជាកម្មាភិបាលល្អ ។ ដូនណា សតិអារម្មណ៍ភាន់ច្រឡំ មានការខុសឆ្គងដោយភាន់ច្រឡំដល់អប់រំទៅ កែប្រែតាមសតិអារម្មណ៍របស់បក្ស ។ នេះទុកជាល្អ ។ តែបើអប់រំ កសាងជាបន្តបន្ទាប់ហើយ នៅតែខុសជាខ្សែសង្វាក់ បក្ខជននេះ កម្មាភិបាលនេះ មិនល្អទេ នាំឲ្យគ្រោះថ្នាក់ ។

**ខទី៣ គោលជំហរសាមគ្គីភាព ឯកភាពផ្ទៃក្នុងបក្សៈ**

គោលជំហរសាមគ្គីភាព ឯកភាព មិនមែនកសាងបានភ្លាមៗទេ ។ ទាល់តែជ្រួតជ្រាប និងអនុវត្តមាគ៌ានយោបាយ សតិអារម្មណ៍ ចាត់តាំងរបស់បក្សបានត្រឹមត្រូវ ទើបប្រមូលកម្លាំងសាមគ្គីបានធំទូលាយ ។ ដូនណា បំណងល្អ ចង់សាមគ្គីភាព ឯកភាព តែធ្វើទៅទៅជាបែកបាក់សាមគ្គីទៅវិញ ដោយមិនយល់គោលការណ៍របស់បក្ស ។ ប៉ុន្តែដកពិសោធបណ្ដើរៗ សាមគ្គីបានប្រមូលកម្លាំងបាន ។

តាមពិសោធរបស់បក្ស ទោះជាមានសមត្ថភាពតិច តែបើសាមគ្គីបានល្អ មុខជាដឹកនាំបានល្អ ។ បើសមត្ថភាពច្រើន តែសាមគ្គីមិនបានល្អ ដឹកនាំក៏មិនបានល្អដែរ ។

**ខទី៤ គឺគោលជំហរមាគ៌ាចាត់តាំង ដឹកនាំ និងធ្វើការងាររបស់បក្សៈ**

៤ខនេះជាខសំខាន់ ។ ៦"ខ" ដទៃទៀត ជា "ខ" រួមផ្សំ ។ ដើម្បីជ្រួតជ្រាបលក្ខណៈវិនិច្ឆ័យ ១០"ខ" របស់បក្ស មានតែរៀនសូត្រ ហើយពាក់ព័ន្ធ ។ រៀនសូត្រដោយខ្លួនឯង តស៊ូដោយខ្លួនឯង ហើយសមូហភាពជួយកសាងទៀត ។

បញ្ហានេះ មានសារសំខាន់ក្នុងការកសាងខ្លួនយើងម្នាក់ៗ និងកសាងសមមិត្តដទៃ និងកសាងបក្ស ។ ទប់ទល់សើរើ ។ យើងបំពាក់បំប៉នលក្ខណៈសម្បត្តិ១០ខ ដើម្បីពង្រឹងបក្សយើង ។

លាក់ការណ៍ និងគោលជំហរនយោបាយ ជាមូលដ្ឋានរបស់បក្ស ជំពូកទី១ ជំពូកទី២ ទាំងបីផ្នែកនេះ ជាគោលជំហរជាមូលដ្ឋានរបស់បក្ស ។ ត្រូវរៀនសូត្រ សាចុះសាឡើង ។ ជំពូកឯទៀតជាន័យអនុវត្ត ។

**ជំពូកទី៣**

**អំពីលាក់ការណ៍ចាត់តាំងរបស់បក្ស**

គោលការណ៍ប្រជាធិបតេយ្យប្រមូលផ្ដុំ ។ យើងបានពិនិត្យហើយ ។ ទាល់តែឈរលើលាក់ការណ៍នេះ ទើបឯកភាពគ្នា ។ ឧបមា បុគ្គលត្រូវគោរពសមូហភាព ។ តែបើបុគ្គលមិនគោរពសមូហភាព វាអស់ជាបក្សហើយ ។

**ជំពូកទី៤**

**អំពីខ្សែចាត់តាំងរបស់បក្ស**

ខ្លឹមសារមាត្រាទី៧ គឺដូចតទៅៈ

ក្នុងថ្នាក់នីមួយៗ អង្គការខ្ពស់បំផុត គឺសន្និបាតអង្គការថ្នាក់នោះ ។

ឧទាហរណ៍ៈ មហាសន្និបាតបក្សទូទាំងប្រទេស គឺជាអង្គការខ្ពស់បំផុតរបស់បក្សទូទាំងប្រទេស ។ សន្និបាតភូមិភាគ ជាអង្គការខ្ពស់បំផុត របស់ទូទាំងភូមិភាគ ។

ឧទាហរណ៍ៈ បើមានការខ្វែងគ្នាខាងមាគ៌ា ត្រូវអង្គការខ្ពស់បំផុតសម្រេច គឺមហាសន្និបាតទូទាំងប្រទេសសម្រេច ។ មិនមែនបុគ្គលណា កែប្រែមាគ៌ាតាមផ្លូវបានទេ ។ នៅតាមថ្នាក់ផ្សេងៗ ក៏ដូចគ្នា ។

យើងត្រូវកសាងនិស្ស័យ ការចាត់តាំងយ៉ាងនេះ ។ បើយើងគោរពការចាត់តាំងយ៉ាងនេះ មិនខុសទេ ។ បើខុស ក៏យើងអាចកែប្រែបាន ។

មាត្រា៨ អាចចាត់តាំងផ្នែកដោយឡែក ដោយគណៈកម្មាធិការមជ្ឈិមបក្ស ទទួលភារៈដឹកនាំដោយផ្ទាល់ ឬដោយប្រយោល ។ ឧទាហរណ៍ៈ ផ្នែកយោធាទូទាំងប្រទេស ។ ផ្នែករដ្ឋាភិបាលទូទាំងប្រទេស ផ្នែកវប្បធម៌ទូទាំងប្រទេស ផ្នែកសង្គមកិច្ចទូទាំងប្រទេស កៅស៊ូ កំពង់ផែ ។

**អំពីសាខា**

មាត្រា៩ អង្គភាពដែលមានចាត់តាំងសាខា មានសហករណ៍ រោងចក្រ អង្គភាពអនុសេនាធំយោធា ការដ្ឋានក្រសួង មន្ទីរបដិវត្តន៍ ។

បក្សបានកំណត់ថា ឆ្នាំ៧៦ ត្រូវមានសាខាសហករណ៍តាមមូលដ្ឋាននីមួយៗ បាន៤០ភាគរយ ទៅ៥០ភាគរយ ។ ត្រូវគិតគូរកសាងសាខា តាមមូលដ្ឋានឲ្យបានរហ័ស ។ បើមានសាខាសហករណ៍៥០ភាគរយ គឺយើងខ្លាំង ។ យើងមានលទ្ធភាពពេញទី ។ ពីព្រោះសហករណ៍ឥឡូវ កន្លែងជាច្រើនជាសហករណ៍ភូមិ ។ បើសហករណ៍ភូមិហើយ លទ្ធភាពកសាងសាខាបក្ស ក្នុងសហករណ៍នេះមានពេញទី ពីព្រោះពីមុន ក្នុងសហករណ៍១៥ គ្រួសារ ២០ គ្រួសារ មានមហាជន១០នាក់ ១៥នាក់ល្អ ។ ឥឡូវ សហករណ៍ភូមិ១០០គ្រួសារ ២០០គ្រួសារ មហាជនល្អយ៉ាងតិច ២០ ឬ ៣០នាក់ឡើងទៅ ។

**មាត្រា១០ ភារកិច្ចសាខា**

◆ ភារកិច្ចក្នុងមហាជនៈ ត្រូវអប់រំមហាជនអំពីធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម តាមន័យជាក់ស្តែង ។ បដិវត្តន៍សង្គមនិយម គឺសមូហភាព ។

កសាងសង្គមនិយម គឺ៣គោាន ១ហិកតា ឃ្វាលគោឲ្យល្អ ថែទាំគោឲ្យល្អ រកស្មៅឲ្យគោស៊ី បំពាក់ក្អក់មូសឲ្យគោ ។ ថែទាំភ្លឺ ថែទាំទឹក ។ ថែទាំដំណាំដាំដុះរបស់សហករណ៍ ។ ធ្វើជី ។ បើយើងអប់រំមហាជនយ៉ាងនេះ គឺមហាជនគេយល់ គេធ្វើបាន ។ ដូច្នេះកសាងបក្សក្នុងសហករណ៍បានរហ័ស តាមការជាក់ស្តែង ។

បញ្ហាដែលលំបាក គឺបញ្ហាប្រវត្តិរូប ។ ដើម្បីក្តាប់ប្រវត្តិរូប ត្រូវផ្អែកលើមហាជនក្នុងសហករណ៍ ។ កន្លែងខ្លះចោទថា ប្រវត្តិរូបមិនស្អាត ដោយមហាជនទាំងអស់ យ៉ាងហោចក៏ធ្វើជីវពល ។ បញ្ហានេះមិនសំខាន់ទេ ។ សំខាន់ប្រវត្តិរូបដែលមហាជនគេក្តាប់ ។ ផ្អែកលើមហាជនក្នុងសហករណ៍ ។ បើឲ្យគេពិនិត្យ គេដឹងច្បាស់អ្នកណាល្អ អ្នកណាមិនល្អ ។

**អំពីគណៈកម្មាធិការស្រុក**

មាត្រា១២ មាត្រា១៣ និងមាត្រា១៤ ត្រូវអប់រំមហាជនឲ្យយល់ភារកិច្ច គណៈកម្មាធិការស្រុក ។ តែសំខាន់ បំពាក់គណៈកម្មាធិការស្រុកឲ្យក្តាប់ភារកិច្ចរបស់ខ្លួន ។ បើកាលណាស្រុកក្តាប់ភារកិច្ចរបស់ខ្លួនបាន ស្រុកម្ចាស់ការចាត់ចែង ។ដូច្នេះកម្លាំងនេះ មិនកប់ទេ ។ ទន្ទឹមនេះ យើងអប់រំទូទាំងបក្សឲ្យយល់ភារកិច្ចគណៈកម្មាធិការស្រុក ដើម្បីជាកម្លាំងតាមដាន និងជំរុញ ។

**អំពីគណៈកម្មាធិការតំបន់ ក្រុង**

គណៈតំបន់ ត្រូវជ្រួតជ្រាបភារកិច្ចរបស់គណៈតំបន់ ក្នុងន័យអនុវត្តនៅក្នុងតំបន់ ។ ធ្វើបដិវត្តន៍សង្គមនិយមយ៉ាងម៉េច កសាងសង្គមនិយមយ៉ាងម៉េច៖

បដិវត្តន៍សង្គមនិយមនៅក្នុងតំបន់ គឺសមូហភាព ធ្វើការសមូហភាព រស់នៅសមូហភាព ។ សមូហភាពក្នុងសហករណ៍ ក្នុងកងទ័ព នៅក្នុងគណៈតំបន់ ។ កម្ចាត់ទស្សនៈផ្អែកនិយម តំបន់និយម អង្គភាពនិយម ។

កសាងសង្គមនិយម គឺ៣តោន ១ហិកតា គឺជី ប្រឡាយ ភ្លឺ ភ្លូរឲ្យស្អាត សួនឲ្យស្អាត រើសពូជឲ្យល្អ ។ យើងបំបែកន័យជាក់ស្តែងយ៉ាងនេះឲ្យមហាជនងាយយល់ ។ ឥឡូវគេធ្វើហើយ តែយើងបំបែកឲ្យគេយល់ ។ បើគេយល់ គេកាន់តែភ្ញាក់រឭក គេកាន់តែ

ស្ទុះស្ទាញ ។

### អំពីគណៈកម្មាធិការភូមិភាគ

ក្នុងបក្សត្រូវរៀនសូត្រភារកិច្ចគណៈភូមិភាគ ។ ជាពិសេស គណៈភូមិភាគត្រូវរៀនសូត្រ ដើម្បីបង្កើនគុណភាពដឹកនាំថែមទៀត ។ ជាក់ស្ដែង សន្និបាតភូមិភាគ កំណត់ផែនការការងាររបស់គណៈភូមិភាគហើយ ។

សរុបមកវិញ គឺបំពាក់ភារកិច្ចថ្នាក់នីមួយៗ តាមការជាក់ស្ដែង ។ បដិវត្តន៍សង្គមនិយម គឺសមូហភាព ។

កសាងសង្គមនិយម គឺពគោន ១ហិកតា ប្រព័ន្ធភ្លឺ ប្រឡាយ ជី ថែទាំគោ ក្របី ។

**ជំពូកទី៥**

### អំពីអង្គការស្នូលរបស់បក្ស

សំណូមពរៈ រៀនជំពូកទី៥

ដើម្បីក្ដាប់ និងឃើញឲ្យច្បាស់នូវសារសំខាន់នៃអង្គការស្នូលរបស់បក្ស ។ វាជាថ្នាលរបស់បក្ស ។ វាមានសារសំខាន់ក្នុងការពង្រឹងពង្រីកបក្ស ពិសេស ក្នុងការពង្រីកបក្ស ។ វាមានសារសំខាន់ក្នុងការបន្តវេនកសាងជួររបស់បក្ស ។ដូច្នេះ កុំមើលស្រាល ។ យកចិត្តទុកដាក់ ពង្រឹងពង្រីកអង្គការស្នូលជាអតិបរមា ។ បើបណ្ដែតបណ្ដោយ ជួនណាខូចច្រើនណាស់ ។ នៅក្នុងកងទ័ពក៏ដូច្នេះ នៅក្នុងមូលដ្ឋានក៏ដូច្នេះ ។ ជួនណា មុនពេលចូលអង្គការស្នូល គេល្អ ។ តែក្រោយមក ដោយយើងមិនបានអប់រំ កសាងឲ្យជាប់ គេវិវត្តទៅមិនល្អវិញ ។ ដូច្នេះ ត្រូវយកចិត្តទុកដាក់កសាងអង្គការស្នូល កុំបណ្ដែតបណ្ដោយ កុំចាំដល់គេខុស បានយើងបន្ទោស ។

**ជំពូកទី៦**

### អំពីកងទ័ពបដិវត្តន៍កម្ពុជា

◆ ត្រូវឃើញអំពីកងទ័ពបដិវត្តន៍កម្ពុជា ជាអង្គការផ្ដាច់ការរបស់បក្ស ស្ថិតនៅក្រោមការដឹកនាំផ្ដាច់មុខគ្រប់ផ្នែក និងដាច់ខាតរបស់បក្ស ។ដូច្នេះ កងទ័ពរបស់បក្សត្រូវបរិសុទ្ធ ដើម្បីការពារលទ្ធផលបដិវត្តន៍ ការពារប្រទេស កសាងសង្គមនិយម ។

ផ្ដាច់មុខ គឺមានតែបក្សដឹកនាំកងទ័ព គ្មានអង្គការណាផ្សេងទៀត ឬបុគ្គលណាទៀតដឹកនាំទេ ។

ដាច់ខាត គឺដាច់ខាតលើមាគ៌ានយោបាយ សតិអារម្មណ៍ ចាត់តាំងរបស់បក្ស ។

គ្រប់ផ្នែក គឺតាំងពីនយោបាយ សតិអារម្មណ៍ ចាត់តាំង យោធា បច្ចេកទេស ។

ជាប្រពៃណី កងទ័ពយើងល្អ ។ កងទ័ពយើងចេញពីចលនាបដិវត្តន៍មហាជនខ្លាំងក្លា ។ ដូច្នេះ កងទ័ពនេះខ្លាំងក្លា ។

**ជំពូកទី៧**

### អំពីហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់បក្ស

មាគ៌ារបស់បក្សយើង ក្នុងការកសាងសេដ្ឋកិច្ច ហិរញ្ញវត្ថុ គឺខ្លួនទីពឹងខ្លួន ។ ដូច្នេះ សេដ្ឋកិច្ចរបស់បក្សយើង គឺចេញមកពីផលិតកម្ម ជាក់ស្ដែង គឺចេញមកពីកសិកម្មជាមូលដ្ឋាន ។ ដូច្នេះ យើងខំធ្វើតទៅទៀត ដើម្បីធ្វើជាទុន ។ ជាទុនសម្រាប់ស្បៀង ជាទុនសម្រាប់ការពារប្រទេស ជាទុនសម្រាប់កសាងប្រទេសឲ្យបានឆាប់រហ័ស ។

**ជំពូកទី ៨**

### អំពី ការអនុវត្ត និងកែប្រែលក្ខន្តិកៈរបស់បក្ស

១) ត្រូវអនុវត្តលក្ខន្តិកៈរបស់បក្ស ក្នុងស្មារតី និងគោលជំហរបម្រើបក្ស និងបដិវត្តន៍ ។ បដិវត្តន៍អ្វី? គឺបដិវត្តន៍សង្គមនិយម ។ បើទាញឲ្យថយត្រឹមបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ គឺប្រឆាំងនឹងមាគ៌ារបស់បក្ស ។

២) មានតែមហាសន្និបាត តំណាងបក្សកុម្មុយនីស្តកម្ពុជាទូទាំងប្រទេស ទើបកែប្រែលក្ខន្តិកៈរបស់បក្សបាន ។

បក្ខជនយើង កម្មាភិបាលយើង បក្សយើងទាំងមូល ត្រូវយកចិត្តទុកដាក់រៀនសូត្រលក្ខន្តិកៈរបស់បក្ស ដើម្បីដឹកនាំបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមបានរហ័ស និងបានល្អ ។

យើងត្រូវរៀនសូត្រហើយរៀនសូត្រទៀត រៀនជាសមូហភាព រៀនជាបុគ្គល ។

បើដំណើរការយ៉ាងនេះ យើងក្ដាប់លក្ខន្តិកៈបានណែន ។ មិនមែនក្ដាប់ជាមាត្រាទេ ។ គឺក្ដាប់ក្នុងន័យអនុវត្ត ។ គឺក្ដាប់ជាគោលជំហរ ។

ត្រូវក្ដាប់លក្ខន្តិកៈទាំងមូល តែសំខាន់ គឺក្ដាប់គោលជំហរជាមូលដ្ឋាន និងជំពូកទី១ ទី២ ។

វិធីរៀន មិនមែនរៀនមួយដង គ្រប់មាត្រាទេ ។ ត្រូវចេះឆ្លៀតរៀន មួយដងមួយជំពូក មួយដងមួយជំពូក ។ **ឆេង ឆេង**

# ការិយាល័យព័ត៌មានសាធារណៈ

*"ការិយាល័យព័ត៌មានសាធារណៈ" របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។*

*មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។*

*តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ធនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។*

*ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អ៊ុន សុដាវី តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthsodavy.u@dccam.org ។*





















# កាលវិភាគបញ្ចាំងខ្សែភាពយន្ត ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា
















*រៀងរាល់ថ្ងៃសុក្រ វេលាម៉ោង ១០ : ០០ ព្រឹក*

*ទីតាំង : អគារ H នៃវិទ្យាស្ថានជាតិអប់រំ (មហាវិថីព្រះសីហនុ ភ្នំពេញ)*

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង : ម៉ែន ពិចិត្រ ទូរសព្ទលេខ : ០២៣ ២១៨ ០០៩ អ៊ីម៉ែល : truthmpechet@dccam.org*

# ភាពយន្តឯកសារ«កុំស្មានបងភ្លេច» នឹងបញ្ចាំងជូនប្រជាជននៅតាមភូមិនានា នៅទូទាំងប្រទេសកម្ពុជា ទស្សនា ក្នុងឆ្នាំ២០១៧

ខ្សែភាពយន្តឯកសាររឿង “កុំស្មានបងភ្លេច” ដែលនិយាយអំពីខ្មែរបាត់បង់តន្ត្រី រ៉ក់ អេនរ៉ូល នៅក្នុងអំឡុងពេលកើតមានសង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជា បានគ្រោងធ្វើការចាក់បញ្ចាំងជូនប្រជាជនទស្សនានៅតាមវត្តអារាម ទីប្រជុំជន និងភូមិនានា នៅទូទាំងប្រទេស នៅបំណាច់ឆ្នាំ ២០១៦ និងនៅដើមឆ្នាំ ២០១៧ នេះ ។

បន្ទាប់ពីចំណាយពេលជិត១០ឆ្នាំ ក្នុងការស្រាវជ្រាវ និងថតខ្សែភាពយន្តឯកសារ “កុំស្មានបងភ្លេច” ផលិតដោយលោក ចន ពីរ៉ូហ្ស៊ី ដែលមានរយៈពេល ១ម៉ោង៥០នាទី ត្រូវបានរៀបចំបើកសម្ពោធបញ្ចាំងដំបូង នៅសាលសន្និសីទចតុមុខ នៅខែមករា ឆ្នាំ២០១៤ ដោយមានការចូលរួមពីប្រជាជន សិស្សនិស្សិត មន្ត្រីរាជរដ្ឋាភិបាល ព្រះសង្ឃ សិល្បៈករ (រួមទាំងអ្នករស់រានជីវិតពីរបបខ្មែរក្រហម) និងភ្ញៀវបរទេសជាច្រើននាក់ ។ ភាពយន្តឯកសារនេះ ក៏ត្រូវបានដាក់ប្រកួតប្រជែងនៅក្នុងពិធីប្រកួតខ្សែភាពយន្តលំដាប់ពិភពលោកនៅរោងភាពយន្តសាន់ឌែនប្រទេសអាមេរិក ដោយទទួលបានការចាប់អារម្មណ៍ និងគាំទ្រយ៉ាងខ្លាំងពីសំណាក់ទស្សនិកជនជាពិសេស ប្រជាជនកម្ពុជា ។

ចន ពីរ៉ូហ្ស៊ី ផលិតករខ្សែភាពយន្តឯកសារ “កុំស្មានបងភ្លេច” បានមានប្រសាសន៍ថា ៖ “នៅក្នុងអំឡុងទសវត្សរ៍៦០ និងដើមទសវត្សរ៍៧០ នៅពេលដែលសង្គ្រាមក្នុងប្រទេសវៀតណាម




ក្រុមការងារបញ្ចាំងខ្សែភាពយន្តឯកសាររឿង “កុំស្មានបងភ្លេច” ៖ ខ្មែរបាត់បង់តន្ត្រីរ៉ក អេន រ៉ូល បានចែកលិខិតអញ្ជើញ និងខិតបណ្ណផ្សព្វផ្សាយដល់ក្មេងៗ និងប្រជាជនក្នុងក្រុងបានលុង ខេត្តរតនគិរី ដើម្បីចូលរួមទស្សនាខ្សែភាពយន្តដែលបានចាក់បញ្ចាំងនៅមន្ទីរវប្បធម៌ខេត្ត

បានគាំរាមកំហែងនៅតាមបណ្តោយព្រំដែន តន្ត្រីបែបថ្មីនេះ បានលេចជារូបរាងនៅក្នុងប្រទេសកម្ពុជាដែលចម្លងចេញពីតន្ត្រី រ៉ក់ អេន រ៉ូល មកពីបស្ចិមប្រទេស ដោយមានឫសគល់នៃទម្រង់ដើមរបស់ខ្លួនបង្កើតបានជាតន្ត្រីមួយបែបថ្មីខុសពីតន្ត្រីដទៃ ។

តន្ត្រីករខ្មែរបានបង្កើតតន្ត្រីមួយបែបនេះ ចេញពីក្បួនខ្នាតដ៏សំខាន់នៃតន្ត្រីរ៉ក់ផ្សេងៗរបស់ អាមេរិក អង់គ្លេស និងបារាំង ដោយដាក់បញ្ចូលសំឡេង និងចង្វាក់តន្ត្រីប្រពៃណីខ្មែរតែមួយគត់របស់ខ្លួន ។ សំឡេងដ៏ពិរោះក្រអូនក្រអៅរបស់អ្នកចម្រៀង ស្ត្រីដែលល្បីឈ្មោះបានក្លាយជាចំណុចទាក់ទាញ ហើយធ្វើឲ្យតន្ត្រីច្នៃប្រឌិតមួយនេះទទួលបានការពេញនិយមយ៉ាងខ្លាំងពីសំណាក់សាធារណជន ។

ប៉ុន្តែនៅពេលដែលសង្គមខ្មែរ ជាពិសេសតន្ត្រីករវ័យក្មេងទទួលយកវប្បធម៌បស្ចិមប្រទេស ហើយបានអភិវឌ្ឍន៍ខ្លួនក្រោមឥទ្ធិពលនៃវប្បធម៌នេះ ប្រទេសកម្ពុជាគឺបានធ្លាក់ក្នុងភ្លក់ភ្លើងសង្គ្រាមយ៉ាងឆាប់រហ័ស ។ ខាងនិន្នាការនេ្សងនិយមសម្តេចព្រះ នរោត្តម សីហនុ បានចូលរួមជាមួយនឹងខ្មែរក្រហម ហើយបានបង្រួបបង្រួមប្រជាជនតាមជនបទឲ្យប្រយុទ្ធប្រឆាំងនឹងរដ្ឋាភិបាលដែលបានបណ្តេញព្រះអង្គចេញពីតំណែង ។ ចំណែកនិន្នាការស្តាំឯណោះវិញ កងកម្លាំងយោធាកម្ពុជាបានបង្កសង្គ្រាម ដែលមានយុទ្ធនាការទម្លាក់គ្រាប់បែកក្នុងទ្រង់ទ្រាយធំនៅតាមទីជនបទ ។ ទីបញ្ចប់ បន្ទាប់ពីបានទទួលជ័យជម្នះលើសង្គ្រាម ខ្មែរក្រហមបានកំណត់ទិសដៅកម្ទេចវប្បធម៌ខ្មែរ ។

បន្ទាប់ពីខ្មែរក្រហមគ្រួតត្រាប្រទេសនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមចាប់ផ្តើមលុបបំបាត់ចោលអត្តសញ្ញាណនៃឥទ្ធិពលរបស់បស្ចិមប្រទេស និងភាពទាន់សម័យទាំងអស់ ។ បញ្ញវន្ត សិល្បករ តន្ត្រីករ ត្រូវបានដៅជាមុខសញ្ញាដាក់លាក់ និងត្រូវកម្ចាត់ចោលជាប្រព័ន្ធ ។ ដូច្នេះហើយ អំពើប្រល័យពូជសាសន៍មួយក្នុងចំណោមអំពើឃោរឃៅបំផុតក្នុងប្រវត្តិសាស្ត្រមនុស្សជាតិក៏បានចាប់ផ្តើមឡើង ដោយខ្មែរក្រហមបានសម្លាប់ប្រជាជនប្រមាណពីរលាននាក់ ស្មើនឹងមួយភាគបួននៃប្រជាជនកម្ពុជាទាំងមូល ។

កុំស្មានបងភ្លេច ៖ ខ្មែរបាត់បង់តន្ត្រីរ៉ក់ ដឹកកកាយនូវលក្ខណៈធាតុផ្សំរបស់តន្ត្រីខ្មែរ ដែលបានប្រែក្លាយជាតន្ត្រីរ៉ក់ អេន រ៉ូល ហើយបានរីកចម្រើនឆ្ពោះទៅមុខ ប៉ុន្តែស្ទើរតែត្រូវបានបំផ្លិចបំផ្លាញចោលទាំងស្រុងនៅក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម ។ ខ្សែភាពយន្តឯកសារនេះ បានផ្តល់គំហើញថ្មីស្តីពីប្រទេសមួយដែលធ្លាប់តែឮពីសង្គ្រាម និងពីអំពើប្រល័យពូជសាសន៍ ។

ខ្សែភាពយន្តនេះ គឺជាពិធីប្រារព្ធអបអរដល់សិល្បៈតន្ត្រីដ៏អស្ចារ្យមកពីប្រទេសកម្ពុជា និងស្វែងយល់ពីសារសំខាន់របស់សិល្បៈតន្ត្រីមកលើសង្គមពីអតីតកាល និងបច្ចុប្បន្ន» ។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាប្រធានផលិតកម្មខ្សែភាពយន្តឯកសាររឿង «កុំស្មានបងភ្លេច» បានឲ្យដឹងថា ៖ «ខ្មែរក្រហមបានសម្លាប់សិល្បករ និងសិល្បការិនីជាច្រើន និងមានចេតនាផ្លាស់ប្តូរទាំងស្រុងនូវសិល្បៈ វប្បធម៌ និងរបៀបរបបរស់នៅរបស់ប្រជាជន ។ ប៉ុន្តែខ្មែរក្រហមមិនអាចលុបបំបាត់សិល្បៈទាំងនោះបានឡើយ ដោយសារតែសិល្បៈស្ថិតនៅក្នុងដួងព្រលឹងរបស់ប្រជាជនយើងគ្រប់រូប ។ រហូតមកដល់សព្វថ្ងៃ យើងនៅតែបន្តច្រៀង (ចម្រៀងសម័យ) រួមទាំងចម្រៀងដែលនិពន្ធដោយខ្មែរក្រហម ។

ខ្សែភាពយន្តឯកសាររឿង «កុំស្មានបងភ្លេច» មិនត្រឹមតែនិយាយពីការបាត់បង់សិល្បៈតន្ត្រីប៉ុណ្ណោះទេ ប៉ុន្តែក៏បានបង្ហាញពីប្រវត្តិសាស្ត្រ សង្គ្រាម ភាពស៊ីវិល័យ គំនិតច្នៃប្រឌិតដ៏រស់រវើករបស់ សិល្បៈករ ភាពឃោរឃៅ រន្ធត់ និងតក់ស្លុតនៅក្នុងសម័យកាលមួយដែលសិល្បៈ និងតន្ត្រីត្រូវបានហាមឃាត់ និងលុបបំបាត់ ។

ខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច» ក៏បានបង្ហាញពីការស្លាប់ និងការបែកបាក់គ្រួសាររបស់ប្រជាជន និងសិល្បៈនៅក្នុងពេលសង្គ្រាម និងនៅពេលដែលយោធាខ្មែរក្រហមជម្លៀសប្រជាជនដោយបង្ខំចេញពីផ្ទះសម្បែង នៅខែមេសា ឆ្នាំ១៩៧៥ ។ រហូតមកដល់សព្វថ្ងៃ ប្រជាជន និងសិល្បៈករ ដែលនៅរស់រានមានជីវិតពីការកាប់សម្លាប់ក្នុងរបបខ្មែរក្រហមមួយចំនួននៅតែមិនទាន់បានទទួលដំណឹងពីសាច់ញាតិដែលបាត់ខ្លួននៅឡើយ ។ អ្នកទាំងនេះនៅតែចងចាំ និងរំពុកពីអំពើឃោរឃៅរបស់យោធាខ្មែរក្រហមដែលធ្វើមកលើប្រជាជន ។

ការបញ្ចាំងខ្សែភាពយន្តឯកសារ “កុំស្មានបងភ្លេច” នឹងប្រមូលប្រជាជននៅតាមភូមិនានាដែលកម្រនឹងមានឱកាសជួបគ្នាមកពិភាក្សាពីរឿងរ៉ាវផ្សេងៗ ដែលខ្លួនបានជួបប្រទះនៅក្នុងរបបខ្មែរក្រហម ។ ការបញ្ចាំងនេះ ក៏នឹងផ្តល់ឱកាសដល់អ្នកភូមិដើម្បីឲ្យគាត់និយាយចេញមកនូវរឿងរ៉ាវឈឺចាប់ដែលបានលាក់ទុកនៅក្នុងខ្លួនរបស់គាត់ជាច្រើនឆ្នាំមកហើយ និងជាផ្នែកមួយដើម្បីធ្វើឲ្យប្រជាជនទាំងអស់នោះបានធូរស្បើយក្នុងចិត្ត ។ ដោយសារតែរបបខ្មែរក្រហមបានកន្លងផុតទៅជាង៤០ឆ្នាំមកហើយ ដូច្នេះរឿងរ៉ាវរបស់ប្រជាជនមួយចំនួនហាក់ត្រូវបានមើលរំលង និងមិនអើពើ ទោះបីអ្នកទាំងនោះ កំពុងរស់ជាមួយនឹងភាពឈឺចាប់ ជំងឺផ្លូវចិត្តធ្ងន់បណ្តាលមកពីរបបនេះក៏ដោយ ។

ខ្សែភាពយន្តឯកសារនេះ នឹងរំឭកឡើងវិញពីស្នាដៃសិល្បៈដ៏រស់រវើករបស់ខ្មែរពីសម័យមុន ហើយដែលមិនត្រូវបានយកចិត្តទុក និងត្រូវបានបំផ្លាញចោលស្ទើរតែទាំងស្រុងពីរបបខ្មែរក្រហម ។ សិល្បៈករ និងអ្នកចម្រៀងល្បីល្បាញតាំងពីទសវត្សរ៍៦០ជាច្រើនត្រូវបានសម្លាប់ អ្នកដែលនៅរស់រានជីវិតត្រូវរួមគ្នាកសាងស្នាដៃសិល្បៈទាំងនេះឡើងវិញ ក្រោយពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ។

ទន្ទឹមនេះ ដើម្បីលើកតម្កើងស្នាដៃសិល្បៈ និងតន្ត្រីខ្មែរ ការបញ្ចាំងខ្សែភាពឯកសារ “កុំស្មានបងភ្លេច” នឹងជួយបំផុសប្រជាជននៅតាមទីជនបទនានាឲ្យចេះស្រឡាញ់ ថែរក្សាសិល្បៈរួមជាមួយការអប់រំដើម្បីទប់ស្កាត់កុំឲ្យកើតមានការបំផ្លិចបំផ្លាញសម្បត្តិសិល្បៈទាំងនេះទៀត ។

ថ្មីៗនេះ ខ្សែភាពយន្តឯកសារ “កុំស្មានបងភ្លេច” ត្រូវបានចាក់បញ្ចាំងជូនប្រជាជនទស្សនានៅខេត្តបាត់ដំបងដែលជាស្រុកកំណើតរបស់អតីតអ្នកចម្រៀងដ៏ល្បីល្បាញ គឺអ្នកស្រី រស់ សេរីសុទ្ធា កាលពីអំឡុងចុងទសវត្សរ៍៦០ និងដើមទសវត្សរ៍៧០ ។ ខ្សែភាពយន្តឯកសារនេះ ក៏បានចាក់បញ្ចាំង នៅខេត្តសៀមរាប ដែលជាខេត្តសម្បូរទៅដោយប្រាង្គប្រាសាទ ចម្លាក់ និងវប្បធម៌របស់កម្ពុជា និងនៅក្រុងបានលុង ខេត្តរតនគិរី ។

## ការចាក់បញ្ចាំងនៅខេត្តបាត់ដំបង

ប្រជាពលរដ្ឋនៅក្រុងបាត់ដំបងប្រមាណជាង៥០០នាក់ បានចូលរួមទស្សនាការបញ្ចាំងខ្សែភាពយន្តឯកសារ “កុំស្មានបងភ្លេច” នៅក្នុងបរិវេណវត្តដំរីស ក្រុងបាត់ដំបង ដែលស្ថិតនៅក្បែរ



ការចាក់បញ្ចាំងខ្សែភាពយន្តឯកសាររឿង “កុំស្មានបងភ្លេច” ៖ ខ្មែរបាត់បង់តន្ត្រីរ៉ក អេន រ៉ូល នៅវត្តដំរីស ក្រុងបាត់ដំបង ។ មានទស្សនិកជនដែលជាមន្ត្រី រាជការ សិស្ស និស្សិត ព្រះសង្ឃ និងប្រជាជនប្រមាណជាង៥០០នាក់ បានចូលរួមទស្សនាខ្សែភាពយន្តនេះ ។

ផ្ទះរបស់អតីតអ្នកចម្រៀង រស់ សេរីសុទ្ធា ។ ការបញ្ចាំងខ្សែភាពយន្តនេះ ក៏មានការចូលរួមពីសំណាក់គ្រួសាររបស់អ្នកស្រី រស់ សេរីសុទ្ធា ដែរ ។

បន្ទាប់ពីទស្សនិកជនបានទស្សនាខ្សែភាពយន្តនេះចប់ ក៏មានការពិភាក្សា និងសួរសំណួររវាងអ្នកចូលរួម និងផលិតករ ចន ពីរ៉ូហ្ស៊ី ។ ទស្សនិកជនបានបង្ហាញពីអាម្មណ៍ផ្សេងៗគ្នាអំពីខ្សែភាពយន្តនេះ ៖

ថេន សារ៉ុម ជាគ្រូបង្រៀនភាសាអង់គ្លេស បានបង្ហាញពីចំណុចពីរដែលគាត់ចាប់អារម្មណ៍ ក្រោយពីទស្សនា គឺអ្នកធាក់ស៊ីក្លូជាច្រើនមកឈប់ជុំគ្នានៅមុខវិទ្យុជាតិដើម្បីស្តាប់តន្ត្រី ។ អ្នកទាំងនោះហាក់ដូចជារីករាយជាមួយនឹងតន្ត្រី ទោះបីជាប្រទេសកំពុងប្រឈមនឹងសង្គ្រាមក៏ដោយ ព្រោះតន្ត្រីចម្រៀងជាផ្នែកមួយជួយឲ្យអារម្មណ៍បានស្បើយពីក្តីកង្វល់បានមួយគ្រាដែរ ។

ចំពោះ ប៊ូ ហាក់ ជាវិចិត្រករ បានបង្ហាញពីអាម្មណ៍របស់ខ្លួនថា គាត់ពិតជាភ្ញាក់ផ្អើលខ្លាំងណាស់ដែលប្រទេសយើងមាននៅសេសសល់ឯកសារ ដែលអាចបង្កើតកុននេះឡើង ។ គាត់បានលើកឡើងថា តន្ត្រីនៅសម័យនោះ គឺមានភាពខុសគ្នាឆ្ងាយណាស់ពីតន្ត្រីបច្ចុប្បន្ន ។ អ្នកចម្រៀងក្នុងអំឡុង ទសវត្សរ៍៦០ និង៧០ គឺមានសំឡេងក្រអួនក្រអៅ ផ្អែមល្ហែម ជាមួយនឹងទំនុកច្រៀងដ៏មានអត្ថន័យ និងអត្ថរស ហើយវាបាននាំអារម្មណ៍ខ្ញុំទៅកាន់កម្ពុជាកាលពីអតីតកាលដ៏អស្ចារ្យមួយ ។

សម្បត្តិ ជាកម្មករសំណង់ បានបង្ហាញពីការយល់ឃើញស្រដៀង ប៊ូហាក់ ដែរថា គាត់មិនចូលចិត្តចម្រៀងសម័យបច្ចុប្បន្ននោះទេ ។ អត្ថន័យក្នុងបទចម្រៀងបច្ចុប្បន្ន គឺគ្មានអ្វីក្រៅការស្រឡាញ់ និងការស្អប់នោះទេ ។

ក្នុងឱកាសនោះ អ្នកចូលរួមក៏បានពិភាក្សាគ្នាអំពីរឿងរ៉ាវផ្ទាល់ខ្លួន និងសមាជិកក្រុមគ្រួសារខ្លួននៅក្នុងរបបខ្មែរក្រហម បន្ទាប់ពីអ្នកទាំងនោះបានឃើញឈុតខ្លះនៅក្នុងភាពយន្តឯកសារដែលបង្ហាញអំពីរបបខ្មែរក្រហម ។ អ្នកចូលរួមទាំងនេះ ក៏បានចែករំលែកនូវបទពិសោធន៍របស់ខ្លួនជាមួយនឹងអ្នកចូល រួមផ្សេងទៀត ។ ការបញ្ចាំងកុននៅខេត្តបាត់ដំបងនេះ បានប្រព្រឹត្តទៅដោយមានកិច្ចសហការពីសំណាក់អាជ្ញាធរមូលដ្ឋាន និងជាពិសេសកិច្ចខិតខំប្រឹងប្រែងរបស់បងស្រី អ្នកស្រី រស់ សេរីសុទ្ធា ។ គាត់បានឲ្យដឹងថា "រឿងកុំស្មានបងភ្លេច" បាននាំអារម្មណ៍អ្នកគ្រប់គ្នាឲ្យត្រឡប់ទៅជួបអ្នកចម្រៀងចាស់ៗ និងគិតអំពីអតីតកាល ជាពិសេសរបបខ្មែរក្រហម ។

## ការចាក់បញ្ចាំងនៅខេត្តសៀមរាប

ដោយមានការសហការល្អពីសំណាក់អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ក្នុងខេត្តសៀមរាប និងអាជ្ញាធរជាតិអប្សរា ខ្សែភាពយន្តឯកសារដែលមានចំណងជើងថា "កុំស្មានបងភ្លេច" ត្រូវបានចាក់បញ្ចាំងជូនប្រជាជនទស្សនានៅបរិវេណស្រះស្រង់ ដែលស្ថិតក្នុងភូមិស្រះស្រង់ខាងជើង សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប ។ ប្រជាជនប្រមាណជាង ១.០០០នាក់ រួមមានព្រះសង្ឃ គ្រូបង្រៀន អាជីវករ កម្មករ កម្មការិនី កសិករ នៅតាមភូមិនានាបានចូលរួមទស្សនាខ្សែភាពយន្តនេះ ។

សិល្បៈចម្រៀងដែលបានបង្ហាញក្នុងខ្សែភាពយន្តនេះ បាននាំអារម្មណ៍អ្នកទស្សនាឲ្យត្រឡប់ទៅកាន់សម័យកាលមួយដែលរីករាយផង និងក្រៀមក្រំផង ៖

លោក ឡុក បូគាល់ ជាគ្រូបង្រៀននៅវិទ្យាល័យសម្តេចឪ បានបង្ហាញពីអារម្មណ៍រីករាយ និងតក់ស្លុតពេលដែលបានទស្សនា ហើយឮបទចម្រៀងមួយចំនួនដែលគាត់ធ្លាប់បានស្តាប់ និងច្រៀងលេងកាលពីអតីតកាល ។ កាលពីអំឡុងទសវត្សរ៍៦០ សិល្បៈចម្រៀងរបស់កម្ពុជាមានការរីកចម្រើន គួរជាទីកត់សម្គាល់ ។ បទនីមួយៗត្រូវបានតាក់តែងមកយ៉ាងពិរោះរណ្តំ ។ ចំណែកអត្ថន័យ និង សំនៀងរបស់អ្នកចម្រៀង គឺនៅតែស្ថិតក្នុងចិត្តអ្នកស្តាប់ជានិច្ច ។ គ្រូ បូគាល់ បានឲ្យដឹងថា នៅអំឡុង ទសវត្សរ៍៦០ ចម្រៀងដែលអ្នកនិពន្ធសរសេរ គឺមានគ្រប់រសជាតិទាំងមនោសញ្ចេតនា កំប្លុកកំប្លែង និងញាក់កន្ត្រាក់អារម្មណ៍ ហើយចម្រៀងទាំងនោះក៏បានផ្លាស់ប្តូរទៅតាមសម័យកាលដែរ ។ ជាក់ស្តែង ដូចជានៅក្នុងអំឡុងឆ្នាំ១៩៧០ ចម្រៀងត្រូវបានសរសេរ និងច្រៀងមួយបែបផ្សេងទៀត ដែលភាគច្រើនទាក់ទងនឹងការតស៊ូប្រយុទ្ធនឹងខ្មាំងសត្រូវ ឬជំរុញឲ្យយុទ្ធជនចូលធ្វើកងទ័ពដើម្បីការពារប្រទេសជាតិ ។

ការបញ្ចាំងរឿង "កុំស្មានបងភ្លេច" ក៏ជាវេទិកាមួយដែល



ក្រុមការងារកុន រួមជាមួយផលិតករ ចន ពីរ៉ូហ្ស៊ី បានចាក់បញ្ចាំងខ្សែភាពយន្តឯកសាររឿង "កុំស្មានបងភ្លេច" ៖ ខ្មែរបាត់បង់តន្ត្រីរ៉ក អេន រ៉ូល នៅភូមិស្រះស្រង់ខាងជើង ស្ថិតក្នុងសង្កាត់នគរធំ ក្រុងសៀមរាប ។ មានទស្សនិកជនដែលជាមន្ត្រីរាជការ សិស្ស និស្សិត ព្រះសង្ឃ និងប្រជាជនប្រមាណជាង១.០០០នាក់ បានចូលរួមទស្សនាខ្សែភាពយន្តនេះ ។

ផ្តល់ឱកាសដល់អ្នកដែលធ្លាប់បានឆ្លងកាត់សម័យកាលនោះចូលរួមចែករំលែកដល់អ្នកជំនាន់ក្រោយឲ្យបានដឹងអំពីរឿងរ៉ាវរបស់ខ្លួន តាមរយៈការទស្សនាកុនឯកសារដែលបង្ហាញពីសម័យកាលមួយទៅសម័យកាលមួយ ។

ពេលឮបទលោក ស៊ិន ស៊ីសាមុត ដែលមានចំណងជើងថា "អាហ្គោហ្គោ" អ៊ំប្រុសម្នាក់បានរម្លឹកប្រាប់ក្មេងៗដែលអង្គុយក្បែរគាត់ដោយទឹកមុខរីករាយថា គ្រាន់តែឮបទនេះភ្លាម ធ្វើឲ្យគាត់នឹកឃើញដល់ភាពជាយុវវ័យរបស់គាត់ និងសម័យកាលមួយដ៏រីករាយ ។ ប៉ុន្តែភាពរីករាយទាំងនេះ ត្រូវបានរលាយសាបសូន្យបន្ទាប់ពីខ្មែរក្រហមគ្រប់គ្រងប្រទេស ។ ពេលដែលគាត់មើលឃើញការដ្ឋានការងារនៅក្នុងរបបខ្មែរក្រហម និងឮចម្រៀងបដិវត្តន៍ធ្វើឲ្យទឹកមុខរបស់គាត់ប្រែជាស្រពោន ។ ចម្រៀងទាំងនេះបានធ្វើឲ្យគាត់នឹកឃើញដល់ភាពលំបាក វេទនាដែលគាត់បានជួបប្រទះ និងឆ្លងកាត់ ។ គាត់បានប្រាប់ក្មេងៗទាំងនោះថា នៅក្នុងរបបខ្មែរក្រហម ទោះបីជាមានការហាមប្រាមមិនឲ្យច្រៀងចម្រៀងពីសង្គមចាស់ក៏ដោយ គាត់តែងលួចច្រៀងលេងស្ងាត់ៗពេលនៅជាមួយមនុស្សដែលគាត់ទុកចិត្ត ។ គាត់បាននិយាយថា ពេលច្រៀងចម្រៀងទាំងនោះ ធ្វើឲ្យអារម្មណ៍យើងចាកឆ្ងាយពីការពិបាកចិត្ត និងទុក្ខវេទនាដែលយើងកំពុងជួបប្រទះមួយរយៈដែរ ។ អ្នកដែលបានមកចូលរួមទស្សនា ជាពិសេសប្រជាជនដែលមានវ័យចាស់ៗ តែងលើកយករឿងរ៉ាវរបស់ខ្លួនមកនិយាយប្រាប់ដល់សមាជិកគ្រួសារ និងអ្នកដែលនៅក្បែរខាងពីព្រឹត្តិការណ៍ដែលគាត់បានជួបប្រទះតាមសម័យកាលទាំងនោះ ទាំងភាពរីករាយ និងទុក្ខលំបាក ។ ក្មេងៗងាកសួរចាស់ៗនៅក្បែរខ្លួនអំពីទិដ្ឋភាពដែលបានឃើញក្នុងភាពយន្ត និងចោទជាសំណួរថា ក្នុងសម័យកាលទាំងនោះ ពិតជាមានការសម្តែងបែបនេះមែនទេ? និងសំណួរជាច្រើនទៀតដែលក្មេងទាំងនោះ បានមើលឃើញក្នុងភាពយន្តឯកសារមួយនេះ ។

យាន សុធីត អាយុ១៨ឆ្នាំ សិស្សវិទ្យាល័យសម្តេចឪ បានរៀបរាប់ប្រាប់ខ្ញុំជាមួយនឹងអារម្មណ៍ក្តុកក្តួលថា "ពេលដែលខ្ញុំបានឃើញវីដេអូត្រង់វគ្គមួយដែលបង្ហាញអំពីការដ្ឋានការងារដែលមនុស្សជាច្រើនកំពុងរែកដីក្នុងរបបខ្មែរក្រហម ធ្វើឲ្យខ្ញុំមានអារម្មណ៍ក្តុកក្តួល មិនអាចទប់ទឹកភ្នែកបានឡើយ ។ រូបភាពទាំងនេះធ្វើឲ្យខ្ញុំស្រមៃឃើញពីភាពលំបាករបស់ប្រជាជននៅក្នុងរបបខ្មែរក្រហម ។ ជាពិសេស ធ្វើឲ្យអារម្មណ៍ខ្ញុំនឹកដល់ពាក្យពេជន៍ដែល

ឪពុកម្ដាយរបស់ខ្ញុំធ្លាប់និយាយប្រាប់អំពីភាពលំបាកវេទនាដែលគាត់ធ្លាប់បានជួបប្រទះក្នុងរបបខ្មែរក្រហម ។ ខ្ញុំពិតជាមិនអាចទប់ទឹកភ្នែកមិនឲ្យហូរបានទេ ។ ខ្ញុំនឹកស្រណោះដល់ឪពុកម្ដាយរបស់ខ្ញុំដែលប្រឹងប្រែងតស៊ូតាំងពីរបបខ្មែរក្រហមរហូតដល់សព្វថ្ងៃនេះ» ។

**ការចាក់បញ្ចាំងនៅខេត្តរតនគិរី**

នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ក្រុមការងារកុនសហការ



ការរៀបចំបញ្ចាំងខ្សែភាពយន្តឯកសាររឿង "កុំស្មានបងភ្លេច" នៅមន្ទីរវប្បធម៌ ខេត្តរតនគិរី

ជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន បានរៀបចំបញ្ចាំងខ្សែភាពយន្តឯកសាររឿង "កុំស្មានបងភ្លេច" នៅបរិវេណមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តរតនគិរី ស្ថិតនៅក្នុងសង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី ដែលមានទស្សនិកជនប្រមាណជាង ៦០០នាក់ ចូលរួមទស្សនា ។ ក្នុងចំណោមអ្នកទស្សនាទាំងនេះ ៩៥ភាគរយ ជាសិស្ស (រួមទាំងសិស្សជនជាតិទំពួនផង) មកពីវិទ្យាល័យឡាបានសៀក, វិទ្យាល័យសម្ដេចឪ, គ្រូបង្រៀន, ប្រជាជន និងមន្ត្រីរាជការទូទាំងខេត្តរតនគិរីទាំងមូល ។

បន្ទាប់ពីទស្សនាខ្សែភាពយន្តឯកសារនេះចប់ ដាលីន ដែលជាសិស្សមកពីវិទ្យាល័យមួយ បានបង្ហាញអារម្មណ៍ភ្ញាក់ផ្អើលថា នាងមិននឹកស្មានថា នៅសម័យសម្ដេចព្រះនរោត្តម សីហនុ មានការរីកចម្រើនខ្លាំងខាងផ្នែកសិល្បៈដូច្នេះទេ ។ នាងចាប់អារម្មណ៍ទៅលើតន្ត្រី ការសម្ដែងរបស់សិល្បៈករ និងចម្រៀងនៅសម័យនោះ ។ ប៉ុន្តែនាងបានសម្ដែងការសោកស្ដាយចំពោះប្រទេសកម្ពុជា ដែលទទួលរងការទម្លាក់គ្រាប់បែកជាច្រើន ដែលការទម្លាក់គ្រាប់បែកនេះបានបំផ្លាញសម្បត្តិវប្បធម៌ និងសម្លាប់ជីវិតមនុស្ស រួមទាំងសិល្បៈករផង ។

ដាលីន បានសំណូមពរឲ្យយុវជនជំនាន់ក្រោយចូលរួមទស្សនាខ្សែភាពឯកសារ "កុំស្មានបងភ្លេច" នេះឲ្យបានគ្រប់ៗគ្នា ព្រោះយុវជនជាសសរទ្រូង និងជាអ្នកដឹកនាំប្រទេសទៅថ្ងៃអនាគត និងរួមគ្នាដើម្បីលើកតម្កើងវិស័យសិល្បៈ តន្ត្រីឲ្យរីកចម្រើនថែមទៀត ។

ចំណែក ទេស ដានិត អាយុ១៦ឆ្នាំ ជាសិស្ស បានឲ្យដឹងថា បន្ទាប់ពីគាត់បានទស្សនាខ្សែភាពឯកសារនេះចប់ ធ្វើឲ្យគាត់ដឹងច្រើនពីសិល្បៈតន្ត្រីនៅក្នុងសម័យនោះ ។ ដានិត តែងតែស្ដាប់ចម្រៀងដើម្បីលម្ហែរអារម្មណ៍ ។ ក្រៅពីចម្រៀង និងតន្ត្រីនៅក្នុងកុនឯកសារនេះ ដានិត ចាប់អារម្មណ៍ពីសង្គ្រាម ព្រោះបានធ្វើឲ្យគាត់យល់ដឹងច្រើនពីប្រវត្តិសាស្ត្រកាលពីសម័យនោះ ។ គាត់យល់ថា កុនឯកសារនេះមានសារសំខាន់ ហើយគាត់ចង់ឲ្យប្រជាជនខ្មែរទាំងក្មេងចាស់ ចូលរួមទស្សនាដើម្បីជាចំណេះដឹង និងរួមគ្នាថែរក្សាស្នាដៃសិល្បៈ ។

ខ្សែភាពយន្តឯកសារ "កុំស្មានបងភ្លេច" បានគ្រោង និងបន្តចាក់បញ្ចាំងនៅតាមបណ្ដាខេត្ត មួយចំនួនដូចជា ខេត្តមណ្ឌលគិរី (បញ្ចាំងនៅវត្តសែនមនោរម្យ) និងនៅខែមករា នៅឆ្នាំ២០១៧ នេះ នឹងចាក់បញ្ចាំងនៅខេត្តស្ទឹងត្រែង ដែលជាស្រុកកំណើតរបស់អតីតអ្នកចម្រៀងដ៏ល្បីលោក ស៊ិន ស៊ីសាមុត នៅថ្ងៃទី០៣ វេលាម៉ោង៦ល្ងាច (នៅវត្តកតិយ៉ារាម ហៅវត្តកណ្ដាល), ខេត្តកណ្ដាល នៅថ្ងៃទី៨ វេលាម៉ោង៣រសៀល (នៅវិទ្យាល័យ ហ៊ុន សែន ស្អាង) និងខេត្តកំពត នៅថ្ងៃទី១០ វេលាម៉ោង៦ល្ងាច (នៅវត្តត្រើយកោះ) ។

ខ្សែភាពយន្តនេះ ក៏មានបញ្ចាំងជូនសាធារណជនទស្សនារៀងរាល់ថ្ងៃសុក្រ វេលាម៉ោង១០ព្រឹក នៅវិចិត្រសាលសិល្បៈសហសម័យរបស់វិទ្យាស្ថានស្លឹករឹតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានទីតាំងនៅវិទ្យាស្ថានជាតិអប់រំ ។

**សោម ប៊ុនថន និង ធាច សារៈមុនិន្ទ**

# ខ្ញុំមិនមានការភ័យខ្លាចទេ ទោះបីជារស់នៅអតីតតំបន់ខ្មែរក្រហមក៏ដោយ

ជាប្រជាជនចំណូលថ្មីនៅស្រុកអន្លង់វែង មីង គង់ សុខា មានស្រុកកំណើតនៅខេត្តស្វាយរៀង ។ គាត់បានផ្លាស់មករស់នៅភូមិអូរគគីរក្រោម ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ទើបតែបានពីរឆ្នាំប៉ុណ្ណោះ ។ សុខា មករស់នៅស្រុកអន្លង់វែង ជាមួយគ្រួសារខាងប្តី ដែលមានឪពុកក្មេកជាអតីតយោធាខ្មែរក្រហម ។



ទូន សិរីរតនា និស្សិតស្ម័គ្រចិត្តគម្រោងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានសម្ភាស គង់ សុខា នៅផ្ទះរបស់គាត់ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ពីបទពិសោធន៍ទាក់ទងនឹងរបបខ្មែរក្រហម

បើទោះបីជារស់នៅក្នុងភូមិដែលពោរពេញដោយអតីតខ្មែរក្រហមក៏ដោយ ក៏ សុខា មិនមានអារម្មណ៍ភ័យខ្លាចក្នុងការនិយាយពីរឿងរ៉ាវដែលគាត់ធ្លាប់បានឆ្លងកាត់ប្រាប់មកខ្ញុំដែរ ។ នៅពេលសួរនាំគាត់ពីជីវិតក្នុងរបបខ្មែរក្រហម សុខា បានរៀបរាប់ប្រាប់ថា គ្រួសាររបស់គាត់ត្រូវបានខ្មែរក្រហមជម្លៀសពីខេត្តស្វាយរៀងមកដល់ឃុំក្បាលកោះ និងព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ កាលនោះ គាត់មិនដែលឃើញខ្មែរក្រហមសម្លាប់មនុស្សផ្ទាល់ភ្នែកទេ ប៉ុន្តែគាត់ជឿថាប្រាកដជាមានការសម្លាប់មនុស្ស ព្រោះគាត់បានឃើញអន្លង់មួយដែលមានសុទ្ធតែសាកសព ។ សុខា បានរំឭកប្រាប់ខ្ញុំទៀតថា ដោយសារតែគាត់នៅក្មេង អង្គការតម្រូវឲ្យគាត់ចូលក្នុងកងកុមារ ហើយការងាររបស់គាត់គឺរើសអាចម៍គោ និងដើរកាប់ដើមទន្រ្ទានខែត្រ ។

ព្រឹត្តិការណ៍ដែល សុខា ចងចាំនោះគឺ ថ្ងៃរំដោះ ៧ មករា នៅពេលមួយដែលវៀតណាមចូលមករំដោះនោះ គាត់បានឃើញយន្តហោះ និង ឡាន ជាច្រើនគ្រឿងបើកចូលមកដោយមានដាក់ទង់ជាតិវៀតណាម និងទង់ជាតិខ្មែរ និងឃើញមានមនុស្សជាច្រើនទៀត ។ ពេលនោះគាត់បានឃើញកងទ័ពទាំងនោះបាញ់សម្លាប់យោធាខ្មែរក្រហម ដែលយោធាខ្លះធ្លាក់ពីលើឡាននៅនឹងភ្នែក ។ បន្ទាប់មកមានមនុស្សប្រុសម្នាក់និយាយមកកាន់គាត់ឲ្យទៅប្រាប់ឪពុកម្តាយឲ្យត្រឡប់ទៅស្រុកវិញ ព្រោះប្រទេសបានរំដោះហើយ ។ ពេលឮដូច្នេះ សុខា ក៏ប្រញាប់រត់ទៅរកឪពុកម្តាយ និងបាននាំគ្នាធ្វើដំណើរត្រឡប់ទៅផ្ទះនៅខេត្តស្វាយរៀងវិញ ។

ជាជនរងគ្រោះដែលរស់រានមានជីវិត ចំពោះ សុខា ផ្ទាល់យល់ថា ការបង្កើតឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមជារឿងល្អ ហើយយ៉ាងហោចណាស់ក៏គាត់មានអារម្មណ៍ថាស្ងប់ចិត្តជាងមុនដែរ ។

សុខា មានអារម្មណ៍ថាធូរស្រាលច្រើននៅពេលដែលក្មេងជំនាន់ក្រោយចង់ដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហម ព្រោះគាត់ចង់ឲ្យក្មេងៗជឿថា ការសម្លាប់មនុស្ស និងការលំបាករបស់ប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬខ្មែរក្រហមនេះ គឺពិតជាមានប្រាកដមែន ។ ពេលខ្លះគាត់ក៏មានអារម្មណ៍ឈឺចាប់ដែរនៅពេលដែលក្មេងៗមិនជឿពីប្រវត្តិសាស្ត្រដ៏ជូរចត់ដែលគាត់ធ្លាប់បានឆ្លងកាត់មួយនេះ ។

**ទូន សិរីរតនា**

# សុខចិត្តរៀបការដើម្បីរក្សាជីវិតកូន

អ្នកមីង សាវី មានអាយុ៤៦ឆ្នាំ សព្វថ្ងៃរស់នៅភូមិអូរគគីរក្រោម ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ នៅមុនរបបខ្មែរក្រហម សាវី រស់នៅជាមួយឪពុកម្តាយនៅភូមិប្រាសាទ ឃុំសំរោងយា ស្រុកពួក ខេត្តសៀមរាម ។ នៅរបបខ្មែរក្រហម ឪពុករបស់ សាវី ឈ្មោះ ឈុំ សាញ់ ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ ។

សាវី បានរំឭកថា យប់នោះ ឪពុករបស់គាត់កំពុងជក់បារីនៅមុខខ្ទម ចំណែកគាត់ពេលនោះកំពុងដេកជាមួយម្តាយ ។ ពេលនោះកងឈ្លបបានមកហៅឪពុកគាត់ ហើយម្តាយគាត់សួរឈ្លបនោះថា នាំប្តីគាត់ទៅណា? ឈ្លបនោះឆ្លើយថា នាំពុកទៅព្រៃករកត្រី ។ នៅពេលនោះ មិនត្រឹមតែឪពុករបស់គាត់ម្នាក់ទេ សូម្បីតែពូរបស់គាត់ (ប្អូនប្រុសម្តាយ) ក៏ត្រូវឈ្លបនាំទៅជាមួយដែរ ។ គ្រាន់តែឃើញកងឈ្លបនាំអ្នកទាំងពីរទៅ ម្តាយគាត់អស់សង្ឃឹមថានឹងបានជួបគ្នាវិញហើយ ។ គាត់គិតថា ប្រហែលជាអង្គការស៊ើបដឹងថា អ្នកទាំងពីរគឺជាអតីតកងស្វ័យត្រាណក្នុងរបប លន់ នល់ ហើយ ។ ចាប់តាំងពីយប់នោះមក អ្នកទាំងពីរក៏បាត់ដំណឹងរហូត ។



ខាន់ ម៉ារី និស្សិតស្ម័គ្រចិត្តគម្រោងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានទៅជួប និងសម្ភាស សាវី នៅផ្ទះរបស់គាត់ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ពីបទពិសោធន៍ទាក់ទងនឹងរបបខ្មែរក្រហម ។

បន្ទាប់ពីការនាំប្តី និងប្អូនទៅបាត់មួយរយៈមក រឿងដែលគួរឲ្យហួសចិត្តចំពោះម្តាយរបស់ សាវី ក៏កើតឡើង ។ អង្គការបានបង្ខំឲ្យម្តាយរបស់គាត់យកប្តីថ្មី ប៉ុន្តែគាត់បានប្រកែក ។ អង្គការក៏បានបង្ខំគាត់ជាថ្មីម្តងទៀត ដោយប្រាប់ថា បើហ៊ានប្រកែកមួយលើក ជាពីរលើកទៀត អង្គការនឹងយកទៅសម្លាប់ទាំងម្តាយ ទាំងកូនមិនខាន ។ ដោយគ្មានជម្រើស ម្តាយរបស់ សាវី ក៏យល់ព្រមតាមបញ្ជារបស់អង្គការដើម្បីរក្សាជីវិតខ្លួន និងកូន ។

ក្រោយមក សាវី ត្រូវអង្គការចាត់ឲ្យនៅកងកុមារដោយមានការងាររកាប់ទន្ទ្រានខែត្រ ។ គាត់ធ្វើការនៅកងកុមារទទួលបានរបបបបរលាយជាមួយនឹងត្រកួនពីរពេលក្នុងមួយថ្ងៃ ហើយពេលយប់អាចមកដេកជាមួយម្តាយនៅផ្ទះ ។ សាវី ធ្វើការនៅកងកុមាររហូតដល់របបខ្មែរក្រហមដួលរលំ ។

សាវី បានរៀបការនៅឆ្នាំ ១៩៨៧ ជាមួយនឹងឈ្មោះ ប៊ុនតៃ ដែលជាយោធាខ្មែរក្រហម ។ នៅឆ្នាំដដែលគាត់ និងប្តី បានចាកចេញពីស្រុកកំណើតទៅរស់នៅជំរំសាយប៊ី ។ គាត់បានរំឭកថា ការរស់នៅជំរំលំបាកខ្លះដែរ ដោយសារតែយើងមិនអាចដើរទៅណាមកណាដោយសេរី ប៉ុន្តែចំពោះស្បៀងអាហារមិនសូវខ្វះខាតប៉ុន្មានទេ ព្រោះអង្គការចែកអង្ករ ស្រីខ គ្រឿងទេសឲ្យរៀងរាល់មួយអាទិត្យម្តង ។

បន្ទាប់ពីប្រទេសមានសុខសន្តិភាពពេញលេញ សាវី និងគ្រួសារ បានផ្លាស់មករស់នៅស្រុកអន្លង់វែង ។ គាត់បានទិញដីបន្ថែម សម្រាប់សាងសង់ផ្ទះ និងធ្វើស្រែចម្ការ ។ រឿងរ៉ាវដែលបានកើតឡើងចំពោះគាត់ និងគ្រួសារក្នុងរបបខ្មែរក្រហម គាត់មិនមានគំនិតគុំគួននោះទេ ។ សាវី មានជំនឿតាមផលកម្មអ្នកណាអ្នកសាង អ្នកនោះអ្នកទទួល ។ ទោះជាយ៉ាងណា សាវី តែងតែបន់ស្រន់កុំឲ្យប្រទេសកើតសង្គ្រាម និងអំពើកាប់សម្លាប់ម្តងទៀត ព្រោះគាត់មិនចង់បែកបាក់គ្រួសារម្តងទៀតនោះទេ ។

**ខាន់ ម៉ារី**

# អ្វីដែលខ្ញុំប្រាថ្នាចង់បាន គឺ សន្តិភាព

ឡឹក លាត ជាឈ្មោះដើមរបស់អតីតយុទ្ធជនម្នាក់ដែលបានចូលរួមចលនាតស៊ូបដិវត្តន៍ជាមួយខ្មែរក្រហម ។ បន្ទាប់ពីចូលបដិវត្តន៍នៅឆ្នាំ១៩៧៣ ឡឹក លាត បានផ្លាស់ប្តូរទៅឈ្មោះបដិវត្តន៍ថា ឡឹក សល និងបានប្រើរហូតមកដល់បច្ចុប្បន្ននេះ ។

សល ជាកូនកសិករដែលមានស្រុកកំណើតនៅស្រុកប្រាសាទបាគង ខេត្តសៀមរាប ។ មុនរបបខ្មែរក្រហម សល ជាក្មេងម្នាក់ដែលខស្សហ៍ព្យាយាមរៀនសូត្រ ។ គាត់បានជិះកង់យ៉ាងឆ្ងាយពីផ្ទះនៅឃុំបាគង ទៅរៀននៅសាលាស្ថិតនៅក្នុងវត្តលលៃ ក្នុងខេត្តសៀមរាប ។ សល បានរៀនត្រឹមថ្នាក់ទី១០ ប៉ុណ្ណោះ ស្រុកក៏កើតសង្គ្រាម ។

ក្រោយរដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ ភូមិស្រុករបស់ សល រស់នៅ ត្រូវបានគ្រប់គ្រងដោយខ្មែរក្រហម ។ ខ្មែរក្រហមបានធ្វើការកៀងគរប្រជាជន យុវជន យុវនារីឲ្យចូលរួមជាមួយចលនាបដិវត្តន៍របស់ខ្លួន ។

នៅឆ្នាំ១៩៧៣ សល និងយុវជន យុវនារីក្នុងភូមិមួយចំនួន ត្រូវបានកម្មាភិបាលខ្មែរក្រហម ជ្រើសរើសឲ្យធ្វើជាយោធា និងបញ្ជូនទៅហាត់ក្បួនយុទ្ធសាស្ត្រយោធា៣ខែ នៅកោះត្រឡាច ដែលស្ថិតក្នុងខេត្តសៀមរាប ។

សល បានឲ្យដឹងថា បន្ទាប់ពីហ្វឹកហាត់រួចមក គាត់ត្រូវបានថ្នាក់លើចាត់តាំងឲ្យទៅឈរជើងនៅសមរភូមិ ។ នៅសមរភូមិម្នាក់ៗ ត្រូវត្រៀមខ្លួនជាស្រេចក្នុងការប្រយុទ្ធ ។ សល បានរំឭកពីអារម្មណ៍របស់គាត់នៅពេលនោះប្រាប់ខ្ញុំថា «ពេលទៅច្បាំងម្តងៗ ខ្ញុំតែងតែមានអារម្មណ៍ភ័យព្រួយ ព្រោះថាការធ្វើសង្គ្រាម គឺតែងតែមានស្លាប់ និងមានរស់ បើមិនមែនគេ គឺខ្ញុំ» ។ នៅពេលនោះ




ក្រុមនិស្សិតស្ម័គ្រចិត្តបានទៅធ្វើទស្សនកិច្ចសិក្សារយៈពេលបីថ្ងៃនៅតំបន់ប្រវត្តិសាស្ត្រអន្លង់វែង ក្រោមការរៀបចំរបស់គម្រោងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

ខ្ញុំមិនបានគិតវែងឆ្ងាយទេ គ្រាន់តែដឹងថា គេឲ្យធ្វើអី យើងត្រូវតែធ្វើហ្នឹង ហើយយើងមិនអាចនិយាយតវ៉ាអ្វីបានទាំងអស់ ព្រោះបើហ៊ានតវ៉ា យើងនឹងមានរឿង ។

នៅឆ្នាំ១៩៧៥ សល បានរងរបួសធ្ងន់ដោយសារត្រូវអម្បែងគ្រាប់កាំភ្លើង អ៊ឹម-៧៩ នៅពេលប្រយុទ្ធជាមួយទាហាន លន់ នល់ ។ អម្បែងគ្រាប់បានខ្ទាតមកត្រូវជិតបំពង់ករបស់គាត់ ហើយបានធ្វើឲ្យមានស្នាមដែលបណ្ដាលឲ្យសុខភាពរបស់គាត់ចុះទ្រុឌទ្រោមរហូតមកដល់បច្ចុប្បន្ន ។

ប៉ុន្មានខែក្រោយជ័យជម្នះ សល បានជាសះស្បើយ ហើយត្រូវបានអង្គការផ្លាស់ឲ្យទៅបម្រើការនៅអង្គភាពកាំភ្លើងធំឈរជើងនៅព្រំដែនថៃ ។ ក្នុងអង្គភាពរបស់គាត់មានសមាជិក ១២នាក់ ដែលមានឈ្មោះ វ៉ុន ជាអ្នកគ្រប់គ្រង (បច្ចុប្បន្នរស់នៅខេត្តកំពង់ធំ) ។ រៀងរាល់បីថ្ងៃម្ដង មេក្រុមរបស់ សល តែងតែបើកអង្គប្រជុំ អប់រំ ទិតៀន និងតាមដានសកម្មភាពការងាររបស់សមាជិកក្រុម ។

ក្រៅពីការងារកងទ័ព សល និងសមាជិកក្រុមត្រូវធ្វើស្រែ លើកទំនប់ និងជីកប្រឡាយ ដូចប្រជាជនធម្មតាដែរ ។ ការងារនេះ សល បានធ្វើរហូតមកដល់ឆ្នាំ១៩៧៦ ។ ទោះបីជាយោធាក៏ដោយ ក៏ សល មិនបានរបបអាហារហូបចុកគ្រប់គ្រាន់ដែរ ។ ទាក់ទងការសម្លាប់ និងការធ្វើទារុណកម្មនៅក្នុងរបបខ្មែរក្រហម សល បាននិយាយថា ជាទូទៅ ទារុណកម្ម និងការសម្លាប់ដែលគាត់បានដឹង ភាគច្រើនមិនសូវកើតមានឡើងនៅក្នុងជួរកងទ័ពទេ ប៉ុន្តែច្រើនកើតមានឡើងចំពោះប្រជាជនធម្មតា ។

ឆ្នាំ១៩៧៧ កម្ពុជាប្រជាធិបតេយ្យ កើតមានសង្គ្រាមផ្ទៃក្នុង រវាងភូមិភាគនិរតី និង ភូមិភាគបូព៌ា ។ ជាសង្គ្រាមមួយដែលធ្វើការបោសសម្អាតទាំងខ្មាំងខាងក្នុង ក៏ដូចជាខ្មាំងខាងក្រៅ ។ ទោះជាយ៉ាងណា សល នៅតែបន្តបម្រើការងារក្នុងអង្គភាពកងកាំភ្លើងធំប្រចាំខេត្តឧត្តរមានជ័យដដែល ។

ឆ្នាំ១៩៧៨ សល ត្រូវបានអង្គភាពចាត់ឲ្យមកធ្វើជាគ្រូបង្រៀនកូនៗរបស់យោធា និងកម្មាភិបាលខ្មែរក្រហមវិញ ប៉ុន្តែស្ថិតនៅក្នុងអង្គភាពកាំភ្លើងធំដដែល ។ សល បង្រៀនសិស្សប្រមាណជាង២០ នាក់ ។ ការបង្រៀនសិស្ស គាត់គ្រាន់តែបង្ហាត់ក្មេងៗទាំងនោះអំពីអក្សរខ្មែរ ពីព្យញ្ជនៈ និងស្រៈ ព្រមទាំងបង្រៀនវិធីប្រកបអក្សរ ការអាន និងការសរសេរបន្តិចបន្តួចប៉ុណ្ណោះ ។

ឆ្នាំ១៩៧៩ សល បានវាយប្រយុទ្ធជាមួយកងទ័ពវៀតណាមនៅថ្នល់បែក ស្រុកសូត្រនិគម ខេត្តសៀមរាប ។ ពេលនោះ រថក្រោះរបស់កងទ័ពវៀតណាមបានវាយលុកយ៉ាងខ្លាំងនៅក្នុងទីតាំងដែល សល កំពុងឈរជើង ។ ដោយសារកងទ័ពរបស់វៀតណាមមានប្រៀបខ្លាំងជាង ទើបបណ្ដាលឲ្យខាងកងទ័ពរបស់ខ្មែរក្រហមទប់ទល់មិនឈ្នះ ពិសេសកងកាំភ្លើងធំរបស់ សល បានបាក់ទ័ពនាំគ្នារត់បែកខ្ញែកគ្នាអស់ ។ សល បានភៀសខ្លួនមកនៅជួរភ្នំក្រោម អស់រយៈពេលមួយឆ្នាំ ។

ឆ្នាំ១៩៨១ សល បានឡើងទៅលើជួរភ្នំដងរែក ដើម្បីបន្តឈរជើងការពារនៅទីនោះ ។ គាត់កម្រចុះពីភ្នំណាស់ មួយខែ ឬពីរខែទើបចុះពីភ្នំម្ដង ពេលចុះពីភ្នំ គឺសំដៅទៅស្រុកវ៉ារិន ស្រុកពួក និងស្រុកស្រីស្នំ ដើម្បីដឹកជញ្ជូនគ្រាប់ទុកសម្រាប់ប្រយុទ្ធតទល់ជាមួយកងទ័ពវៀតណាម និងម្យ៉ាងទៀត ក្នុងគោលបំណងធ្វើសកម្មភាពអប់រំ និងកៀងគរប្រជាជនឲ្យប្រយុទ្ធប្រឆាំងជាមួយនឹងវៀតណាម និងជួយផ្គត់ផ្គង់ជាស្បៀងដល់កម្លាំងខ្មែរក្រហម ។

នៅឆ្នាំ១៩៨២ សល បានរៀបការនៅលើភ្នំដងរែកជាមួយនារីម្នាក់ឈ្មោះ វួច លន់ ដែលជាអ្នកបម្រើការងារនៅទីនោះដែរ ។ សល បានឲ្យដឹងថា ពេលនោះ គាត់ទាំងពីរបានស្រឡាញ់គ្នា និងបានយល់ចិត្តគ្នា ។ បន្ទាប់មក សល បានសម្រេចចិត្តទៅប្រាប់មេក្រុមរបស់គាត់ ដើម្បីរៀបការ ដែលនៅក្នុងពេលនោះមានចំនួនពាគូ ។

សល បានចូលនិវត្តន៍ក្នុងឆ្នាំ២០១៣ បន្ទាប់ពីគាត់បានធ្វើជាគ្រូបង្រៀននៅសាលាបឋមសិក្សាអូរគគីរកណ្ដាល ។ គិតមកទល់នឹងពេលនេះ សល មានអាយុ៦៣ឆ្នាំហើយ ។ យ៉ាងណាមិញ សល នៅតែបន្តធ្វើការងារកសិកម្មបន្តិចបន្តួចនៅផ្ទះ ដើម្បីរកចំណូលខ្លះៗជួយផ្គត់ផ្គង់ដល់ជីវភាពរស់នៅក្នុងគ្រួសារ ។ ជាចុងក្រោយអ្វីដែល សល ប៉ងប្រាថ្នាធំជាងគេបំផុតសម្រាប់ជីវិតរបស់គាត់ គឺឯករាជភាព និងសន្តិភាពនៅក្នុងប្រទេសកម្ពុជា ។

**ព្រឿន បញ្ញារី**

# ដំណើរជីវិតឆ្លងកាត់របបខ្មែរក្រហម

យាយ ម៉ៅ យន់ អាយុ៦០ឆ្នាំ មានស្រុកកំណើតនៅភូមិជប់ ឃុំជប់តាត្រាវ ស្រុកអង្គរធំ ខេត្តសៀមរាប និងតា មី លឹម មានអាយុ៧០ឆ្នាំ ។ អ្នកទាំងពីររស់នៅក្នុងភូមិស្រឡៅស្រោង ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ តាយាយមានកូនចំនួនបួននាក់ ។ យាយ ម៉ៅ យន់ បានរៀបរាប់ពីដំណើរជីវិតរបស់គាត់ដែលបានឆ្លងកាត់ក្នុងរបបខ្មែរក្រហមដូចខាងក្រោម ៖

ស្ថិតនៅក្នុងភូមិជប់ ឃុំជប់តាត្រាវ ស្រុកអង្គរធំ ខេត្តសៀមរាប យាយ យន់ រស់នៅក្នុងគ្រួសារកសិករមួយដែលមានជីវភាពសមរម្យ ។ ក្នុងវ័យប្រមាណ១៥ឆ្នាំ គឺចំពេលដែលខ្មែរក្រហមវាយដណ្តើមបានជ័យជម្នះពីកងទ័ពរបស់លោកសេនាប្រមុខ លន់ នល់ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ អ្វីៗដែលជាការរំពឹងទុករបស់ប្រជាជនកម្ពុជាទូទាំងប្រទេសថា សង្គ្រាមនឹងត្រូវបានបញ្ចប់នោះ វាបានប្រែក្លាយទៅជាភាពផ្ទុយស្រឡះទៅវិញ ។ ប្រហែលជាបីម៉ោងក្រោយរំដោះ ខ្មែរក្រហមបានជម្លៀសប្រជាជនឲ្យចេញពីទីក្រុង ឲ្យទៅរស់នៅតាមបណ្តាខេត្តនានា ដោយយកលេសថា ខ្មាំងកងទ័ពរបស់អាមេរិកមកទម្លាក់គ្រាប់បែកក្នុងទីក្រុង ។ ប្រជាជនដែលរស់នៅទីក្រុងទាំងអស់បានបង្ខំចិត្តចាកចេញពីផ្ទះសម្បែងរបស់ខ្លួន ដោយរៀបចំសម្ភាររបស់របរសម្រាប់ហូបចុកបន្តិចបន្តួចទៅតាមខ្លួន ហើយធ្វើដំណើរដោយថ្មើរជើងទៅតាមទិសដៅរៀងៗខ្លួន ។ ចំពោះប្រជាជនដែលមានបងប្អូនរស់នៅទីជនបទស្រាប់ មានការងាយស្រួលក្នុងការពឹងពាក់ ស្នាក់អាស្រ័យជាមួយពេលដែលខ្លួនទៅដល់ ។ ប៉ុន្តែ ចំពោះប្រជាជនដែលរស់នៅក្នុងទីក្រុងភ្នំពេញ ហើយគ្មានបងប្អូននៅតាមទីជនបទវិញ គឺពិតជាមានការលំបាកខ្លាំងណាស់ ។ មិនយូរប៉ុន្មាន នៅពេលដែលប្រជាជន (អ្នក១៧មេសា) ទៅដល់ទីជនបទភ្លាម ខ្មែរក្រហម



មាស សុជា និស្សិតស្ម័គ្រចិត្តគម្រោងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានទៅជួប និងសម្ភាសយាយ ម៉ៅ យន់ ពីបទពិសោធន៍ក្នុងរបបខ្មែរក្រហម ក្នុងអំឡុងពេលចុះទៅធ្វើទស្សនកិច្ចសិក្សារយៈពេលបីថ្ងៃ នៅតំបន់ប្រវត្តិសាស្ត្រអន្លង់វែង ខេត្តឧត្តរមានជ័យ

បានប្រមូលយកសម្ភារ និងរបស់របរប្រើប្រាស់ដែលជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន យកទៅដាក់ធ្វើជាសម្បត្តិរួមនៅកន្លែងមួយដែលគេហៅថា "សហករណ៍" ។ ទ្រព្យសម្បត្តិរបស់គ្រួសារយាយ យន់ ក៏ត្រូវបានខ្មែរក្រហមប្រមូលយកអស់ដែរ ។

ក្នុងភូមិនីមួយៗ មានរោងសហករណ៍ប្រហែលជាពីរ ឬបីកន្លែង អាស្រ័យទៅលើទំហំរបស់ភូមិ និងចំនួនប្រជាជនដែលរស់នៅ ។ នៅក្នុងផ្ទះរបស់ប្រជាជននាសម័យកាលនោះ គឺគ្មានរបស់អ្វីដែលសំខាន់ និងមានតម្លៃក្រៅពីកំសៀវដាំទឹកដីកញ្ចាស់មួយតែប៉ុណ្ណោះ ។ យាយ យន់ រួមជាមួយអ្នកភូមិដទៃទៀត ត្រូវបានប្រធានភូមិដែលទើបតែបានជ្រើសតាំងថ្មីដោយអង្គការខ្មែរក្រហម បានចាត់តាំងឲ្យធ្វើការងារបង្កបង្កើនផល លើកទំនប់ លើកភ្លឺស្រែ តាមផែនការរបស់ថ្នាក់លើដាក់ឲ្យ ។ ប្រជាជនម្នាក់ៗត្រូវលើកភ្លឺស្រែយ៉ាងហោចណាស់១៥ម៉ែត្រ បើសិនជាធ្វើមិនទាន់នោះគ្មានសិទ្ធិឈប់សម្រាក និងហូបបាយឡើយ ។ ចំពោះយាយ យន់ បានខិតខំតស៊ូ ប្រឹងប្រែងព្យាយាមធ្វើការងារនោះទាល់តែបានសម្រេចតាមផែនការ ។ ចំណែកអាហារដែលធ្វើឲ្យប្រជាជនហូបវិញ គឺបបរពីរវែករាវៗសុទ្ធតែទឹកស្ទើរតែរកគ្រាប់អង្ករគ្មាន និងលាយជាមួយបណ្តូលចេក ប្រៀបដូចជាបបរសម្រាប់ឲ្យសត្វជ្រូកដែរ ។

ជារៀងរាល់ថ្ងៃ យាយ យន់ ខំប្រឹងធ្វើការងារបានទៀងទាត់ ព្រោះយាយជាអ្នកស្រែចម្ការស្រាប់ ប៉ុន្តែ ពិតជាគួរឲ្យអាណិតចំពោះអ្នកដែលធ្លាប់រស់នៅក្នុងទីក្រុង ដែលធ្លាប់តែហូបអាហារគ្រប់គ្រាន់ ឆ្ងាញ់ៗ ហើយមិនធ្លាប់ទទួលរងនូវការងារនឿយហត់បែបនេះ គឺពិតជាលំបាកណាស់ ។ ប្រជាជនថ្មី មិនបានហូបឆ្អែត និងមិនអាចទប់ទល់ជាមួយនឹងអាកាសធាតុខាងក្រៅបានបណ្តាលឲ្យកើតជំងឺ តែគ្មានថ្នាំពេទ្យព្យាបាល គ្មានអ្នកនៅមើលថែ គឺរង់ចាំតែថ្ងៃស្លាប់ប៉ុណ្ណោះ ។

នៅឆ្នាំ១៩៧៦ យាយ យន់ បានបែកពីឪពុកម្តាយដោយខ្មែរក្រហមបានចាត់តាំងឲ្យទៅរៀនពេទ្យផ្នែកឆ្មបនៅភូមិភាគនិរតី ។ ការណ៍ដែលបញ្ជូនយាយឲ្យទៅរៀននេះ គឺដើម្បីជួយសម្រាលកូនឲ្យប្រពន្ធរបស់យោធាខ្មែរក្រហម ។ ក្នុងពេលដែលលោកយាយកំពុងបំពេញការងារជាឆ្មបនៅឯអង្គភាព គាត់ឃើញទិដ្ឋភាពដ៏ព្រៃផ្សៃរបស់យោធាខ្មែរក្រហមទៅលើកុមារដែលទើបកើតចេញពីផ្ទៃម្តាយ និងកុមារដែលមានអាយុប្រមាណ៦-៧ឆ្នាំ ត្រូវបានយោធាខ្មែរក្រហមវាយទម្លាក់ទៅក្នុងរណ្តៅ ។ រីឯកុមារតូចៗ ដែលកំពុងតែដេកលក់ក្នុងអង្រឹង ត្រូវបានខ្មែរក្រហមបោះឡើងទៅខាងលើ ហើយធ្លាក់មកដី ស្រែកយំកងរំពង ពោរពេញដោយក្តីឈឺចាប់មុននឹងខ្មែរក្រហមសម្លាប់ចោល ក្នុងខណៈដែលឪពុកម្តាយរបស់ក្មេងទាំងនោះទៅបំពេញការងារនៅស្រែឆ្ងាយ ។

យាយ យន់ បានប្រាប់ឲ្យដឹងថា ទង្វើដែលខ្មែរក្រហមធ្វើបែបនេះទៅលើកុមារៗ ដោយខ្មែរក្រហមបានគិតថា កុមារទាំងនេះ បើទុកនៅក៏ឥតប្រយោជន៍ ព្រោះកុមារៗទាំងនេះមិនបានជួយធ្វើការងារ ស្របទៅនឹងពាក្យមួយឃ្លាដែលអង្គការតែងនិយាយជារឿយៗថា "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត" ។ យាយ យន់ បានអះអាងថា ការធ្វើបែបនេះ គឺស្ថិតនៅក្រោមបញ្ជារបស់ថ្នាក់ដឹកនាំ (តាម៉ុក) ។ យាយ យន់ បានឃើញទិដ្ឋភាពបែបនេះស្ទើររាល់ថ្ងៃ ។ លុះដល់ពេលឪពុកម្តាយរបស់កុមារមកពីធ្វើស្រែវិញ មិនឃើញកូនៗ តែងយំសោកបោកខ្លួន ហើយមានការខឹងសម្បារ និងគុំគួនជាមួយខ្មែរក្រហមជាខ្លាំង តែក៏មិនហ៊ានធ្វើការតវ៉ាដែរ ។ ទោះបីលោកយាយ មិនធ្លាប់បានទទួលការវាយធ្វើបាបពីសំណាក់យោធាខ្មែរក្រហមដោយផ្ទាល់ក៏ដោយ តែយាយធ្វើចិត្តមិនបាននឹងទទួលយកនូវភាពព្រៃផ្សៃដែលយាយបានឃើញផ្ទាល់ភ្នែកនូវទង្វើរបស់ខ្មែរក្រហម ធ្វើមកលើកុមារតូចៗទាំងអស់នេះបានទេ ។

ប្រមាណជាបីខែក្រោយមក យាយ យន់ ក៏បានសម្រេចចិត្តរត់ចេញពីអង្គភាព មករស់នៅក្នុងខេត្តសៀមរាប និងបានមកធ្វើការងារលើកភ្លឺស្រែជាមួយអ្នកភូមិជាធម្មតាវិញ ។ ប៉ុន្មានថ្ងៃក្រោយមក អ្នកដឹកនាំរបស់យាយ រួមជាមួយទាហានខ្មែរក្រហមនៅតំបន់ បានចុះមកហៅយាយ យន់ ឲ្យទៅធ្វើការនៅកន្លែងដើមវិញ ប៉ុន្តែយាយបានប្រកែក ។ ពេលនោះ យោធាខ្មែរក្រហមម្នាក់បានយកកាំភ្លើងមកភ្ជង់យាយ យន់ និងបានគំរាមសម្លាប់ ។ ពេលនោះយាយ យន់ បាននិយាយទៅកាន់យោធាខ្មែរក្រហមថា "បើខ្ញុំបានធ្វើអ្វីខុស សូមលោកបាញ់សម្លាប់ខ្ញុំចុះ តែបើខ្ញុំគ្មានទោសទេ សូមលោកកុំសម្លាប់ខ្ញុំអី" ។ ក្រោយពីយោធាខ្មែរ

ក្រហមបានឲ្យយាយ យន់ និយាយដូច្នេះហើយ ក៏បានទម្លាក់កាំភ្លើងចុះ ហើយបានឲ្យយាយ យន់ ទៅធ្វើការក្នុងកងនារីវិញ ។

នៅក្នុងកងនារី យាយ យន់ មានតួនាទីជាអ្នកដឹកជញ្ជូនស្បៀងអាហារ គ្រឿងសព្វាវុធ ដើម្បីយកទៅផ្គត់ផ្គង់ដល់កងទ័ពដែលកំពុងតែធ្វើសង្គ្រាមប្រឆាំងទប់ទល់ជាមួយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា រួមជាមួយកងទ័ពវៀតណាម ។ ការងារនេះ យាយ យន់ ត្រូវធ្វើដំណើរដោយថ្មើរជើង កាត់ព្រៃ និងកាត់វាល ។ យាយដេកនៅគ្រប់ទីកន្លែង ពេលមេឃភ្លឺត្រូវធ្វើដំណើរបន្តទៀតរហូតដល់ទិសដៅដែលបានកំណត់ ។

ប្រហែលជាពីរខែក្រោយមក កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដែលគាំទ្រដោយកងទ័ពវៀតណាម បានវាយយកជ័យជម្នះទាំងស្រុងលើខ្មែរក្រហមនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

នៅពេលនោះ មេដឹកនាំខ្មែរក្រហម រួមមាន ប៉ុល ពត, តាម៉ុក, សុន សេន រួមជាមួយយោធាខ្មែរក្រហម និងគ្រួសាររបស់យោធាជាច្រើនគ្រួសារទៀតដែលក្នុងនោះមានយាយ យន់ ម្នាក់ដែរ បាននាំគ្នារត់គេចខ្លួនទៅរស់នៅលើភ្នំដងរែក ។

ជីវិតរស់នៅលើកំពូលភ្នំដងរែក ខុសគ្នាស្រឡះពីការរស់នៅក្នុងស្រុកភូមិកំណើតដែលពោរពេញទៅដោយភាពភ័យខ្លាច (១៩៧៥-១៩៧៩) ។ ការរស់នៅលើកំពូលភ្នំដងរែក ប្រជាជនមានអាហារសម្រាប់ហូបចុកគ្រប់គ្រាន់ដែលបានទទួលការឧបត្ថម្ភពីសំណាក់មេដឹកនាំខ្មែរក្រហម ។ តួនាទីជាកងនារីរបស់យាយ យន់ ត្រូវបានបញ្ចប់ ។ ពេលនោះ យាយត្រូវបានចាត់តាំងឲ្យធ្វើជាអ្នកមើលថែទាំក្មេងកំព្រាវិញ ។ យាយ យន់ មានចិត្តអាណិតក្មេងៗកំព្រាទាំងអស់នោះណាស់ ក្មេងទាំងនោះត្រូវបានបាត់បង់ឪពុកម្តាយ ដោយសារតែការដឹកនាំរបស់ខ្មែរក្រហម ។ រូបគាត់ផ្ទាល់ក៏ត្រូវបែកបាក់ពីឪពុកម្តាយជាទីស្រឡាញ់ ព្រាត់ប្រាស់បងប្អូនរបស់ខ្លួន តែយាយបែកពីគ្រួសារពេលដែលគាត់មានវ័យធំ ដឹងខុសត្រូវជាងក្មេងៗទាំងអស់នេះ ។ យាយមានចម្ងល់ថា «ហេតុអីបានជាមេដឹកនាំខ្មែរក្រហម បែរជាយកចិត្តទុកដាក់ចំពោះប្រជាជន និងរូបគាត់ដោយផ្តល់ជាស្បៀងអាហារគ្រប់គ្រាន់ និងមិនមានការគំរាមកំហែង គឺផ្ទុយស្រឡះពីការដឹកនាំកាលពីមុន (ពីឆ្នាំ១៩៧៥-១៩៧៩) ។

យាយ យន់ បានរស់នៅលើកំពូលភ្នំដងរែកនេះ រហូតដល់កងទ័ពរដ្ឋាភិបាលវាយចូលមក ហើយមេដឹកនាំខ្មែរក្រហមបាននាំគ្នារត់ចូលទៅក្នុងទឹកដីថៃអស់ ទើបគាត់វិលត្រឡប់មករស់នៅស្រុកកំណើតក្នុងខេត្តសៀមរាបវិញ ។ ពេលមកដល់ស្រុកកំណើត លោកយាយមិនបានជួបជុំឪពុកម្តាយ និងបងប្អូនរបស់គាត់ទេ ដោយអ្នកស្រុកដែលរស់នៅទីនោះបានប្រាប់ថា ឪពុកម្តាយរបស់គាត់បានស្លាប់អស់ហើយ ។ ចំណែកដីស្រែដែលជាកេររបស់ឪពុកម្តាយត្រូវមេភូមិលួចយកធ្វើជាកម្មសិទ្ធិខ្លួន ពេលនោះលោកយាយគ្មានសេសសល់អ្វីទាំងអស់ ។ នៅឆ្នាំ១៩៩៦ យាយ យន់ បានសម្រេចចាកចេញពីខេត្តសៀមរាប ហើយមករស់នៅឯភូមិស្រឡៅស្រោង ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យវិញ រហូតមកដល់សព្វថ្ងៃ ។

## ការបាត់បង់ព្រៃឈើ នៃស្រុកអន្លង់វែង

ខេត្តឧត្តរមានជ័យ កាលពីដើមឡើយ គឺស្ថិតនៅក្នុងខេត្តសៀមរាប ។ ខេត្តនេះត្រូវបានបង្កើតឡើង និងបានកាត់ផ្តាច់ចេញពីខេត្តសៀមរាបនៅក្នុងសម័យសង្គមរាស្ត្រនិយម ។ យាយ យន់ បានឲ្យដឹងថា ចំពោះទេសភាពធម្មជាតិនៃខេត្តឧត្តរមានជ័យ គឺពិតជាមានភាពស្រស់បំព្រង រុក្ខជាតិតូចធំដុះចម្រុះគ្នា រួមជាមួយនិងសម្រស់ព្រៃភ្នំ ជួរភ្នំដងរែកវែងអន្លាយខៀវស្រងាត់ មើលទៅគួរជាទីគយគន់ក្រៃលែង ។ យាយ យន់ បានបន្តឲ្យដឹងថា បើយើងធ្វើការប្រៀបធៀបពីសម្រស់ស្រុកអន្លង់វែងពីមុនមកទល់សព្វថ្ងៃ គឺមានភាពខុសគ្នាស្រឡះ ពីព្រោះថា ព្រៃឈើតូចធំទាំងឡាយនៅក្នុងព្រៃ ត្រូវបានបាត់បង់អស់រលីង ។ តើការបាត់បង់ព្រៃឈើនេះបណ្តាលមកពីមូលហេតុអ្វី? យាយ យន់ បាននិយាយថា នៅសម័យខ្មែរក្រហម (១៩៧៥-១៩៧៩) ថ្វីបើមានការកាប់សម្លាប់មនុស្សយ៉ាងយង់ឃ្នង ព្រៃផ្សៃពីសំណាក់មេដឹកនាំខ្មែរក្រហមមកលើប្រជាជនកម្ពុជាក៏ដោយ ប៉ុន្តែ មេដឹកនាំខ្មែរក្រហមមិនបានកាប់បំផ្លាញព្រៃឈើទេ ។ ក្រោយពីការដួលរលំនៃរបបខ្មែរក្រហម មេដឹកនាំខ្មែរក្រហមមួយចំនួនត្រូវគេចខ្លួនទៅរស់នៅលើកំពូលភ្នំដងរែក ។ ការរស់នៅលើកំពូលភ្នំ ប្រាកដជាជួបការលំបាកដោយគេចមិនផុត បើគ្មានការជួយទំនុកបម្រុង



បឹងតាម៉ុក ស្ថិតនៅក្នុងស្រុកអន្លង់ ខេត្តឧត្តរមានជ័យ ។ បច្ចុប្បន្ន បឹងតាម៉ុក ត្រូវបានក្រសួងទេសចរណ៍រក្សាទុកជាបឹងប្រវត្តិសាស្ត្រសម្រាប់ភ្ញៀវទេសចរណ៍ទស្សនា ហើយបឹងនេះ ក៏ជាកន្លែងស្តុកទឹកទុកសម្រាប់ប្រជាជននៅក្នុងសហគមន៍ប្រើប្រាស់ដែរ ។

ប្តុគត់ផ្គង់ ស្រូវ អង្ករ ស្បៀងអាហារ និងសម្ភារផ្សេងៗ ពីអ្នកខាងក្រៅទេនោះ ។ សួរថា តើស្បៀងអាហារទាំងអស់នោះ តើតាម៉ុក បានមកពីណា? យាយ យន់ បានបន្តថា តាម៉ុក បានធ្វើការទាក់ទងជាមួយថៃ ដើម្បីបានជាស្បៀងអាហារទាំងអស់នោះ យកមកផ្គត់ផ្គង់ដល់កងទ័ព និងប្រជាជនរបស់ខ្លួន ។ តាមរយៈការផ្តល់ស្បៀងអាហារពីថៃ តាម៉ុក ត្រូវកាប់ឈើយកទៅលក់ឲ្យថៃ ។ លើសពីនេះ តាម៉ុក បានបញ្ជាឲ្យកងទ័ពរបស់ខ្លួនកាប់ឈើយកធ្វើលំនៅដ្ឋានគ្រប់ៗគ្នា ។ ប៉ុន្តែ ការកាប់ព្រៃឈើទាំងនោះ គឺតាម៉ុក បានបញ្ជាឲ្យកាប់តែដើមឈើណាដែលគ្រប់អាយុប៉ុណ្ណោះ ។

លុះក្រោយមក ពេលដែល តាម៉ុក ត្រូវបានរាជរដ្ឋាភិបាលចាប់ខ្លួន ព្រៃឈើក្នុងស្រុកអន្លង់វែង ត្រូវរងនូវភាពអន្តរាយ ដោយសារប្រជាជនដែលរស់នៅក្នុងតំបន់កាប់បំផ្លាញ រួមជាមួយនឹងប្រជាពលរដ្ឋមកពីតំបន់ផ្សេងៗទៀត នាំគ្នាសម្រុកមកកាប់ឈើ និងរស់នៅទីនេះច្រើនឡើងៗ ហើយគ្រួសារនីមួយៗ បានធ្វើការរុករានដី រាទដីដើម្បីធ្វើស្រែចម្ការ ព្រមទាំងមានក្រុមហ៊ុនថៃមួយចំនួនចូលមកកាប់ឈើយ៉ាងអាណាធិបតេយ្យ ដោយគ្មានការរវល់អើពើពីសំណាក់មន្ត្រីរាជការ ក៏ដូចជាអាជ្ញាធរដែរ ។ ទង្វើទាំងនេះបានធ្វើឲ្យព្រៃឈើនៅតំបន់អន្លង់វែង បាត់បង់យ៉ាងគំហុក ពិសេសពីឆ្នាំ ២០០០ មកទល់បច្ចុប្បន្ននេះ ធ្វើឲ្យព្រៃឈើបាត់បង់យ៉ាងច្រើន ហើយសត្វព្រៃជាច្រើន បានរត់ទៅរស់នៅក្នុងព្រៃនៃទឹកដីថៃ ។

ចំពោះការបាត់បង់ព្រៃឈើនេះ ទាំងលោកយាយ យន់ក្តី ទាំងប្រជាជនដែលរស់នៅក្នុងស្រុកអន្លង់វែងក្តី ពិតជាមានការព្រួយបារម្ភជាខ្លាំង ព្រោះគាត់យល់ថា ទៅថ្ងៃអនាគតកូនចៅ ពិតជាលែងបានឃើញ និងស្គាល់ប្រភេទឈើល្អៗ និងសត្វព្រៃមិនខាន ។ ការបាត់បង់ព្រៃឈើនេះ ក៏អាចកើតមានជាគ្រោះធម្មជាតិ គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ ការកើនកំដៅនៃភពផែនដីដែរ ។

នៅពេលអនាគត យាយ ម៉ៅ យន់ ក៏ដូចប្រជាជនដែលរស់នៅក្នុងស្រុកអន្លង់វែងទាំងអស់ ចង់ឲ្យស្រុកអន្លង់វែងមួយនេះក្លាយទៅជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ តាមរយៈសមិទ្ធផលដែលបានសន្សល់ទុកពីសំណាក់មេដឹកនាំខ្មែរក្រហមទាំង១៨កន្លែង ដែលក្រសួងទេសចរណ៍បានចាត់ទុកជាតំបន់ទេសចរណ៍នេះ មានអ្នកទេសចរជាតិ និងអ្នកទេសចរអន្តរជាតិ ចូលមកទស្សនាឲ្យបានច្រើន ជាពិសេសនោះ គឺចំពោះទេសចរជាតិ ព្រោះប្រជាជនខ្មែរមួយចំនួនធំស្ទើរតែមិនបានដឹងថា ស្រុកអន្លង់វែង គឺជាទឹកដីដែលមេដឹកនាំខ្មែរក្រហមកាន់កាប់ចុងក្រោយក្នុងចលនាតស៊ូរបស់ខ្លួន ។

**មាស សុខជា**

# ការបាត់បង់ព្រៃឈើនៅតែជាការបារម្ភ



ផល សំណាង និស្សិតស្ម័គ្រចិត្តគម្រោងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានទៅជួប និងសម្ភាស សឿន ស៊ីម នៅផ្ទះរបស់គាត់ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ពីបទពិសោធន៍ទាក់ទងនឹងរបបខ្មែរក្រហម

សឿន ស៊ីម ជាប្រជាជនម្នាក់រស់នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ គាត់មានស្រុកកំណើតនៅខេត្តកំពង់ស្ពឺ ។ ជាមនុស្សរួសរាយម្នាក់ គាត់បានរៀបរាប់រឿងរ៉ាវផ្ទាល់ខ្លួនខ្លះៗ ប្រាប់ដល់ខ្ញុំ មុនពេលដែលគាត់មកដល់ស្រុកអន្លង់វែងនេះ ។

ស៊ីម និងគ្រួសាររស់នៅស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។ បន្ទាប់ពីរដ្ឋប្រហារទម្លាក់ សម្តេច សីហនុ តំបន់ដែល ស៊ីម រស់នៅ ត្រូវបានគ្រប់គ្រងដោយខ្មែរក្រហម ។ ស៊ីម បានឈប់រៀននៅថ្នាក់ទី៩ (សង្គមចាស់) ហើយបានចូលរួមជាមួយចលនាតស៊ូរបស់ខ្មែរក្រហម ដោយមាននាទីជាយោធា ដែលពេលនោះគាត់មានវ័យទើបតែ ១២ឆ្នាំប៉ុណ្ណោះ ។ ស៊ីម បានរំឭកថា ការងារជាយោធា គឺគាត់ទទួលបានការហ្វឹកហ្វាត់ត្រឹមត្រូវដើម្បីត្រៀមប្រយុទ្ធនឹងទាហាន លន់ នល់ ។ ចំពោះស្បៀងអាហារ និងសម្លៀកបំពាក់មិនខ្វះខាតទេ ។

ស៊ីម នៅចាំបានថា អ្នកគ្រប់គ្រងនៅពេលនោះមានឈ្មោះ គឿន និង កុយ ហើយប្រធានកងពលគាត់មិនចាំឈ្មោះទេ ។ ការហ្វឹកហាត់របស់គាត់ពេលនោះមានការយកចិត្តទុកដាក់ពីសំណាក់គ្រូ ម៉្យាងទៀត ដោយសារគាត់ពេញចិត្ត និងស្រឡាញ់ការងារជាយោធានេះផង ទើបធ្វើឲ្យគាត់មិនមានអារម្មណ៍ភ័យខ្លាចពេលឡើងទៅប្រយុទ្ធនៅសមរភូមិ ។

ទោះបីជាយ៉ាងណាក៏ដោយ បន្ទាប់ពីខ្មែរក្រហមគ្រប់គ្រងប្រទេស សមាជិកគ្រួសាររបស់ ស៊ីម មិនមានសំណាងដូច ស៊ីម ទេ ។ អ្នកទាំងអស់គ្នាត្រូវអង្គការបំបែក និងចាត់តាំងឲ្យចូលធ្វើការតាមកងផ្សេងៗ ។ ពេលនោះ ស៊ីម ក៏មិនដែលបានទទួលដំណឹង ឬសុខទុក្ខក្រុមគ្រួសារដែរចាប់តាំងពីចូលធ្វើយោធា ។ គាត់មិនដែលបានត្រឡប់មកលេងផ្ទះទេ ។ ស៊ីម រំឭកអំពីជីវិតជាយោធាប្រាប់ខ្ញុំថា គាត់បានប្រយុទ្ធជាមួយទាហាន លន់ នល់ ជាច្រើនលើក ។ ក្រុមរបស់គាត់មានគ្នាប្រមាណ៦០០ នាក់ បានប្រយុទ្ធដំបូងនៅម្តុំត្រពាំងក្រឡឹង ខេត្តកំពង់ស្ពឺ និងបានត្រូវរបួសជាច្រើន ទើបដកថយ ។ ស៊ីម បានឲ្យដឹងថា ពេលនោះថ្នាំសង្កូវសម្រាប់ព្យាបាលភាគច្រើនទទួលបានមកពីប្រទេសចិន ហើយចំពោះម្ហូបអាហារវិញគឺមិនខ្វះខាតទេ ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ស៊ីម បានគេចខ្លួនចេញពីយោធាខ្មែរក្រហម ត្រឡប់មកស្រុកកំណើតនៅថ្ពងវិញ ។ គាត់បានជួបជុំគ្រួសារវិញ និងបានស្ម័គ្រចិត្តចូលធ្វើជាសេនាជនការពារភូមិ ។

ស៊ីម មិនបានចាំរឿងរ៉ាវដែលគាត់ឆ្លងកាត់ទាំងអស់ទេ

ដោយសារតែវាបានកន្ទួលផុតទៅច្រើនឆ្នាំមកហើយ ។ ស៊ីម រស់នៅស្រុកកំណើតរហូតដល់ឆ្នាំ២០០០ ទើបគាត់ និងគ្រួសារសម្រេចចិត្តទៅរស់នៅអន្លង់វែង ។

ស៊ីម បានឲ្យដឹងថា មកដល់ដំបូង តំបន់អន្លង់វែង គឺមានសភាពស្ងាត់ជ្រងំ ហើយហ៊ុំព័ទ្ធទៅដោយព្រៃក្រាស់ៗ និងមានសត្វតូចធំជាច្រើន ។ ចំណែកឯផ្លូវធ្វើដំណើរ ពោរពេញទៅដោយភក់ជ្រាំ ដែលពិបាកក្នុងការធ្វើដំណើរណាស់ ។ ប្រជាជននៅទីនេះភាគច្រើន ប្រកបរបរធ្វើស្រែចម្ការ ។ ទោះបីជាគ្រួសាររបស់ ស៊ីម មានជីវភាពធម្មតា និងធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិត តែគាត់ពិតជាមានសុភមង្គល ព្រោះគាត់បានរស់នៅជួបជុំគ្រួសារ ហើយក៏មិនចាំបាច់ព្រួយបារម្ភអំពីការរស់នៅបែកបាក់គ្រួសារដូច ក្នុងរបបខ្មែរក្រហមដែរ ។

ស៊ីម បានបន្តថា ពីមួយឆ្នាំទៅមួយឆ្នាំ ប្រជាជនរស់នៅតំបន់អន្លង់វែងមានការកើនឡើង ព្រោះមានអ្នកចំណូលថ្មីមករស់នៅ និងប្រកបរបររកស៊ីជាបន្តបន្ទាប់ ។ ទន្ទឹមនឹងការកើនឡើងអ្នកដែលមករស់នៅអន្លង់វែង ព្រៃឈើក៏ចាប់ផ្តើមវិចវិលបន្តិចម្តងៗ ដោយសារតែ មានការកាប់រានដីសាងសង់ផ្ទះ ធ្វើចម្ការ ហើយជាពិសេសការកាប់បំផ្លាញពីសំណាក់ឈ្មួញរកស៊ីឈើតែម្តង ។ ស៊ីម ប្រាប់ខ្ញុំជាមួយនឹងអារម្មណ៍សោកស្តាយថា ពេលនេះ ព្រៃឈើក្រាស់ៗ សត្វតូច ធំ ដែលគាត់ធ្លាប់បានឃើញ គឺមិនមានទៀតទេ ហើយជំនួសមកវិញនូវចម្ការដំណាំធំៗ ។

ក្តីបារម្ភរបស់ ស៊ីម ចំពោះការបាត់បង់ព្រៃឈើ គឺ ព្រៃឈើជាប្រភពទាក់ទាញទឹកភ្លៀង ហើយបើភ្លៀងធ្លាក់មិនទៀងទាត់នោះទេទិន្នផលស្រូវរបស់គាត់ក៏មិនបានផលច្រើនដែរ ។ ព្រៃឈើមានប្រយោជន៍ណាស់សម្រាប់មនុស្សជាតិ ជាពិសេស អាចជួយបញ្ចៀសនូវគ្រោះ ធម្មជាតិដូចជា ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ជាដើម ។ ជាចុងក្រោយ ស៊ីម ក៏ស្នើឲ្យប្រជាជនទាំងអស់ចូលរួមថែរក្សាព្រៃឈើ និងអប់រំក្មេងៗជំនាន់ក្រោយអំពីគុណប្រយោជន៍នៃព្រៃឈើសម្រាប់ជីវិតមនុស្សជាតិ ។

**ផល សំណាង**

# ដំណឹងស្វែងរកពូ និងមីង



នាងខ្ញុំឈ្មោះ កប ដាវី ជាកូនរបស់លោកឪពុកឈ្មោះ ពៅ កប ។ ឪពុកខ្ញុំកើតនៅឆ្នាំ១៩៣០ នៅភូមិសូសិតក្រោម ឃុំដំណាក់កន្ទួត ស្រុកកំពង់ត្រាច ខេត្តកំពត ។ គាត់មានឪពុកឈ្មោះ ពៅ កាន់ និងម្តាយឈ្មោះ អ៊ុំ ផិន ។

ឪពុកខ្ញុំ ពៅ កប បានចូលរួមក្នុងចលនាខ្មែរឥស្សរៈនៅជំនាន់អាណានិគមនិយមបារាំង ។ ក្រោយមក គាត់បានទៅទីក្រុងហាណូយ ប្រទេសវៀតណាម ។

នៅឆ្នាំ១៩៥៤ គាត់បានរៀបការជាមួយប្រពន្ធជនជាតិវៀតណាម និងមានកូនស្រីពីរនាក់ ។ នៅឆ្នាំ១៩៧០ គាត់បានចូលមកកម្ពុជាវិញ ដើម្បីវាយប្រឆាំងនឹងអាមេរិក ហើយក្រោយមកទៀត ខ្ញុំគ្រាន់តែដឹងថា គាត់ត្រូវបានខ្មែរក្រហមសម្លាប់ ។

ជាចុងក្រោយ ខ្ញុំគ្រាន់តែដឹងថា ឪពុករបស់ខ្ញុំមានប្អូនប្រុសឈ្មោះ ពៅ ហ៊ុន និងប្អូនស្រីឈ្មោះ ពៅ ហឹម ។ សព្វថ្ងៃ ខ្ញុំនៅតែចង់ជួប និងសង្ឃឹមថា ពូមីង នឹងបានឃើញខ្ញុំ ហើយអាចមករកខ្ញុំ (ក្មួយ) នៅមន្ទីរពេទ្យធំ (ព្រះកេតុមាលា) ព្រោះសព្វថ្ងៃខ្ញុំជាគ្រូពេទ្យមធ្យមនៅមន្ទីរពេទ្យនេះ ។

**ពីក្មួយ កប ដាវី**

# ស្ងួស វណ្ណា ហៅ យឿន
# អតីតកងទ័ពជើងទឹកប្រចាំកងពលលេខ៣

ស្ងួស វណ្ណា ហៅ យឿន មានស្រុកកំណើតនៅភូមិដូនឪ ឃុំត្រពាំងរាំង (បច្ចុប្បន្នឃុំស្នាយអញ្ជិត) ស្រុកឈូក (បច្ចុប្បន្នស្រុកជុំគីរី) ខេត្តកំពត ។ យឿន មានឪពុកឈ្មោះ ស្ងួស សុខ (ស្លាប់) និងម្ដាយឈ្មោះ ចេង ដៃ (ស្លាប់) ។ គាត់ជាកូនទី៦ក្នុងណោមបងប្អូនប្រុសស្រី៧នាក់ ។ សព្វថ្ងៃបងប្អូនបង្កើតរបស់គាត់នៅរស់តែបីនាក់ប៉ុណ្ណោះ ។ យឿន បានរំឭកអំពីជីវិតរបស់គាត់ក្នុងរបបខ្មែរក្រហមថា ៖

ក្នុងឆ្នាំ១៩៧២ យឿន ទើបតែមានអាយុត្រឹមតែ១៣ឆ្នាំប៉ុណ្ណោះ ត្រូវបានមេឃុំឈ្មោះ ស្ងួង បង្ខំឲ្យចូលធ្វើជាកងទ័ពខ្មែរក្រហម ។ ដំបូងឡើយ យឿន ធ្វើជាកងឈ្លបម្នាក់នៅឃុំត្រពាំងរាំង ។ ពីរទៅបីខែក្រោយមក យឿន ត្រូវបានបញ្ជូនឲ្យទៅធ្វើជាកងយោធាស្រុកឈូក ដោយឈរជើងនៅវត្តអង្គអស់រយៈពេល ៦ខែ ហើយក្រោយមក គាត់ត្រូវបានផ្ទាក់លើបញ្ជូនទៅកងអនុសេនាធំឈរជើងនៅកំពង់ត្រាច ទាន់ហន់ តាមបណ្ដោយព្រំដែនកម្ពុជាវៀតណាម ។ យឿន ឈរជើងនៅទីនោះប្រហែលមួយឆ្នាំទើបផ្ទាក់លើបញ្ជូនកងរបស់គាត់ ទៅវាយជាមួយទាហាន លន់ នល់ នៅឯស្រែអំបិល និងទឹរូមខេត្តកំពតក្នុងខែកក្កដា ឆ្នាំ១៩៧៣ ។ រហូតដល់ឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមកំពុងតែច្បាំងដណ្ដើមទីក្រុងភ្នំពេញ កងពលរបស់ យឿន ត្រូវបានបញ្ជូនទៅវាយជាមួយទាហាន លន់ នល់ នៅកំបូល និងបែកចាន ។


ក្រុមការងារគម្រោងជំរុញឲ្យមានការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានទៅជួប និងសម្ភាស ស្ងួស វណ្ណា ហៅ យឿន ទាក់ទងនឹងរបបខ្មែរក្រហម នៅផ្ទះរបស់គាត់ ស្ថិតនៅស្រុកឈូក ខេត្តកំពត កាលពីឆ្នាំ២០០៩

បន្ទាប់ពីខ្មែរក្រហមដណ្ដើមបានទីក្រុងភ្នំពេញនៅថ្ងៃ១៧ មេសា ១៩៧៥ កងពលរបស់ យឿន ត្រូវបានបែងចែកជាពីរផ្នែកធំៗ ។ មួយកងពលត្រូវបានបញ្ជូនទៅវាយនៅឯដោះអញ្ជូរស្ថិតនៅក្បែរកំពង់សោម ហើយ យឿន ស្ថិតនៅក្នុងផ្នែកមួយទៀតដែលត្រូវទៅឈរជើងនៅតំបន់ទឹកសាបកងកេង ។ ក្នុងកងពលធំលេខ៣ ដែល យឿន ឈរជើងនៅកងកេង មានកងវរសេនាធំៗទាំងអស់ចំនួន៣ មានលេខ៦១, ៦២ និង៦៣ ។ យឿន ពុំបានស្គាល់ប្រធានកងវរសេនាធំលេខ៦១ទេ ប៉ុន្តែ យឿន ស្គាល់ តា សារី ដែលជាមេកងវរសេនាធំ៦២ ។ បច្ចុប្បន្ននេះ តា សារី បានស្លាប់ហើយ ។

យឿន ស្ថិតនៅក្នុងកងវរសេនាតូច៦៥ កងវរសេនាធំ៦៣ ចំណុះកងពលទី៣ ។ អ្នកដឹកនាំធំៗនៅក្នុងកងវរសេនាតូច ៦៥ មាន តាឈឿន ប្រធាន, ម៉ុន អនុប្រធាន និង កាន សមាជិក ។ តាឈឿន មានស្រុកកំណើតនៅភូមិព្រៃវែង ស្រុកជុំគិរី ខេត្តកំពត ។ ចំណែកឯប្រធានកងវរសេនាធំ៦៣ មានឈ្មោះ តាយ៉ាន និងអនុប្រធានឈ្មោះ តា ញាន់ ។ ក្រោយមកតា ញាន់ បានឡើងឋានៈជាអនុប្រធានកងពលធំលេខ៣ ។ បច្ចុប្បន្ន តា ញាន់ រស់នៅស្រុកអន្លង់វែង ។ ប្រធានកងពលធំលេខ៣ គឺតា មុត ។

អំឡុងពេលឈរជើងនៅកងកេង យឿន មានតួនាទីជាប្រធានកងវរសេនាតូច ដែលគ្រប់គ្រងកងទ័ពប្រមាណជា៣០ នាក់ ។ ប្រធានកងសេនាធំ ដែលគ្រប់គ្រងលើ យឿន មានឈ្មោះថា តានី ។ ស្របពេលដែល យឿន កំពុងឈរជើងនៅកងកេងប្រហែលជា១ខែ គាត់បានដឹងដំណឹងថា ខ្មែរក្រហមចាប់បានកប៉ាល់ធំមួយឈ្មោះថា កប៉ាល់ម៉ាយ៉ាហ្គេស របស់អាមេរិក ។ បន្ទាប់ពីការចាប់កប៉ាល់ ម៉ាយ៉ាហ្គេសហើយ ខាងរដ្ឋាភិបាលសហរដ្ឋអាមេរិកបានចេញសេចក្ដីប្រកាសព័ត៌មានតាមវិទ្យុទៅកាន់ខ្មែរក្រហមឲ្យធ្វើការដោះលែងកប៉ាល់ម៉ាយ៉ាហ្គេសភ្លាម បើមិនដូច្នោះទេ សហរដ្ឋអាមេរិកនឹងបញ្ជូនទាហានមកធ្វើការទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជាជាថ្មីឡើងវិញ ។ ដោយសារតែខ្មែរក្រហមមិនព្រមដោះលែងកប៉ាល់ម៉ាយ៉ាហ្គេស កងទ័ពអាកាសអាមេរិកបានធ្វើការទម្លាក់គ្រាប់បែកមកលើព្រលានយន្តហោះកងកេង និងតំបន់មួយចំនួនទៀតនៅកំពង់សោមអស់រយៈពេលប្រហែលជា២យប់ ៣ថ្ងៃ ដែលបានបណ្ដាលឲ្យឆេះយន្តហោះអស់ជាច្រើនគ្រឿង និងខូចខាតផ្ទះសម្បែងខ្លះដែរ ។ កប៉ាល់នេះក៏ត្រូវបានសហរដ្ឋអាមេរិករំដោះយកទៅវិញ ។

លុះដល់ខែកក្កដា ឆ្នាំ១៧៧៥ កងវរសេនាតូច៦៥របស់ យឿន ត្រូវបានបញ្ជូនទៅកោះថ្មី និងកោះសេះ ។ ខ្មែរក្រហមបានធ្វើការបែងចែកកងអនុសេនាធំចំនួនពីរឲ្យនៅឈរជើងកោះថ្មី ហើយចំណែកឯមួយកងអនុសេនាធំទៀតត្រូវបានបញ្ជូនទៅកោះសេះ ។ យឿន បានយាមល្បាតនៅកោះថ្មីប្រហែល៨ទៅ៩ខែ ។ ពាក់កណ្ដាលឆ្នាំ១៩៧៦ គាត់ក៏ត្រូវបានផ្ទាក់លើចាត់បញ្ចូលទៅក្នុងកងវរសេនាធំជើងទឹកលេខ១៨០ ។

ក្នុងចំណោមមនុស្សជាច្រើនដែលត្រូវបានបញ្ចូលទៅក្នុងកង១៨០នេះ យឿន នៅចងចាំបានមនុស្សម្នាក់ប៉ុណ្ណោះឈ្មោះ ទ្រូន ។ បន្ទាប់ពីចូលក្នុងកងវរសេនាធំជើងទឹកលេខ១៨០ ភ្លាម យឿន ត្រូវបានបញ្ជូនឲ្យហ្វឹកហាត់បច្ចេកទេសជួសជុលកប៉ាល់ នៅអូរឈើទាលរយៈពេល៦ខែ ដោយមានការបង្ហាត់បង្រៀនដោយគ្រូឯកទេសជើងទឹក ជនជាតិចិនប្រហែល១០នាក់ដែលមកពីប្រទេសចិន និងមានការសម្របសម្រួលផ្នែកភាសាដោយជនជាតិខ្មែរដែលធ្លាប់បានរៀនសូត្រនៅប្រទេសចិន ។ កងទ័ពដែលត្រូវបានបង្ហាត់នៅអូរឈើទាលមានប្រមាណជា៧០នាក់ ដែលអ្នកទាំងនោះត្រូវបានជ្រើសរើសឲ្យទៅរៀនតាមផ្នែកដូចជា ផ្នែកម៉ាស៊ីន, កាំភ្លើង, រ៉ាដា, បើកបរ, កងកាំភ្លើងធំ ជាដើម ។

ក្រោយបញ្ចប់វគ្គសិក្សាកងទ័ពជើងទឹកទាំងអស់ត្រូវបានបញ្ជូនទៅកាន់មូលដ្ឋានរាមដើម្បីធ្វើការចាត់ចែងទៅតាមកប៉ាល់នានា ។ ស្របពេល យឿន ទើបតែបញ្ចប់វគ្គសិក្សាថ្មីៗ ចិនជួយជាជំនួយកប៉ាល់ចម្បាំង២គ្រឿងឲ្យខ្មែរក្រហមដែលមានលេខ ០១១ និង០១២ ដូច្នេះ យឿន ក៏បានចូលបម្រើការផ្នែកម៉ាស៊ីនក្នុងកប៉ាល់ប្រឆាំងលេខ០១១ ដែលជាកប៉ាល់ជំនួយចុងក្រោយបង្អស់របស់ចិនមកឲ្យខ្មែរក្រហម ។ យឿន បានចេញល្បាតតាមកប៉ាល់ពីមូលដ្ឋានរាមទៅតាមកោះនានា ជួនកាលគាត់ទៅល្បាតនៅកោះតាងមួយសប្ដាហ៍ ឬក៏មួយខែ ហើយត្រឡប់ទៅមូលដ្ឋានរាម ឬអូរឈើទាល និងទៅតាមកោះវិញ សាចុះសាឡើង ។

កងវរសេនាធំជើងទឹក១៨០ស្ថិតនៅក្នុងកងពលលេខ៣

ដែលមានការគ្រប់គ្រងរបស់ តា មុត ផ្ទាល់ ។ បញ្ជាការដ្ឋានកងពលទ័ពជើងទឹកធំស្ថិតនៅសណ្ឋាគារ៧ជាន់ក្នុងក្រុងកំពង់សោម និងមូលដ្ឋានតូចៗ២ទៀត ដែលមួយស្ថិតនៅអូរឈើទាលសម្រាប់ជាចំណតកប៉ាល់សង្គ្រាម និងបង្ហាត់ទ័ព ហើយមូលដ្ឋាននៅរាមសម្រាប់ជាចំណតកប៉ាល់ដឹកសម្ភារ ព្រមទាំងរក្សាទុកទូកដែលចាប់បាន ។ កងវរសេនាធំជើងទឹក១៤០ នេះមានកប៉ាល់ការពារចំនួន ១០ កប៉ាល់ល្បាត១២ ទូកបណ្តែត១២ ទូក *PCF* ដែលផលិតនៅសហរដ្ឋអាមេរិកដែលសល់ពីសម័យសាធារណរដ្ឋខ្មែរចំនួន៤ កប៉ាល់ផ្តាច់មីន៤ និងកប៉ាល់ចម្បាំង២ ។ កប៉ាល់ចម្បាំងអាចផ្ទុកមនុស្សបានលើសពី៧០នាក់ កប៉ាល់ការពារអាចផ្ទុកមនុស្សបានច្រើនជាង៣០នាក់ កប៉ាល់ល្បាតផ្ទុកមនុស្សបាន១២នាក់ កប៉ាល់បណ្តែតផ្ទុកមនុស្ស១២នាក់ និងទូក *PCF* ផ្ទុកមនុស្សបានពី៧ទៅ ៨នាក់ ។ ទូក *PCF* ប្រើសម្រាប់ល្បាតនៅតាមតំបន់កោះ និងចាប់ទូកវៀតណាម និងទូកនេសាទថៃ ព្រមទាំងទូកឬកប៉ាល់ផ្សេងៗទៀត ។

នៅឆ្នាំ១៩៧៨ ខ្មែរក្រហមបានឃាត់កប៉ាល់សិង្ហបុរីមួយទៀត ។ ខណៈពេលដែល យឿន កំពុងតែយាមល្បាតទៅក្បែរកោះតាង យឿន បានឃើញកប៉ាល់នេះបោះយុថ្កានៅខាងកើតកោះតាង និងមានការយាមកាម ដោយទូក *PCF* ។ នៅពេលដែល យឿន បានឃើញកប៉ាល់នោះ មនុស្សដែលនៅក្នុងកប៉ាល់សិង្ហបុរីទាំងអស់ត្រូវបានចាប់បញ្ជូនទៅបញ្ជាការដ្ឋានកងពលធំជើងទឹកនៅកំពង់សោមអស់ហើយ ។ ការបញ្ជូនមនុស្សទៅកំពង់សោមនេះដើម្បីធ្វើការបញ្ជូនបន្តទៅភ្នំពេញ ។ មនុស្សទាំងអស់ដែលនៅលើកប៉ាល់នោះសុទ្ធសឹងតែជាជនជាតិបរទេស ដែលនិយាយភាសាអង់គ្លេស ។

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមមិនត្រឹមតែឃាត់បានកប៉ាល់ធំៗទាំងពីរខាងលើទេ ខ្មែរក្រហមចាប់បានទូកនេសាទថៃ និងទូកកងទ័ពវៀតណាមប្រមាណ៣០ ទៅ៥០ គ្រឿង ដែលក្នុងនោះភាគច្រើនជាទូកនេសាទថៃ ។ នៅមុនការចាប់កប៉ាល់សិង្ហបុរី រាល់ទូកនេសាទថៃដែលចាប់បានត្រូវបានដោះលែងឲ្យទៅប្រទេសវិញ ។ តែក្រោយមកទៀត រាល់ទូកដែលចាប់បានទាំងអស់មិនត្រូវបានដោះលែងឡើយ ។ អំឡុងពេលដែលចាប់បានទូកច្រើនជាងគេបំផុតគឺនៅចុងឆ្នាំ១៩៧៧ ដល់ដើមឆ្នាំ១៩៧៨ ។ ម្យ៉ាងវិញទៀតរាល់អ្នកនេសាទថៃទាំងអស់ត្រូវបានបញ្ជូនទៅបញ្ជាការដ្ឋាននៅកំពង់សោមដើម្បីធ្វើការបញ្ជូនបន្តហើយទូកទាំងនោះត្រូវយកទៅចតនៅរាម ឬក៏កម្ទេចចោលតែម្តង ។ រីកងទ័ពវៀតណាមដែលបន្លំខ្លួនជាអ្នកនេសាទវិញ ត្រូវបានសម្លាប់ចោលនៅនឹងកន្លែង និងខ្លះទៀតត្រូវបានបញ្ជូនយកទៅសម្លាប់នៅតំបន់ *TE* ស្ថិតនៅរាម និងខ្លះទៀតត្រូវបានបញ្ជូនទៅភ្នំពេញ ។

ពេលដែលយួនវាយចូលស្រុកខ្មែរដើមឆ្នាំ១៩៧៩ កប៉ាល់ *PCF* ចំនួនពីរគ្រឿងបានចេញទៅប្រយុទ្ធតែ ត្រូវបានកងទ័ពវៀតណាមបាញ់លិចអស់ ហើយខ្មែរក្រហមក៏បញ្ជូនកប៉ាល់ការពារទៅមួយគ្រឿងទៀត តែត្រូវបានកងទ័ពវៀតណាមបាញ់ឲ្យលិចដូចគ្នា ។

បន្ទាប់មកខ្មែរក្រហមបានចាត់ឲ្យកប៉ាល់ចម្បាំងរបស់ យឿន ទៅម្តង ។ នៅពេលទៅជិតដល់ខ្មែរក្រហមបានឲ្យកប៉ាល់នេះត្រឡប់មកវិញ ។ នៅពេលដែលវៀតណាមចូលលុកលុយពេញកម្ពុជាហើយ កប៉ាល់ចម្បាំងនេះត្រូវបាន យឿន យកទៅបើកបុកកម្ទេចចោលនៅព្រែកត្រពាំង រួចហើយ យឿន ក៏រត់ទៅព្រំដែន និងរួចរស់ជីវិតរហូតដល់បច្ចុប្បន្ន ។

សព្វថ្ងៃនេះ យឿន មានប្រពន្ធ និងកូនប្រុស៦នាក់ ។ ប៉ុន្តែជាអកុសល កូនប្រុសរបស់គាត់ពីរនាក់បានស្លាប ។ យឿន និងប្រពន្ធ មិនមានប្រកបរបរអ្វីទេ គឺកូនៗរបស់គាត់ជាផ្គត់ផ្គង់ជីវភាពគាត់ទាំងពីរ ។

**គិត ស្រីពៅ**

# អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ *http://d.dccam.org/Projects/Magazines/Magazine_Searching.htm* ។ ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# បាត់ដំណឹងឪពុកម្តាយ និងប្អូនៗ សូន្យឈឹង

កាលពីខែវិច្ឆិកា ឆ្នាំ២០១៦ កន្លងទៅ មជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំ "វេទិកាសាធារណៈស្តីពីការផ្សាយបន្តផ្ទាល់ ការប្រកាសសាលដីកាស្ថាពររបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមក្នុងសំណុំរឿង០០២ វគ្គ១ ប្រឆាំងនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន" នៅវត្តថាឡាបរិវ៉ាត់ ដែលស្ថិតនៅក្នុងឃុំថាឡាបរិវ៉ាត់ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ។ ក្រោយពេលចប់កម្មវិធី ខ្ញុំបានធ្វើដំណើរសំដៅទៅផ្ទះរបស់ក្រុមប្រឹក្សាឃុំថាឡាបរិវ៉ាត់ ក្នុងគោលបំណងលាគាត់វិលមកទីរួមខេត្តស្ទឹងត្រែងវិញ ។ ពេលទៅដល់ផ្ទះរបស់គាត់ ខ្ញុំបានឃើញគាត់កំពុងអង្គុយសរសេររបាយការណ៍លើកៅអីឈើមួយនៅក្បែរគ្រែ ។ គាត់បានចេញមករាក់ទាក់ខ្ញុំ ជាមួយនឹងទឹកមុខញញឹម ហើយបានហៅខ្ញុំ និងមិត្តរួមការងារម្នាក់ទៀត ចូលទៅអង្គុយលេងលើគ្រែខាងក្រោមផ្ទះ ។ ទិដ្ឋភាពនៅជុំវិញផ្ទះរបស់គាត់នាពេលនោះ មានសភាពស្ងប់ស្ងាត់ ដោយកូនៗរបស់គាត់បានទៅសាលារៀន ចំណែកប្រពន្ធរបស់គាត់បានដឹកគោទៅឲ្យស៊ីស្មៅនៅចម្ការ ។ គាត់បានជជែកលេងជាមួយខ្ញុំពីរឿងរ៉ាវផ្សេងៗ ។ ខ្ញុំក៏បានសួរនាំគាត់ពីឆាកជីវិតដែលគាត់ធ្លាប់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហម ។ ស្ថិតនៅក្នុងភាពស្ងៀមស្ងាត់មួយសន្ទុះ គាត់ក៏បាននិយាយពីប្រវត្តិរបស់គាត់ដែលធ្លាប់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហមដូចខាងក្រោម ៖



ចាន់ ដាំ ក្រុមប្រឹក្សាឃុំថាឡាបរិវ៉ាត់ បានមានប្រសាសន៍ទៅកាន់ប្រជាពលរដ្ឋឲ្យចូលរួមស្តាប់ និងទស្សនាការប្រកាសលាលដីកាស្ថាពររបស់អង្គជំនុំជម្រះតុលាការកំពូលទាក់ទងសំណុំរឿង ០០២វគ្គ១ ដែលមានជនជាប់ចោទ នួន ជា និង ខៀវ សំផន កាលពីខែវិច្ឆិកា ឆ្នាំ២០១៦

## អំពីប្រវត្តិសកម្មភាព និងក្រុមគ្រួសារ

គាត់មានឈ្មោះ ចាន់ ដាំ សព្វថ្ងៃធ្វើជាក្រុមប្រឹក្សាឃុំថាឡាបរិវ៉ាត់ ។ ដាំ មានស្រុកកំណើតនៅភូមិថាឡាបរិវ៉ាត់ ឃុំថាឡាបរិវ៉ាត់ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ហើយបច្ចុប្បន្នរស់នៅក្នុងភូមិឃុំស្រុកកំណើតដដែលជាមួយប្រពន្ធឈ្មោះ យូ ផាន ប្រកបរបរធ្វើស្រែចម្ការ និងមានកូនប្រុសស្រី៧នាក់ ។ ដាំ មានបងប្អូនចំនួន៧នាក់ (ប្រុស៤ ស្រី៣) ។ ឪពុកឈ្មោះ ទិត ចាន់ ជាទាហានជំនាន់សម្តេចសីហនុ ។ គាត់បានឲ្យដឹងថា ឪពុកម្តាយ និងប្អូនៗបួននាក់ទៀត បានបាត់ខ្លួនតាំងពីឆ្នាំ១៩៧០ រហូតមកដល់បច្ចុប្បន្ន ដោយមិនដឹងថារស់ ឬក៏ស្លាប់ទេ ។

មុនឆ្នាំ១៩៧០ ដាំ បានចាកចេញពីគ្រួសារទៅបួសជាណេនបានបីវស្សា និងបានបន្តបួសជាសង្ឃបានពីរវស្សាថែមទៀតនៅវត្តថាឡាបរិវ៉ាត់ ។ ក្រោយពីលាចាកសិក្ខាបទ ក្នុងអំឡុងឆ្នាំ១៩៧២-៧៣ ដាំ បានចូលធ្វើយោធាខ្មែរក្រហម នៅភូមិថាឡាបរិវ៉ាត់ ដោយមាន

ឈ្មោះ ផល ជាកម្មាភិបាលខ្មែរក្រហមក្នុងភូមិជាអ្នកនាំចូល ។ កាលនោះអង្គភាពរបស់ ដាំ មានសមាជិកដែលជាយុទ្ធជនទើបស្ម័គ្រចិត្តចំនួន៣០នាក់ប៉ុណ្ណោះ ហើយអ្នកទាំងអស់គ្នាត្រូវបានអង្គការចាត់ឲ្យទៅភ្នំជី ក្នុងខេត្តកំពង់ធំ ដើម្បីហ្វឹកហ្វឺនក្បួនយុទ្ធសាស្ត្រយោធា ដែលមានអ្នកគ្រប់គ្រងអង្គភាពផ្ទាល់ឈ្មោះ ប៉ង់ (ប៉ង់ជាអ្នកមកពីខេត្តកំពង់ធំ) ។ បន្ទាប់ពីហាត់ក្បួនយុទ្ធសាស្ត្រយោធាអស់រយៈពេលបីខែ អង្គការបានតម្រូវឲ្យយុទ្ធជននៅក្នុងអង្គភាពទាំងអស់ ធ្វើប្រវត្តិរូបរបស់ខ្លួនឡើងវិញ ។ នៅពេលនោះ ដាំ ក៏ត្រូវធ្វើប្រវត្តិរូបដែរ តែដោយសារ ដាំ មានប្រវត្តិរូបជាប់និន្នាការដែលឪពុករបស់គាត់ធ្លាប់ធ្វើជាទាហានក្នុងរបបសម្តេចព្រះនរោត្តម សីហនុ ហេតុដូច្នេះ អង្គការបានបញ្ឈប់ដាំ ពីអង្គភាពយោធា ហើយបញ្ជូន ដាំ ឲ្យមកធ្វើការងារនៅក្នុងតំបន់១០៣ ព្រះវិហារវិញ គឺនៅល្ហុងដើម្បីជួយជាកម្លាំងក្នុងការលើកដាក់សម្ភារខាងពាណិជ្ជកម្មរបស់តំបន់១០៣ ។

## ការជម្លៀស

ក្រោយពេលខ្មែរក្រហមរំដោះប្រទេសកម្ពុជាបានទាំងស្រុងនៅឆ្នាំ១៩៧៥ អង្គការបានចាត់ដាំ ឲ្យទៅធ្វើការនៅអង្គភាពពាណិជ្ជកម្មកំពង់ចាម ដោយរក្សាការងារនៅដដែលគឺ ខាងដឹកជញ្ជូន និងជួយជាកម្លាំងលើកដាក់សម្ភារក្នុងអង្គភាព ។ ចំណែកក្រុមគ្រួសាររបស់ ដាំ និងប្រជាជនដែលរស់នៅឯស្រុកកំណើត ត្រូវបានខ្មែរក្រហមជម្លៀសចេញពីភូមិឲ្យទៅរស់នៅតាមតំបន់នានា ដូចជាជាំក្សាន្ត, បាច និងស្រែគ្នោត ។ ដាំ បានបន្តថា នៅស្រែគ្នោត កាលពីដើមឡើយ នៅតាមបណ្តោយផ្លូវជាតិមិនមានភូមិដ្ឋានប្រជាជនរស់នៅទេ តែពេលនោះខ្មែរក្រហមបានបង្កើតជាភូមិដ្ឋាន និងបានសាងសង់ផ្ទះតាមបណ្តោយផ្លូវជាតិ ដើម្បីឲ្យប្រជាជនរស់នៅ ។ បងម្នាក់ និងប្អូនម្នាក់របស់ ដាំ ត្រូវបានអង្គការជម្លៀសឲ្យទៅរស់នៅជាំក្សាន្ត ដែលជាការដ្ឋានសម្រាប់លត់ដំអ្នកដែលជាប់និន្នាការសង្គមចាស់ ។ រីឯឪពុកម្តាយ និងប្អូនៗបួននាក់ទៀតរបស់ ដាំ បានបាត់ដំណឹងសូន្យឈឹងចាប់តាំងពីឆ្នាំ១៩៧០មក ។

## អង្គភាពប-៣១

ក្រោយពីអង្គការចាត់តាំងឲ្យទៅធ្វើការនៅអង្គភាពពាណិជ្ជកម្មកំពង់ចាមមួយរយៈ ដាំ ត្រូវបានផ្លាស់ទៅនៅក្នុងកងចល័ត លើកទំនប់ ជីកប្រឡាយនៅការដ្ឋាន អូតាលូក (នៅល្ហុង) ក្នុងអង្គភាពប-៣១ (ប-៣១ ជាការដ្ឋានរបស់តំបន់១០៣) ដែលអ្នកគ្រប់គ្រងមានឈ្មោះ តាជា ជាប្រធាន និងតាសេត ជាអនុប្រធាន ។ ការងារនៅអង្គភាពប-៣១ គឺធ្វើការទាំងយប់ទាំងថ្ងៃ ពេលព្រឹកចុះធ្វើការនៅម៉ោង៧ដល់ម៉ោង១១ ឈប់សម្រាកហូបបាយថ្ងៃត្រង់ ។ លុះដល់ម៉ោង១ ចាប់ផ្តើមចុះធ្វើការបន្តទៀតរហូតដល់ម៉ោង៥ល្ងាច ។ បន្ទាប់ពីឈប់សម្រាក់ហូបបាយពេលល្ងាចរួច នៅម៉ោង៦កន្លះយប់ ត្រូវចុះធ្វើការបន្តទៀតរហូតដល់ម៉ោង១១យប់ ។ រីឯការហូបចុកវិញ ដាំ បានឲ្យដឹងថា ក្នុងមួយថ្ងៃអង្គការឲ្យហូបពីរពេល គឺថ្ងៃត្រង់ និងពេលល្ងាច ។ នៅពេលដែលខ្ញុំសួរថា តើអង្គការឲ្យហូបឆ្អែតទេ ដាំ បានឆ្លើយតបជាមួយនឹងសំណើចថា «អត់មានឲ្យហូបឆ្អែតទេ! ដោយសារការហូបមិនឆ្អែតនេះហើយ អ្នកខ្លះដែលកាប់ដីដាក់បង្គី ដួនកាលទាញចបមកក៏ដួលត្រឡប់ត្រឡិនក៏មាន ដោយសារខ្សោយកម្លាំង ។ អ្នកខ្លះត្រូវបានអង្គការគំរាមកំហែងផង និងចាប់យកទៅកសាងក៏មាន (យកទៅសម្លាប់) ពិបាកណាស់នៅកន្លែងការដ្ឋានហ្នឹង» ។ ពេលឈឺម្តងៗពេទ្យបានចែកថ្នាំអាចម៍ទន្សាយឲ្យលេប បើមានអ្នកជំងឺឈឺធ្ងន់ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យដើម្បីព្យាបាល តែការព្យាបាលក៏មិនមានប្រសិទ្ធភាពប៉ុន្មានដែរ ។ អ្នកជំងឺភាគច្រើន កើតជំងឺរាករូសព្រោះមិនមានអាហារហូបចុកគ្រប់គ្រាន់ ហើយថែមទាំងខ្វះអនាម័យក្នុងការរស់នៅផង ។

## អាពាហ៍ពិពាហ៍

នៅឆ្នាំ១៩៧៦ ដាំ ត្រូវបានអង្គការរៀបចំឲ្យមានគ្រួសារ ។ ជាទូទៅក្នុងពិធីមង្គលការក្នុងរបបខ្មែរក្រហម អង្គការមិនអនុញ្ញាតឲ្យឪពុកម្តាយ បងប្អូន ឬសាច់ញាតិរបស់កូនកម្លោះ កូនក្រមុំចូលរួមក្នុងកម្មវិធីឡើយ ។ ការរៀបការម្តងៗ គឺមានកូនកម្លោះ និងកូនក្រមុំ ចាប់ពីម្ភៃទៅសាមសិបគូ និងអាចលើសពីនេះ ។ តែដោយឡែក ដាំ បានឲ្យដឹងថា ក្នុងការរៀបការរបស់គាត់ គឺមានតែបីគូប៉ុណ្ណោះ ។ ការរៀបមង្គលការនេះ ដំបូង អង្គការបានហៅយុវជន និងយុវនារីនៅការដ្ឋានឲ្យមកជួបជុំគ្នា ហើយបានធ្វើការប្រកាសប្រាប់ពីការរៀបចំពិធីអាពាហ៍ពិពាហ៍ ។ បន្ទាប់មក អង្គការបានហៅឈ្មោះកូនកម្លោះ និងកូនក្រមុំដែលជាគូនឹងគ្នាឲ្យអង្គុយលើកៅអីទល់មុខគ្នា ។

បន្ទាប់មកទៀត អ្នកដឹកនាំកម្មវិធីបានឡើងមានមតិណែនាំ ដោយអប់រំគូស្រករថ្មី ឲ្យប្រឹងប្រែងកសាងគ្រួសារ ខិតខំធ្វើការបម្រើអង្គការ ហើយត្រូវចេះលះបង់កម្មសិទ្ធិស្វួនតួឲ្យអស់ ។ ខណៈនោះ អង្គការបានឲ្យគូស្រករថ្មីទាំងអស់ឡើងធ្វើការប្ដេជ្ញាចិត្ត ។ ការប្ដេជ្ញាចិត្ត គឺគ្មាននិយាយអ្វីក្រៅពីការខិតខំបំពេញការងារជូនអង្គការ មិនត្រូវផ្ដេកផ្ដួលពឹងលើប្ដី ឬប្រពន្ធឡើយ ចៀសវាងកុំឲ្យមានកម្មសិទ្ធិស្វួនតួ និងប្ដេជ្ញាបម្រើបក្ស បម្រើប្រជាជនឲ្យអស់ពីចិត្តពីថ្លើម ។ បន្ទាប់ពីប្ដេជ្ញាចិត្តរួចរាល់ហើយ ក៏មានពិធីជប់លៀងបន្តិចបន្តួច ដើម្បីជាកិច្ចបញ្ចប់កម្មវិធី ។

## គុកព្រៃប្រស់

ក្រោយមក មានការផ្លាស់ប្ដូរគណៈតំបន់ (ប្រហែលឆ្នាំ១៩៧៨) ថ្នាក់ដឹកនាំអង្គភាពប-៣១ រួមនឹងសមាជិកដែលធ្វើការនៅក្នុងអង្គភាពប-៣១ ទាំងអស់ត្រូវបានអង្គការចោទថា "ក្បត់នឹងបដិវត្តន៍" រួចចាប់ខ្លួនបញ្ជូនទៅដាក់នៅវត្តព្រៃប្រស់ (គុកព្រៃប្រស់) ក្នុងស្រុកស្ទោង ដែលជាទីកន្លែងឃុំឃាំងអ្នកទោសគ្រប់សមាសភាព ។ អ្នកទោសដែលអង្គការយកទៅដាក់នៅទីនោះ មានទាំងអ្នកមូលដ្ឋាន មានទាំងអ្នក១៧មេសា អ្នកជាប់ពាក់ព័ន្ធនិន្នាការនយោបាយ ឬក៏តំបន់ណាមួយដែលអង្គការយល់ថា ជាក្រុមក្បត់ដូចជានៅតំបន់ព្រះវិហារជាដើម ។ ដាំ និងប្រពន្ធ ក៏មានវាសនាមិនខុសពីអ្នកនៅក្នុងអង្គភាពប-៣១ ប៉ុន្មានដែរ គឺត្រូវបានអង្គការចាប់យកទៅដាក់នៅមន្ទីរឃុំឃាំងព្រៃប្រស់ អស់រយៈពេលប្រាំពីរខែ ដោយមិនទាំងបានដឹងថា ខ្លួនបានធ្វើអ្វីខុសចំពោះអង្គការបដិវត្តន៍ផង ។ អ្នកទោសទាំងអស់ ត្រូវបានអង្គការឲ្យធ្វើស្រែ លើកទំនប់ និងជីកប្រឡាយរៀងរាល់ថ្ងៃ តែមិនបានវាយធ្វើបាប ឬធ្វើទារុណកម្មទេ ។ នៅខែវស្សា ពេលទឹកឡើងម្ដងៗ ពេលទំនប់ធ្លាយ ឬដាច់ អង្គការតែងតែប្រើអ្នកទោសកាយអាចម៍ដីទៅទប់ត្រង់កន្លែងដែលធ្លាយ ទំរាំតែជីកយកអាចម៍ដីមកប៉ះទំនប់បាន ពិតជាវេទនាខ្លាំងណាស់ ។

អ្នកទោសនៅគុកព្រៃប្រស់ បានស្លាប់ជាបន្តបន្ទាប់ ដោយសារការអត់អាហារ, ខ្សោយកម្លាំង, ឈឺគ្មានថ្នាំព្យាបាល និងការសម្លាប់ ។ ដាំ បានឲ្យដឹងថា គុកព្រៃប្រស់នេះបានសម្លាប់អ្នកទោសរហូតដល់រាប់ពាន់នាក់ ។ ក្នុងចំណោមអ្នកទោសមួយរយនាក់ មានបុរសយ៉ាងច្រើនម្ភៃនាក់ប៉ុណ្ណោះ ។ ស្ត្រីខ្លះត្រូវក្លាយខ្លួនជាស្ត្រីមេម៉ាយ ដោយអង្គការយកប្ដីរបស់គាត់ទៅសម្លាប់ ។ អ្នកទោសត្រូវបានអង្គការយកទៅសម្លាប់ស្ទើររាល់ថ្ងៃ ។ ដាំ មិនធ្លាប់ឃើញខ្មែរក្រហមសម្លាប់មនុស្សដោយផ្ទាល់ភ្នែកទេ តែគាត់ដឹងថា របបនេះមានការកាប់សម្លាប់មនុស្ស ព្រោះធ្លាប់ឃើញខ្មែរក្រហមបញ្ជូនអ្នកទោសតាមឡានយកទៅដាក់នៅគុកដំដែក ក្នុងខេត្តសៀមរាប និងគុកព្រៃប្រស់ ក្នុងខេត្តកំពង់ធំ ។

## ផែនការសម្លាប់

ក្រោយមកទៀត ដាំ និងប្រពន្ធ រួមជាមួយអ្នកទោសផ្សេងទៀត ប្រហែល១៥គ្រួសារ ត្រូវបានអង្គការដាក់ផែនការបម្រុងយកមកសម្លាប់ចោលនៅស្ពានតូច ជាប់ផ្លូវជាតិលេខ៦ ក្នុងស្រុកស្ទោង ខេត្តកំពង់ធំ (ក្នុងរបបខ្មែរក្រហមហៅភូមិស្ពានតូច) ។ ពេលនោះ ដោយសារមិនទាន់ដល់ថ្ងៃដែលត្រូវអង្គការសម្លាប់ ដាំ និងប្រពន្ធ និងប្រជាជន១៥គ្រួសារទៀត ត្រូវបានអង្គការយកទៅផ្ញើទុកនៅសហករណ៍ភូមិស្ពានតូចសិន ។ ដាំ បានឲ្យដឹងថា ការរស់នៅរបស់ពួកគាត់ក្នុងភូមិស្ពានតូចមួយរយៈពេលខ្លី តែត្រូវបានសហករណ៍ និងប្រជាជននៅទីនោះជួយទំនុកបម្រុងឲ្យហូបចុកគ្រប់គ្រាន់ ។ ដោយមានការអាណិតអាសូរពីអ្នកភូមិស្ពានតូច ប្រជាជនក្នុងភូមិបានមកខ្សឹបប្រាប់គាត់ថា "ក្មួយៗឆាប់រត់ពួនទៅ គេ (ខ្មែរក្រហម) បម្រុងយកក្រុមក្មួយទៅសម្លាប់ចោលហើយ!" ។ បន្ទាប់មក អ្នកភូមិ បាននាំ ដាំ និងប្រពន្ធ និងគ្រួសារផ្សេងៗទៀត ដែលមកជាមួយគ្នា យកទៅលាក់ក្នុងពំនូកចំបើងកន្លែងបញ្ជាន់ស្រូវ និងបានផ្ដល់ជាអាហារឲ្យហូបចុក ។ ស្របពេលនោះ ក៏មានវត្តមានកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា រួមសហការជាមួយកងទ័ពវៀតណាម បានវាយចូលមក ។ ដាំ និងប្រជាជនឯទៀតក៏បានរួចខ្លួនពីសេចក្ដីស្លាប់តាំងពីពេលនោះមក ។

## ការរស់នៅជួបជុំបងប្អូនក្នុងជីវិតថ្មី

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំទាំងស្រុង ដាំ និងភរិយា បានធ្វើដំណើរវិលត្រឡប់មកស្រុកកំណើតវិញ ដោយថ្មើរជើងអស់រយៈពេលកន្លះខែ ។ ពេលមកដល់ភូមិដែល ដាំ ធ្លាប់រស់នៅកាលពីមុនសម័យខ្មែរក្រហម បានក្លាយទៅជាព្រៃរហោឋាន មានសភាពស្ងាត់ជ្រងំគួរឲ្យសង្វេគ សូម្បីផ្ទះដែលធ្លាប់ជ្រកកោន ក៏ត្រូវ



ចាន់ ដាំ ក្រុមប្រឹក្សាឃុំថាវឡាបរិវ៉ាត់ ក្នុងអំឡុងពេលស្តាប់ និងទស្សនាការប្រកាសសាលដីកាសាលាដំបូងលើ... 

ខ្មែរក្រហមរុះរើ បំផ្លាញខ្ទេចខ្ទីគ្មានសល់ ។ ដាំ ក៏ដូចជាប្រជាជនដទៃទៀត បាននាំគ្នាកាប់ឆ្ការព្រៃ រៀបចំសាងសង់ផ្ទះសម្បែងទៅតាមលទ្ធភាពរៀងខ្លួនឡើងវិញ ។ ក្នុងពេលនោះ ដាំ បានជួបបងស្រី និងប្អូនស្រីរបស់គាត់ ហើយបានបន្តមុខរបរធ្វើស្រែដើម្បីចិញ្ចឹមជីវិត ។ ចំណែក ឪពុកម្តាយ និងប្អូនៗប្អូននាក់ទៀត នៅតែបាត់ដំណឹងដដែល ។ ដាំ បានគិតក្នុងចិត្តថា ឪពុកម្តាយ និងប្អូនៗទាំងប្អូនរបស់គាត់ប្រាកដជាស្លាប់ហើយ ។

ដាំ បានប្រាប់ឲ្យដឹងទៀតថា កាលចូលមករស់នៅក្នុងភូមិដំបូង ប្រជាជនមិនទាន់មានដីសម្រាប់ធ្វើចម្ការទេ ព្រោះនៅក្បែរៗភូមិសុទ្ធសឹងជាព្រៃ ហើយយោធាខ្មែរក្រហម បានស្នាក់អាស្រ័យនៅក្នុងព្រៃនោះ ។ រហូតដល់ពេលដែលខ្មែរក្រហមធ្វើសមាហរណកម្មចុះចូលជាមួយរដ្ឋាភិបាលក្នុងឆ្នាំ១៩៩៨ ទើបប្រជាជននាំគ្នាទៅកាប់ឆ្ការព្រៃយកដីធ្វើចម្ការដាំដំណាំផ្សេងៗ ។

ដាំ តែងនិយាយរំឭករឿងរ៉ាវជីវិតដែលគាត់ធ្លាប់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហម ប្រាប់ដល់កូនៗរបស់គាត់ជានិច្ច ។ ជាចុងក្រោយ ដាំ បានបញ្ជាក់ថា ដោយសាររបបខ្មែរក្រហមជារបបឃោរឃៅ មានការកាប់សម្លាប់ប្រជាជន ហេតុនេះ គាត់មិនគាំទ្ររបបនេះទេ ហើយក៏មិនចង់ឲ្យរបបនេះកើតមានជាលើកទីពីរនៅក្នុងប្រទេសកម្ពុជាទៀតដែរ ហើយការណ៍ដែលអង្គជំនុំជម្រះតុលាការកំពូល បានសម្រេចតម្កល់ទោសមេដឹកខ្មែរក្រហម នួន ជា និង ខៀវ សំផន ឲ្យនៅជាប់គុកអស់មួយជីវិតនោះ ជាការត្រឹមត្រូវ ។ ក្នុងនាមគាត់ជាជនរងគ្រោះម្នាក់ដោយសាររបបមួយនេះ គាត់ពេញចិត្ត ហើយអាចទទួលយកបានចំពោះការសម្រេចរបស់តុលាការ ។

ចំពោះ ដាំ ផ្ទាល់ គាត់មិនចង់ឃើញប្រទេសមានសង្គ្រាមទេ ព្រោះសង្គ្រាមបានបំផ្លាញអ្វីៗសព្វបែបយ៉ាង សម្លាប់ជីវិតមនុស្ស ធ្វើឲ្យខូចខាតផ្ទះសម្បែង បាត់បង់ទ្រព្យសម្បត្តិ ព្រាត់ប្រាស់គ្រួសារ បងប្អូន ឪពុកម្តាយ ជីដូនជីតា និងសាច់ញាតិ ។ ជាក់ស្តែងរហូតមកដល់សព្វថ្ងៃនេះ ដាំ បានបាត់បង់សមាជិកក្នុងគ្រួសារចំនួនប្រាំមួយនាក់ ។ **ឆេង ទើង**

# ក្លាយជាអ្នកទោសដោយសារតែការសង្ស័យ

## *ពីមន្ទីរឃុំឃាំងទៅទឹកដីសេរីភាព*

*ហ៊ូ កុសល បានឆ្លងកាត់រឿងរ៉ាវជាច្រើននៅក្នុងរបបខ្មែរក្រហម ។ គាត់ត្រូវបានយោធាខ្មែរក្រហមចាប់ខ្លួនឃុំឃាំងអស់រយៈពេលជាច្រើនថ្ងៃដោយសារតែការចោទប្រកាន់ខុស ។ កុសល បានភៀសខ្លួនទៅជំរំជនភៀសខ្លួន ហើយចុងក្រោយគាត់បានទៅរស់នៅប្រទេសអាមេរិក នៅចុងឆ្នាំ១៩៧៩ ។*

*នៅពេលថ្មីៗនេះ កុលស បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ និងបានមកស្វែងរកឯកសារ ពីរបបខ្មែរក្រហមនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយគាត់ក៏បានរៀបរាប់ពីជីវិតផ្ទាល់ខ្លួនប្រាប់ដល់បុគ្គលិកទស្សនាវដ្តីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជាថា ៖*

*គាត់កើតនៅឆ្នាំ១៩៣៧ នៅភូមិព្រៃឈរ ឃុំអាគ្រាជ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។ គាត់មានបងប្អូនបីនាក់ ហើយគាត់ជាកូនទីពីរក្នុងគ្រួសារ ។ គាត់មានឪពុកឈ្មោះ ហ៊ូ ប៊ុត និងម្តាយឈ្មោះ គឹម ស៊ីង ។ ដោយសារតែឪពុករបស់គាត់ជាទាហានបារាំងនៅសម័យនោះដូច្នេះគាត់ត្រូវ ផ្លាស់ទៅរស់នៅតាមឪពុកជាច្រើនកន្លែង ដូចជា នៅខេត្តស្ទឹងត្រែង ក្រចេះ និងខេត្តកំពង់ចាម រហូត*



*ហ៊ូ កុសល បច្ចុប្បន្នរស់នៅប្រទេសអាមេរិក បានមកស្រាវជ្រាវឯកសារពីរបបខ្មែរក្រហមនៅមជ្ឈមណ្ឌលឯកសារកម្ពុជា និងបានផ្តល់បទសម្ភាសន៍ពីជីវិតរបស់គាត់ដែលបានឆ្លងកាត់របបនេះប្រាប់ដល់ក្រុមការងារទស្សនាវដ្ដីស្វែងរកការពិត*

ដល់ឪពុករបស់គាត់ស្លាប់នៅឆ្នាំ១៩៥២ ដោយសាររងរបួសនៅពេលឡើងទៅប្រយុទ្ធជាមួយក្រុមឥស្សរៈ នៅសមរភូមិកំពង់ថ្ម ។ បន្ទាប់ពីឪពុកស្លាប់ គាត់ និងម្តាយ បានទៅរស់នៅជាមួយបងស្រីដែលមានប្តីជាទាហាននៅខេត្តបាត់ដំបង ។ នៅទីនោះ គាត់បានចូលរៀននៅវិទ្យាល័យព្រះមុនីវង្ស រហូតដល់ថ្នាក់ឌីប្លូម ហើយក្រៅពីរៀនគាត់ក៏ជាកីឡាទាត់បាល់ឆ្នើមដែរ ។ ក្រោយមក ដោយសារបងស្រីត្រូវផ្លាស់ទៅរស់នៅតាមប្តីនៅខេត្តក្រចេះ (ឆ្នាំ១៩៥៩) និងគ្មានអ្នកជួយទំនុកបម្រុងបន្ត ទើបគាត់សម្រេចចិត្តឈប់រៀន ។ បន្ទាប់មកពីឈប់រៀនគាត់បានចូលធ្វើការងារជាច្រើនកន្លែង ដូចជា នៅក្រុមហ៊ុនអេសកាដេ នៅខាងត្រាវ៉ូ និងធ្វើជាប៉ូលីសដើម្បីទទួលបានកន្លែងស្នាក់នៅ និងអាហារហូប ។

## កម្មករនៅប៉ៃលិន

នៅខែមករា ឆ្នាំ១៩៦៥ គាត់បានចាកចេញពីខេត្តបាត់ដំបង ទៅធ្វើជាកម្មករជីកត្បូងនៅ ខេត្តប៉ៃលិនវិញ ។ ពេលទៅដល់ដំបូង កុសល សង្កេតឃើញមានប្រជាជនប្រមាណជាង៥ម៉ឺននាក់ប៉ុណ្ណោះរស់នៅទីនោះ រួមទាំងជនជាតិកូឡា ។ កុសល បានឲ្យដឹងថា ប្រជាជនដែលទៅរស់នៅខេត្តប៉ៃលិនសម័យនោះ ខ្លះជាអ្នកដែលទើបរួចចេញពីគុក ខ្លះជាចោរលួច ឆក់ប្លន់ និងអ្នកដែលជំពាក់លុយគេ ព្រោះប៉ៃលិនជាតំបន់សម្បូរព្រៃឈើងាយស្រួលលាក់ខ្លួន និងមានជំងឺគ្រុនចាញ់កម្រមានមនុស្សចូលទៅដល់ ។ ប៉ុន្តែប្រជាជនដែលបានទៅដល់ និងរស់នៅខេត្តប៉ៃលិនសម័យនោះ ស្ទើរទាំងអស់មានជីវភាពធូរធា និងរស់នៅមានសេចក្តីសុខ ព្រោះជាតំបន់ដែលងាយស្រួលរកប្រាក់ដែលបានមកពីការជីកត្បូងយកទៅលក់ឲ្យថៅកែថៃ និងថៅកែចិន ដូច្នេះជនទិលខូចក៏ឈប់ប្រព្រឹត្តអំពើខុសច្បាប់ដែរ ។ ប្រជាជននៅប៉ៃលិនមានម៉ូតូជិះស្ទើរគ្រប់គ្នា និងមិនបារម្ភខ្លាចចោរលួច ប្លន់ឆក់ប្លន់ឡើយ ។

## កុងសៃត្បូង

នៅអំឡុងពេលនោះ កុសល បានឈប់ធ្វើជាកម្មករ ដោយប្តូរមករកស៊ីជីកត្បូងដោយខ្លួន ឯងរហូតក្លាយជាកុងសៃទិញត្បូងនៅខេត្តប៉ៃលិន ។ ដោយសារគាត់ជាអ្នកជំនួញ និងមានជីវភាពធូរធា ដូច្នេះគាត់មានការប្រាស្រ័យទាក់ទងច្រើនជាមួយកម្មករជីកត្បូង ប្រជាជន និងមន្ត្រីនៅក្នុងខេត្តប៉ៃលិនទាំងមូល ។ គាត់រស់នៅប៉ៃលិនរហូតទីក្រុងភ្នំពេញរំដោះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ តែទោះបីយ៉ាងណា ប្រជាជននៅខេត្តប៉ៃលិនមិនមានភាពច្របូលច្របល់ទេ គឺអ្នកទាំងនោះបានដើររកខ្មែរក្រហមរហូតដល់ព្រំដែនដើម្បីមកគ្រប់គ្រងជំនួសឲ្យរបបសាធារណរដ្ឋខ្មែរវិញ ។

## ថ្ងៃដំបូងរបស់ខ្មែរក្រហម

មួយថ្ងៃក្រោយមក គឺថ្ងៃទី១៨ ម៉ោង៥ល្ងាច យោធាខ្មែរក្រហមប្រមាណ២០នាក់ដឹកនាំគណៈសមរភូមិឈ្មោះ សម្រេច (សម្រេច មានឪពុកជាអតីតទាហានដូចឪពុកគាត់ដែរ និងធ្លាប់ស្គាល់គាត់ពីមុនមក) បានទៅដល់ខេត្តប៉ៃលិន ដែលពេលនោះមានគណៈកម្មាធិការឃោសនាការ (គាត់ជាសមាជិក) និងគណៈកម្មាធិការទទួលបដិសណ្ឋារកិច្ចខ្មែរក្រហមដែលទើបបង្កើតថ្មី រួមទាំងមន្ត្រីរដ្ឋការនៅក្នុងរបបសាធារណរដ្ឋខ្មែរ និងប្រជាជនបានរង់ចាំទទួលរួចជាស្រេចចាប់ពីវត្តកោងកាង រហូតដល់ផ្សារ (បច្ចុប្បន្នសួនច្បារខេត្តប៉ៃលិន) ។

ពេលទៅដល់ដំបូង យោធាខ្មែរក្រហមបានប្រកាសពីការទទួលបានសន្តិភាព និងការបរាជ័យរបស់កងទ័ព និងរបប លន់ នល់ ។ យោធាខ្មែរក្រហមបានឃោសនាប្រាប់ប្រជាជនកុំឲ្យមានការភ័យបារម្ភ និងត្រូវយកកាំភ្លើងដែលលាក់ទុកកាលពីសម័យ លន់ នល់ មកប្រគល់ឲ្យខ្លួន ។

នៅថ្ងៃបន្ទាប់ ខ្មែរក្រហមប្រកាសប្រាប់អាជីវករលក់ដូរនៅក្នុងផ្សារខេត្តប៉ៃលិន ឲ្យលក់សាច់ជ្រូកក្នុងមួយគីឡូពីររយរៀល (ពេលយោធាខ្មែរក្រហមទទួលជ័យជម្នះភ្លាមៗ នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជននៅក្នុងខេត្តប៉ៃលិននៅចាយលុយនៅឡើយ) ។ ប៉ុន្តែ ត្រូវបានអាជីវករចិនដែលលក់សាច់ជ្រូកក្នុងផ្សារបដិសេធ ព្រោះតម្លៃថោកពេក ដូច្នេះខ្មែរក្រហមក៏បាញ់សម្លាប់អាជីវករនោះនៅនឹងកន្លែងតែម្តង ។

នៅអំឡុងពេលនោះដែរ គណៈសមរភូមិឈ្មោះ សម្រេច ក៏បានចូលមកផ្ទះរបស់ កុសល និង បានស្នើលុយមួយចំនួន ព្រោះគាត់ធ្លាប់មានឈ្មោះ និងមានបណ្ណសមាជិកបក្សជនចូលរួមបង់វិភាគទានខបត្តម្ភដល់ចលនាបដិវត្តន៍ខ្មែរក្រហម ។ សម្រេច ក៏បានប្រាប់ កុសល ថា ឈ្មោះរបស់គាត់មាននៅក្នុងបញ្ជីខ្មែរក្រហមហើយ

ដូច្នេះឲ្យគាត់ត្រៀមរៀបចំអីវ៉ាន់ឲ្យហើយ ។

**ពេលជម្លៀសនៅខេត្តប៉ៃលិន**

នៅវេលាម៉ោង៤ល្ងាច ថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៥ កុសល រួមជាមួយប្រពន្ធ និងកូនម្នាក់បានធ្វើដំណើរតាមរទេះគោចេញពីទីរួមខេត្តប៉ៃលិន ។ បន្ទាប់ចេញផុតពីផ្ទះបន្តិច ប្រជាជនដែលធ្លាប់ស្គាល់បានមកប្រាប់គាត់ថា យោធាខ្មែរក្រហមបានទៅព័ទ្ធផ្ទះរបស់គាត់ ។ ខណៈនោះ គាត់ក៏បានទទួលដំណឹងថា អ្នកដែលមានឈ្មោះនៅគណៈកម្មាធិការឃោសនា និងរៀបចំទទួលខ្មែរក្រហម ស្ទើរទាំងអស់ត្រូវបានសម្លាប់ ។

នៅថ្ងៃជម្លៀសនោះ ក្រុមគ្រួសារ កុសល ធ្វើដំណើររយៈពេលបួនម៉ោងបានចម្ងាយតែបួនគីឡូប៉ុណ្ណោះ ព្រោះមានប្រជាជនណែនណាន់តាន់តាប់នៅលើផ្លូវ ។ គាត់បាននាំប្រពន្ធកូនទៅស្នាក់កំពង់គល់បានមួយរយៈ ក៏ផ្លាស់ទៅធ្វើខ្ទមស្នាក់នៅព្រៃស្វាយ ។ ក្រោយមក ខ្មែរក្រហមបានជម្លៀសបន្ត ទើបគាត់ធ្វើដំណើរមកនៅសហករណ៍កាពោខាងជើង (ភ្នំសំពៅ) តំបន់៣ ភូមិភាគពាយ័ព្យ ។

**សហករណ៍កាពោខាងជើង**

ទៅដល់ដំបូង គាត់បានប្រែឈ្មោះដើមរបស់គាត់ពី ហ៊ួ កុសល ទៅជាមិត្ត ចាន់ ។ នៅទីនោះ ខ្មែរក្រហមចាត់តាំង កុសល (មិត្តចាន់) ឲ្យទៅនៅខាងផ្នែកចុងភៅ ដាំបាយសម្រាប់សហករណ៍កាពោខាងជើង ។ ប៉ុន្តែដោយសារគាត់មិនចេះធ្វើម្ហូប ទើបគាត់បានជ្រើសរើសយាយ ឃឿន (អតីតចុងភៅនៅតាមរោងការពីសង្គមចាស់) មកធ្វើការជាមួយគាត់ ។ នៅឆ្នាំ១៩៧៦ កម្មាភិបាលតំបន់បានចុះមកសហករណ៍កាពោខាងជើង ដូច្នេះ គាត់ក៏រៀបចំ និងចាត់តាំងយាយ ឃឿន ឲ្យធ្វើឈ្លូសដែលយោធាខ្មែរក្រហមយកប្រគល់ឲ្យដើម្បីធ្វើម្ហូបទទួលភ្ញៀវ ។ មុនពេលកម្មាភិបាលតំបន់ទាំងនោះត្រឡប់ទៅវិញ ក៏បានប្រគល់បារីរូបសេកឲ្យគាត់មួយកេសធំទុកសម្រាប់ខាងចុងភៅជក់ តែគាត់យកតែ១០ដើមប៉ុណ្ណោះ រីឯបារីដែលនៅសល់ គាត់យកទៅចែកឲ្យយោធា និងអ្នកធ្វើការនៅតាមមន្ទីរផ្សេងៗជក់ ។

នៅទីនោះ ប្រពន្ធរបស់គាត់ដែលចេះដេរខោអាវ ត្រូវបានអង្គការចាត់ឲ្យដេរ និងប៉ះខោអាវ ឲ្យប្រជាជននៅសហករណ៍ទាំងមូល ចំណែកកូនរបស់គាត់ត្រូវបានអង្គការយកទៅដាក់នៅក្នុងកងកុមារ ។ ប៉ុន្តែដោយសារតែកូនរបស់គាត់ធ្លាប់រស់នៅស្រួលក្នុងគ្រួសារ មិនស៊ូរទ្រាំរស់នៅជុំក្នុងកង ទើបអង្គការចោទប្រកាន់កូនគាត់ថា ទមើស ។

ក្រៅពីការងារដាំបាយ គាត់ត្រូវបានអង្គការចាត់តាំងឲ្យធ្វើជាប្រធានទីសំណាប និងវាស់វែងដីសម្រាប់ប្រជាជនស្ទូង ។ ប៉ុន្តែដោយសារគាត់មិនចេះពីរបៀបធ្វើស្រែ ទើបគាត់លួចទៅសួរចាស់ទុំនៅទីនោះ ហើយតែងលួចយកសារុង ទៅដូរយកខ្សែក្រាត់ និងខ្សែតីដើម្បីទុកប្រើប្រាស់នៅក្នុងកង ។ ចំណែករបបអាហារពេលនោះ ប្រធានវររបស់គាត់តែងតែលួចចែករបបអង្ករសម្រូបឲ្យគាត់ក្នុងមួយថ្ងៃបីកំប៉ុងមកដាំបាយហូប ហើយប្រពន្ធរបស់គាត់ដែលចេះយកចិត្តប្រពន្ធគណៈស្រុកនៅទីនោះ ក៏តែងតែទទួលបានម្ហូបអាហារដែលនៅសេសសល់ពីគ្រួសាររបស់គណៈស្រុក យកមកហូបដែរ ។

ក្រោយមក ដោយសារឃើញគាត់ខិតខំប្រឹងប្រែងធ្វើការងារ ទើបយោធាចាត់តាំងឲ្យទៅវាស់ទំនប់ និងទៅដោះយកមនុស្សពេលដែលសហករណ៍ចាប់ខ្លួន ហើយថែមទាំងបានបើកខោអាវខ្មៅ កន្សែង និងស្បែកជើងឲ្យគាត់ស្លៀកពាក់ទៀតផង ។ នៅពេលចុះធ្វើការម្តងៗ គាត់តែងតែទទួលត្រី សាច់ពីយោធាយកមកចែកឲ្យគណៈឃុំ និងគណៈកងហូប ។

គាត់ធ្វើការនៅតំបន់៣ រហូតដល់ថ្ងៃ២០ ខែមករា ឆ្នាំ១៩៧៨ ក៏មានយោធាឃុំម្នាក់មកស្រែកហៅគាត់នៅសហករណ៍ថា "ពុកចាន់ៗ (សម័យនោះប្រជាជនហៅគាត់ថា ពុកចាន់) អង្គការហៅទៅដាំបាយឲ្យប្រជាជននៅកំពីងពួយ តែមិនចាំបាច់យករបស់របរទៅជាមួយទេ" ។ ព្រដូច្នេះ គាត់ក៏យកដំណឹងនេះទៅប្រាប់មេកង ចំណែកប្រពន្ធរបស់គាត់បានត្រឹមទទួលដំណឹងបន្តពីប្រជាជនក្នុងភូមិថាគាត់ទៅដាំបាយនៅកំពីងពួយប៉ុណ្ណោះ ព្រោះពេលនោះប្រពន្ធគាត់ត្រូវបានចាត់តាំងឲ្យទៅច្រូតស្រូវ និងត្រូវដេកនៅវាលស្រែ ។

**អ្នកទោសនៅឃ្លាំងអំបិល**

នៅពេលនោះ យោធាខ្មែរក្រហមមិនបានយកគាត់ទៅកន្លែងដាំបាយនៅកំពីងពួយទេ តែបែរជាយកទៅឃ្លាំងដាក់អំបិលរបស់សហករណ៍ នៅភ្នំសំពៅវិញ រួចហើយឲ្យគាត់ដោះសម្លៀក

បំពាក់ចេញទាំងអស់ ។ នៅពេលគាត់ដើរចូលទៅដល់ក្នុងឃ្លាំង គាត់ក៏ឃើញអ្នកទោសពីរនាក់ជាប់ខ្នោះ គឺ ប៊ុត ឈឿន (បច្ចុប្បន្នរស់នៅស្តុកតុនសហរដ្ឋអាមេរិក) និងឈ្មោះ ទេស ហៀច ទើបគាត់ដឹងថា យោធាខ្មែរក្រហមកុហកគាត់ ។ គាត់ត្រូវបានយោធាខ្មែរក្រហមសង្ស័យ និងចោទថាឈ្មោះ ហ៊ូ កុសល ហៅ ហ៊ុត ពាក់ស័ក្តិ៣ដែលជាបក្ខពួករបស់ កែម ធី និង ឌៀប ស៊ាន អតីតជាចៅហ្វាយ ខេត្តប៉ៃលិន ។ ប៉ុន្តែគាត់បានបដិសេធ និងប្រាប់ថា អង្គការច្រឡំឈ្មោះហើយ ព្រោះ ហ៊ូ កុសល ហៅ ហ៊ុត ត្រូវអង្គការចាប់យកទៅបាត់ហើយ ចំណែកគាត់ឈ្មោះ ចាន់ ។

ទោះយ៉ាងណា យោធាបានឃុំឃាំង និងដាក់ខ្នោះជើងគាត់ម្នាងរួចហើយឲ្យបាវទៅគាត់មួយសម្រាប់ក្រាលដេកផ្ទាល់នឹងដី និងឆ្នាំងមួយសម្រាប់ដាក់ទឹកផឹក និងសម្រាប់ត្រងទឹកនោម ។

នៅក្នុងគុក គាត់ទទួលបានរបបអាហារបន្តិចបន្តួចប៉ុណ្ណោះសម្រាប់ហូប ។ គាត់ត្រូវបានយោធាខ្មែរក្រហមវាយ និងប្រកចង់ថ្នាស៊ិកឲ្យថប់ដង្ហើមដើម្បីសួរចម្លើយ ។ យោធាខ្មែរក្រហមបានសួរគាត់ទាក់ទងនឹងគណៈតំបន់១ឈ្មោះ ស៊ូ និងគណៈតំបន់៣ឈ្មោះ ភោគ សារី ដែលអង្គការបានចាប់ខ្លួនរួចហើយ ។

រយៈពេលបួនថ្ងៃក្រោយមក យោធាខ្មែរក្រហមបញ្ជាគាត់ឲ្យជីករណ្តៅ ។ បន្ទាប់ពីគាត់ជីកបានពីររណ្តៅយោធាក៏ដោះលែងគាត់ ។ ប៉ុន្តែ មុននឹងដោះលែងយោធាខ្មែរក្រហមបានយកគាត់ទៅបំពាក់បំប៉ន់ និងប្រាប់ថា ប្រសិនបើមាននរណាសួរនាំត្រូវឆ្លើយថា អង្គការបញ្ជូនគាត់ឲ្យទៅធ្វើការនៅតាមកន្លែងផ្សេងៗ ។

នៅម៉ោង៨ព្រឹក យោធាខ្មែរក្រហមបានជូន កុសល ត្រឡប់ទៅភូមិវិញដែលមានចម្ងាយប្រមាណបីគីឡូម៉ែត្រពីកន្លែងឃុំឃាំង ។ ពេលឃើញគាត់ត្រឡប់មកវិញ ប្រធានសហករណ៍បានដាំបាយបីកំប៉ុង និងអាំងត្រីរស់មួយដែលជារបស់សមូហភាពយកមកឲ្យគាត់ហូប ។ ដោយសារឃ្លានខ្លាំងគាត់ហូបបាយ និងត្រីរហូតអស់ ។

## ពីប្រទេសកម្ពុជាទៅជំរំ

គាត់រស់នៅសហករណ៍កាពោខាងជើង រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ទើបគាត់នាំគ្រួសាររត់គេចចេញមកជួបនឹងកងវៀតណាមនៅតាមផ្លូវ ។ កងទ័ពវៀតណាមបានសួរនាំគាត់ពីកន្លែងលាក់ខ្លួនរបស់ខ្មែរក្រហម និងបានប្រគល់គោក្របី និងស្រូវជាច្រើនមកឲ្យគាត់ ។

នៅទីនោះ គាត់ត្រូវបានចាត់តាំងឲ្យធ្វើគណៈឃុំនៅអូរតាគាំ បានរយៈពេលបីខែ ទើបគាត់ចេញទៅនៅជំរំចាស់ និងជំរំខៅអ៊ីដាង ក្នុងទឹកដីថៃ ។ បន្ទាប់មក គាត់និងប្រពន្ធ ព្រមទាំងកូនពីរនាក់បានចេញទៅរស់នៅប្រទេសហ្វីលីពីនរយៈពេល៦ខែ ទើបបន្តទៅរស់នៅប្រទេសអាមេរិក នៅខែសភា ឆ្នាំ១៩៨១ ។

រហូតមកដល់ថ្ងៃនេះ កុសល នៅតែនិយាយពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម ព្រោះគាត់យល់ថា រឿងរ៉ាវដែលកន្លងហួសទៅហើយ គឺជាមេរៀនមួយដែលយើងគួរតែចងចាំ និងទប់ស្កាត់កំហុសទាំងឡាយដែលខ្មែរក្រហមបានប្រព្រឹត្តកុំឲ្យកើតឡើងជាថ្មីម្តងទៀត ។

**សោម ប៊ុនថន**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន នឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

Email: truthbunthorn.s@dccam.org

Home page: www.d.dccam.org

# អតីតពេទ្យទាហានផ្តល់សក្ខីកម្មអំពីការវាយប្រហារទាហានខ្មែរក្រហម

*អតីតប្រធានពេទ្យទាហាន 2-TCW-1065 (រក្សាខ្លួនជាជនអនាមិកសម្រាប់ការស៊ើបអង្កេតលើសំណុំរឿងផ្សេងទៀត) ផ្តល់សក្ខីកម្មអំពីតួនាទីក្នុងការប្រយុទ្ធជាមួយទាហានខ្មែរក្រហមចាប់តាំងពីពាក់កណ្តាលឆ្នាំ១៩៧៨ ។ សាក្សីបានផ្តល់ព័ត៌មានអំពីការសហការរបស់គាត់ជាមួយវៀតណាម និងបញ្ជាក់ពីការជួបជាមួយមេដឹកនាំយោបាយជាន់ខ្ពស់ជាច្រើនរូបដែលសម្ងំលាក់ខ្លួនក្នុងព្រៃដើម្បីរៀបចំគម្រោងផ្តួលរំលំរបបខ្មែរក្រហម ។*



សាក្សី អតីតជាពេទ្យយោធា បានផ្តល់សក្ខីកម្មនៅសាលាក្តីខ្មែរក្រហម

## ការសាកសួរដោយចៅក្រម

ភាគីទាំងអស់មានវត្តមាននៅក្នុងតុលាការ ហើយអង្គជំនុំជម្រះត្រូវបានផ្តល់ជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែរញ ដើម្បីធ្វើការសាកសួរទាក់ទងទៅនឹងអង្គភាពរបស់សាក្សី ។ សាក្សីជាប្រធានមន្ទីរពេទ្យ១៥៦ នៃពេទ្យទាហាន ដែលចំណុះឲ្យកងពលធំលេខ៤ ។ លោកចៅក្រម ឡាវែរញ ក៏បានសួរបន្ថែមទៅលើព័ត៌មានដែលថា សាក្សីជាប្រធានកងវរសេនាធំ តើវាជាការពិតដែរឬទេ? ហើយប្រសិនជាពិត តើកងវរសេនាធំរបស់គាត់មានទីតាំងនៅឯណាដែរ? សាក្សីបានឆ្លើយថា ចាប់តាំងពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៨មក គាត់លែងជាប្រធានមន្ទីរពេទ្យទៀតហើយ ដោយគាត់បានចូលក្នុងសមរភូមិវិញម្តង ។ ស្របពេលជាមួយគ្នានេះដែរ មានរដ្ឋប្រហារមួយនៅភូមិភាគ៤ ដែលធ្វើឲ្យទាហានជាច្រើនរត់គៀសខ្លួន ។ នៅពេលនោះ គ្មាននរណាម្នាក់នៅពីលើខ្ញុំនោះទេ ។ ដូច្នេះសាក្សីជាអ្នករៀបចំកងកម្លាំងដើម្បីវាយប្រហារខ្មែរក្រហម ។ គ្មានមេបញ្ជាការយោធាផ្សេងក្រៅពីខ្ញុំនោះដែរ ។ សាក្សីមានមេបញ្ជាការផ្ទាល់២រូប ដែលជាមេបញ្ជាការកងវរសេនាធំ ដែលទីស្នាក់ការកណ្តាលរបស់កងវរសេនាធំមានមូលដ្ឋាននៅកន្លែងផ្សេង ។ សាក្សីនៅសមរភូមិមុខ ហើយទាហាននឹងត្រូវបញ្ជូនទៅមន្ទីរពេទ្យនៅពេលដែលពួកគេមានរបួសដែលសមរភូមិមានចម្ងាយ៥០គីឡូម៉ែត្រពីមន្ទីរពេទ្យ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ពួកគេមិនបានចូលរួមក្នុងសមរភូមិមុខនោះដែរ ។

លោកចៅក្រម ឡាវែរញ បានចោទសួរបន្តថា តើសាក្សីធ្លាប់ចូលរួមដោយផ្ទាល់ក្នុងការវាយលុកតំបន់របស់វៀតណាមដែរឬទេ? សាក្សីបានឆ្លើយថា ពួកគាត់គឺជាពេទ្យទាហាន ដូច្នេះគាត់ទទួលខុសត្រូវលើការព្យាបាលទាហានដែលមានរបួសតែប៉ុណ្ណោះ ។ ដោយផ្អែកលើហេតុផលនេះ ខ្ញុំមិនបានចូលរួមដោយផ្ទាល់ក្នុងការប្រយុទ្ធនោះទេ ។ ពួកគេបានបាត់បង់ភូមិខ្លះក្នុងព្រំប្រទល់ដែនសីមារបស់គេ ហើយអ្នកតំណាងអង្គការបានធ្វើការជាមួយសាក្សីក្នុងការផ្ទៀងផ្ទាត់ដែនទីនេះ ។ ខេត្តខ្លះរបស់ខ្មែរលែងមាននៅក្នុងដែនទីទៀតហើយ ។ សាក្សីបានទទួលការណែនាំនេះពីភូមិភាគ ប៉ុន្តែគាត់មិនប្រាកដនោះទេ ។

លោកចៅក្រម ឡាវែរញ បានអានសម្រង់ខ្លីនៃបទសម្ភាសន៍របស់សាក្សីចំពោះការខ្វែងគំនិតគ្នាទៅលើបញ្ហាព្រំដែន ។ បន្ទាប់ពីកិច្ចប្រជុំ មេដឹកនាំវរសេនាធំជាអ្នកផ្សព្វផ្សាយព័ត៌មានទាំងនេះទៅដល់ពួកគេ ។ សាក្សីបានទទួលព័ត៌មានទាំងនេះតាមរយៈមេបញ្ជាការវរសេនាធំ ។

លោកចៅក្រម ឡាវែរញ ក៏បានធ្វើការសាកសួរបន្ថែមចំពោះការបញ្ចុះបញ្ចូលប្រឆាំងជាមួយនឹងវៀតណាម ដើម្បីបង្ហាញ

ឲ្យវៀតណាមឃើញថា កម្ពុជាមិនមែនទន់ខ្សោយដូចវៀតណាមគិតនោះទេ ។ សាក្សីបានតបថា ការបញ្ចុះបញ្ចូលនេះ ត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ១៩៧៧ ក្នុងគោលបំណងព្រមានដល់ភាគីវៀតណាមឲ្យគោរពបូរណភាពទឹកដីកម្ពុជា ។

ក្នុងសក្ខីកម្មរបស់សាក្សី សាក្សីបានលើកឡើងថា កម្ពុជាមិនមែនទន់ខ្សោយដូចការគិតរបស់វៀតណាមនោះទេ ដូច្នេះទើបមានការវាយប្រហារលើវៀតណាមពីសំណាក់ភាគីកម្ពុជា ។ បន្ទាប់ពីការឃោសនាបានធ្វើឡើង វាគ្មានការកំណត់ ឬការបន្ធូរបន្ថយនោះទេ ហើយគោលដៅរបស់ពួកគេគឺយោធាទាំងអស់ ។

សាក្សីមិនបានដឹងថា កងកម្លាំងមួយណាជាអ្នកវាយប្រហារផ្សារស្នាច់នោះទេ ហើយសាក្សីក៏មិនបានដឹងពីព័ត៌មានលម្អិតទាក់ទងនឹងរឿងនេះដែរ ។ តាមចម្លើយរបស់សាក្សី គោលដៅសំខាន់របស់ពួកគេ គឺយោធាទាំងអស់ ។

លោកចៅក្រម ឡាវ៉ែញ បានបង្ហាញផែនទីមួយទៅកាន់សាក្សី ។ ត្រង់ចំណុចនេះ លោកស្រី ហ្គីស្សេ បានប្រានចោលចំពោះការបង្ហាញផែនទីនេះដោយអះអាងថា វាមិនមានការពាក់ព័ន្ធនឹងសវនាការនាពេលនេះនោះទេ ប៉ុន្តែលោកចៅក្រម ឡាវ៉ែញ បានបញ្ជាក់ថា វាជាប់ពាក់ព័ន្ធនឹងការកើតឡើងនៃវិវាទ ។ លោកស្រី ហ្គីស្សេ បានលើកឡើងបន្ថែមថា ផែនទីនេះទាក់ទងនឹងការវាយលុកទៅលើទឹកដីវៀតណាម ហើយវាមានលក្ខណៈស៊ីជម្រៅខ្លាំងណាស់ ។

លោកចៅក្រម ឡាវ៉ែញ សាកសួរបន្តទាក់ទងនឹងភូមិត្នោត, ស្នាច់, ស្វាយ, ដល និង ចាស ប៉ុន្តែខាងសាក្សីបដិសេធមិនស្គាល់ភូមិទាំងនោះទេ ។

លោកចៅក្រម ឡាវ៉ែញ ក៏លើកឡើងពីសារទូរលេខនៅខែតុលា ឆ្នាំ១៩៧៧ ដែលចុះហត្ថលេខាដោយ ឈុន ។ ត្រង់ចំណុចនេះ សាក្សីបានស្រាយបំភ្លឺថា គាត់បានមើលឯកសារមួយចំនួន ហើយ ឈុន មិនមែននៅក្នុងភូមិភាគបូព៌ានោះទេ ។ សាក្សីក៏មិនបានដឹងឈ្មោះអ្នកសរសេរសារទូរលេខនោះដែរ ។

សាក្សីបានបន្តថា គាត់ក៏មានការឆ្ងល់អំពីអ្នកដែលបង្កើតរដ្ឋប្រហារនេះឡើងដែរ ។ លោកប្រធានបានរំឭកសាក្សីឲ្យឆ្លើយសំណួរ ហើយកុំនិយាយនូវអ្វីដែលគាត់ (សាក្សី) មិនបានដឹង ។

សាក្សីពុំបានដឹងថា បន្ទាយទាហានលេខ២៧ មានចម្ងាយប៉ុន្មាននោះទេ ហើយត្រង់ចំណុចនេះលោកចៅក្រម ឡាវ៉ែញ ទាមទារឲ្យមានការពន្យល់ឲ្យបានក្បោះក្បាយអំពីតួនាទីរបស់បន្ទាយទាហាននេះ ដែលវាមានទីតាំងស្ថិតនៅក្នុងតំបន់របស់វៀតណាម ។ សាក្សីបានជួប សោ ភឹម ដោយផ្ទាល់ ប៉ុន្តែគាត់មិនបាននិយាយអំពីបញ្ហាវៀតណាមជាមួយ សោ ភឹម នោះទេ ។ ពួកយើងមិនបានពិភាក្សាអំពីបញ្ហានយោបាយ ឬផែនការយុទ្ធសាស្ត្រយោធាអ្វីនោះទេ នេះបើតាមចម្លើយរបស់សាក្សី ។

សាក្សីបន្តថា ឈុន មិនមែនជាសមាជិករបស់ក្រុមកម្មាភិបាលភូមិភាគបូព៌ានោះទេ ។ ជាថ្មីម្តងទៀតលោកប្រធានបានរំឭកការណែនាំរបស់គាត់ ឲ្យបានជាក់លាក់ជាងមុនទៅកាន់សាក្សី ។ សាក្សីក៏បញ្ជាក់ម្តងទៀតថា គាត់មិនបានដឹងអំពីព័ត៌មានលម្អិតទាក់ទងនឹងគម្រោងការនោះទេ ។ លោកចៅក្រម ឡាវ៉ែញ បានបន្តសួរអំពីឧស្ម័នពុលដែលបានលើកឡើងក្នុងសារទូរលេខ ។ សាក្សីបានឆ្លើយថា នៅក្នុងមន្ទីរពេទ្យមានអ្នករបួសជាច្រើន ហើយមានចំនួនអ្នកស្លាប់តិចតួចណាស់ ដូច្នេះគាត់មិនដែលឃើញមានការប្រើប្រាស់ឧស្ម័នពុលនោះទេ ។

ទាក់ទងនឹងផែនការរបស់ សោ ភឹម ក្នុងការជួបជាមួយវៀតណាម សាក្សីបានស្រាយបំភ្លឺថា សោ ភឹម មិនបាននិយាយអំពីបញ្ហានេះជាមួយគាត់ទេ ។

លោកចៅក្រម ឡាវ៉ែញ បានសាកសួរបន្តថា តើមានការសហការគ្នារវាងកងកម្លាំងរបស់ កែ ពក និងកងកម្លាំងរបស់វៀតណាមដែរឬទេ? សាក្សីតបថា នៅក្នុងដំណាក់កាលបន្ទាប់មកទៀត វៀតណាមបានវាយប្រហារកម្ពុជា ហើយកម្លាំងរបស់មជ្ឈិម បានឈរជើងនៅសមរភូមិក្រោយ ស្របពេលដែលកម្លាំងភូមិភាគបូព៌ាឈរជើងនៅសមរភូមិមុខ ។ នៅក្នុងពេលនោះ កម្លាំងរបស់មជ្ឈិមបានវាយប្រហារទៅលើកងកម្លាំងរបស់ខ្លួនឯង ។ លោកប្រធានបានណែនាំឲ្យសាក្សីផ្តល់ចម្លើយឲ្យបានច្បាស់លាស់ ។

## ការសហការរវាងសាក្សី និងវៀតណាម

លោកចៅក្រម ឡាវ៉ែញ បានសាកសួរអំពីចំនួនកងកម្លាំងដែលឋិតនៅក្រោមបញ្ជាពីសាក្សីចាប់ពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៨ ។ សាក្សីបានឆ្លើយថា កងកម្លាំងទាំងនោះមកពីកងពលតូចលេខ១៤ ដែលក្នុងនោះមានទាហាន៣០០នាក់ មកពីកងទ័ពថ្មើរជើង

និង៤០នាក់ផ្សេងទៀត មកពីកងទ័ពពិសេស ។ ការប្រយុទ្ធចាប់ផ្តើមតាំងពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៨ រហូតដល់ខែវិច្ឆិកា ឆ្នាំដដែលនេះ ។ សាក្សីមិនបានដឹងអំពីការភៀសខ្លួនរបស់កម្មាភិបាលខ្មែរទៅកាន់វៀតណាមនោះទេ ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៨ សាក្សីបានទាក់ទងជាមួយនឹងទាហានវៀតណាម ។

ពួកគេទាំងនោះជាសត្រូវរបស់ខ្ញុំ ។ នៅក្នុងដំណាក់កាលដំបូង ពួកយើងប្រយុទ្ធជាមួយវៀតណាម ។ បន្ទាប់មករដ្ឋប្រហារបានកើតឡើង ហើយពួកយើងចាប់ផ្តើមប្រយុទ្ធជាមួយកងកម្លាំងខ្លួនឯងវិញម្តង ។ សាក្សីបានចងចាំមនុស្ស២នាក់ដែលឈរនៅខាងវៀតណាមគឺ កុយ វៀង និង ទិត ។ សាក្សីក៏បានជួបជាមួយ ហេង សំរិន, អ៊ុក ប៊ុនឈឿន រួមជាមួយ ប៉ុល សារឿន ផងដែរ ។

លោកចៅក្រម ឡាវែញ បានសាកសួរអំពីតួនាទីរបស់សាក្សីនៅពេលដែលរណសិរ្សត្រូវបានបង្កើតឡើង ។ សាក្សីបានឆ្លើយថា គាត់បានចាកចេញពីកម្ពុជា ទៅកាន់ស្ថានីយប៉ូលីស Long Xuyen ។ ក្រោយមកទៀតគាត់ត្រូវបាននាំយកទៅបន្ទាយយោធានៅ Long Giao ហើយបន្ទាប់មកទៀត សាក្សីបានត្រឡប់មកកម្ពុជាវិញ ។ សាក្សីទៅទទួលអ្នកទោសសង្គ្រាមពីខេត្តកំពង់ធំ ដែលគាត់ត្រូវបង្រៀនអ្នកទាំងនោះអំពីគោលនយោបាយរណសិរ្ស ។

អ្នកទាំងនោះត្រូវបានបញ្ជូនមកពីសៀមរាប និងកំពង់ធំ ។ គោលបំណងក្នុងការអប់រំទូន្មាននាពេលនោះ គឺដើម្បីណែនាំពួកគេឲ្យធ្វើអំពើល្អ ។ ប្រធាននៅពេលនោះគឺជាជនជាតិវៀតណាម ហើយជនជាតិវៀតណាមនោះ គឺជានាយទីចាត់ការផងដែរ ។ ការអប់រំទូន្មាននាពេលនោះ គឺត្រូវបានអនុញ្ញាតដោយគោលនយោបាយរណសិរ្ស ។ វៀតណាមបានផ្តល់កិច្ចការក្នុងការទូន្មានមនុស្សអំពីគោលនយោបាយរណសិរ្សនេះមកឲ្យភាគីកម្ពុជា ។ ពួកគេនៅក្រោមការគ្រប់គ្រងរបស់វៀតណាម ហើយសាក្សីគឺជាអនុប្រធានតែមួយគត់នាពេលនោះ ។

ពួកគេប្រមូលជនស៊ីវិល៤០០នាក់ ដែលមកពីខេត្តផ្សេងៗគ្នា ដែលអ្នកទាំងនោះជាកម្មាភិបាលស៊ីវិល មកពីកងអនុសេនាតូច និងកងអនុសេនាធំ ។ សាក្សីឋិតនៅជំរំអប់រំកម្មាភិបាល ហើយមានការខ្វែងគំនិតគ្នាជាច្រើនបានកើតឡើងទាក់ទងនឹងគោលនយោបាយនេះ ។

## ការឃុំឃាំង

នៅឆ្នាំ១៩៧៩ សាក្សីបានធ្វើដំណើរទៅពោធិ៍សាត់ជាមួយទាហាន៩នាក់ ដើម្បីស្វែងរកគ្រួសាររបស់គាត់ដែលត្រូវបានជម្លៀសចេញដោយ ប៉ុល ពត ។ បន្ទាប់មកនៅឆ្នាំ១៩៨០ សាក្សីត្រូវបានគេឃុំខ្លួនអស់រយៈពេល៨ខែ ។ ខ្ញុំត្រូវបានចោទប្រកាន់ពីបទប៉ុនប៉ងរត់ភៀសខ្លួនទៅបរទេស សាក្សីត្រូវបានចោទសួរដដែលៗ អំពីមូលហេតុដែលគាត់ទៅខេត្តពោធិ៍សាត់ ។ វៀតណាមលែងជឿទុកចិត្តខ្ញុំទៀតហើយ ។ សាក្សីត្រូវបានគេចោទប្រកាន់ថា ចង់រត់ភៀសខ្លួនទៅប្រទេសថៃ ។ ស្ថានភាពនៅក្នុងពន្ធនាគារគឺអាក្រក់ខ្លាំងណាស់ ។ ខ្ញុំមិនមានបាយហូបទេ ពេលខ្លះខ្ញុំត្រូវហូបអំបិល ឬក៏គ្មានអ្វីហូបសោះក៏មានដែរ ។ ពន្ធនាគារនៅពេលនោះគឺឋិតនៅក្រោមការគ្រប់គ្រងរបស់វៀតណាម ។ ខ្ញុំពិតជាខកចិត្តខ្លាំងណាស់ ។ ខ្ញុំបានចេញពីរបបមួយ ហើយធ្លាក់ចូលទៅក្នុងរបបមួយផ្សេងទៀត ។

## អនីតិភាព

សាក្សីមិនអាចចំណាំកម្មាភិបាលមេដឹកនាំ ដែលទៅតំបន់នោះបានទេ ។ សាក្សីបន្តថា គោលនយោបាយមិនត្រូវបានសាយភាយដល់គាត់នោះទេ ដោយគិតថាគាត់ជាអតីតទាហាន លន់ នល់ ហើយជាពេទ្យទាហានសម្រាប់ព្យាបាលមនុស្សតែប៉ុណ្ណោះ ។ សាក្សីបានឮដឹងថា មានមនុស្សបាត់ខ្លួន ប៉ុន្តែគាត់មិនដឹងថាអ្នកទាំងនោះទៅទីណានោះទេ ។ ខ្ញុំមិនបានដឹងពីគោលនយោបាយរបស់ពួកគេនៅពេលនោះទេ ។ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គ្មានជនជាតិវៀតណាមទេ ហើយសាក្សីក៏មិនដឹងពីគោលនយោបាយទាក់ទងនឹងជនជាតិចាមដែរ ។

ត្រង់ចំណុចនេះលោកចៅក្រម ឡាវែញ បញ្ចប់ការសាកសួររបស់គាត់ ហើយផ្តល់នាទីនេះទៅសហព្រះរាជអាជ្ញា ។

## សោ ភីម

សហព្រះរាជអាជ្ញាជាតិ សេង លាង បានសួរអំពីចំនួនមនុស្សជំនិតរបស់ សោ ភីម ។ សាក្សីតបថា មនុស្សជំនិតរបស់ សោ ភីម មាន៥នាក់ ក្នុងនោះដែរសាក្សីចងចាំតែឈ្មោះ ចឹង និង យឹក ប៉ុណ្ណោះ សាក្សីមិនចាំ នង ស៊ីម និង ជ័យ នោះទេ ។ ចឹង និង អ៊ុង ត្រូវជាក្មួយរបស់សាក្សី ក៏ប៉ុន្តែពួកគេទាំងពីរនាក់បានស្លាប់

បាត់ទៅហើយ ។

សហព្រះរាជអាជ្ញា លាង បានសំដៅទៅលើបទសម្ភាសន៍កាលពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៥ រវាង នង ស៊ីម និងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយបានសួរទៅកាន់សាក្សីអំពីកាលបរិច្ឆេទដែលសាក្សីត្រូវបានបញ្ជូនទៅសមរភូមិមុខក្នុងឆ្នាំ១៩៧៨ ។ តាមចម្លើយរបស់សាក្សី គាត់ត្រូវបានបញ្ជូនទៅធ្វើជាពេទ្យទាហាននៅសមរភូមិមុខនៅចុងឆ្នាំ១៩៧៧ ហើយគាត់ចាំមិនបានទេថាគាត់ទៅដល់សមរភូមិមុខបានប៉ុន្មានម៉ោងមុនពេលដែលវៀតណាមវាយប្រហារកម្ពុជា ។ មេបញ្ជាការកងវរសេនាធំលេខ១៥៦ ជាអ្នកផ្ដល់ការណែនាំ ហើយមានតែមនុស្ស៦នាក់ប៉ុណ្ណោះដែលនៅក្នុងអង្គភាពពេទ្យនាពេលនោះ ។

សហព្រះរាជអាជ្ញា លាង បានបន្តសួរទៅកាន់សាក្សីថា តើហេតុអ្វីបានជាគេបញ្ជូនពេទ្យទាហានឲ្យទៅវាយប្រហារបន្ទាយទាហាន? កងវរសេនាធំ ត្រូវបានបែងចែកចេញជាកងវរសេនាធំលេខ ១៥៤, ១៥៥ និង ១៥៦ ។ មុនពេលដែលកងវរសេនាធំលេខ១៥៦ ទៅសមរភូមិ ពួកគេត្រូវបញ្ជូនក្រុមឈ្លបទៅមើលស្ថានការណ៍ជាមុនសិន ។

សហព្រះរាជអាជ្ញាបានបន្តសាកសួរអំពី មេបញ្ជាការរង ឈឺន ។ សាក្សីបានបញ្ជាក់ថា ឈឺន ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ ព-២ ដែលស្ថិតនៅក្នុងភូមិភាគ ។ នៅពេលនោះមានមនុស្ស ៤នាក់ ដែលជាមេដឹកនាំ ។ នៅពេលដែលកងកម្លាំងអនុសេនាធំលេខ១៦៥ ដកថយ គោលបំណងរបស់ពួកគេគឺដើម្បីទប់ទល់ជាមួយវៀតណាមដែលចូលក្នុងទឹកដីកម្ពុជា ។ មេបញ្ជាការនីមួយៗត្រូវមានយុទ្ធវិធីរៀងៗខ្លួន ។ អង្គភាពរបស់សាក្សីមិនបានប្រើគ្រាប់មីន ឬដាក់ចម្រូងអ្វីនោះទេ ។ នៅពេលដែលវៀតណាមវាយចូលមក អង្គភាពរបស់សាក្សីរវល់នៅសមរភូមិមុខ ហើយកងកម្លាំងទាំងអស់ត្រូវបានបញ្ជូនទៅសមរភូមិមុខគ្មានសេសសល់ម្នាក់ណានោះឡើយ ។

នៅពេលដែលវៀតណាមសម្រុកចូល គ្មានកងកម្លាំងសម្រាប់ទប់ទល់ជាមួយវៀតណាមនៅផ្លូវលេខ៧នោះទេ ដែលនៅពេលនោះ កងវរសេនាធំលេខ១៥៥ និង ១៥៦ ជាអ្នកដែលត្រូវទប់ទល់ជាមួយវៀតណាម ។ នៅពេលដែលវាយចូលមក វៀតណាមបានប្រើកាំភ្លើងធុនធំ ។ វៀតណាមប្រើកងកម្លាំងសំខាន់របស់គេដើម្បីសម្រុកចូលមក ។ នៅពេលនោះ មានការបែងចែកកងកម្លាំង



រថក្រោះរបស់កងទ័ពវៀតណាម ត្រូវបានកងទ័ពបដិវត្តន៍ខ្មែរក្រហមបាញ់ឆេះក្នុងអំឡុងពេលវាយប្រយុទ្ធគ្នា នៅសមរភូមិខេត្តស្វាយរៀង នៅខែធ្នូ ឆ្នាំ១៩៧៧

សម្រាប់ទប់ទល់នឹងការវាយលុករបស់វៀតណាម ។ បើសិនជាទាហានវៀតណាមចូលកាន់តែជ្រៅ កងកម្លាំងមជ្ឈិមត្រូវជួយទប់ស្កាត់ និងប្រយុទ្ធជាមួយវៀតណាមនៅតំបន់នោះ ។ ទាហានវៀតណាម មានការភ័យខ្លាចចំពោះស្ថានការណ៍បែបនេះ ដូច្នេះហើយទើបពួកគេដកទ័ពចេញ ។

## កម្មាភិបាល

បន្ទាប់ពីសម្រាក សហព្រះរាជអាជ្ញា លាង បានបង្ហាញរូបថត២សន្លឹកដល់សាក្សីដើម្បីស្វែងយល់ថា តើសាក្សីស្គាល់មនុស្ស២នាក់ក្នុងរូបនេះដែរឬទេ ។ រូបថតនេះត្រូវបានអនុញ្ញាតឲ្យយកមកប្រើប្រាស់នៅក្នុងអង្គជំនុំជម្រះបន្ទាប់ពីមានការពិភាក្សាគ្នាពីអង្គចៅក្រម ។ តាមរយៈរូបថត បានបង្ហាញពីបុរសម្នាក់ដែលឈរពីមុខខ្ទមមួយ ហើយសហព្រះរាជអាជ្ញាបានសួរទៅកាន់សាក្សីតើគាត់នៅចងចាំមនុស្សដែលនៅក្នុងរូបថតនេះដែរឬទេ ។ សាក្សីបានឆ្លើយថា ម្នាក់នោះគឺ នឹម ដែលប្រហែលជាអ្នកបើកឡានរបស់ សោ ភឹម ។

រូបថតបន្ទាប់បង្ហាញពី អ៊ឹង ដែលជាអ្នកធ្វើការជាមួយញឹម ។ សហព្រះរាជអាជ្ញា លាង បានអានបទសម្ភាសន៍របស់ នង នឹម ដែលរៀបរៀងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីមើលពីប្រតិកម្មរបស់សាក្សី ។ សាក្សីបានឆ្លើយថា គាត់គ្រាន់តែដឹងថា នង នឹម ជាអ្នកបើកឡានរបស់ សោ ភឹម ប៉ុណ្ណោះ ហើយ នឹម ដឹងរឿងច្រើនណាស់ ។

សាក្សីបានបន្តទៀតថា គាត់មិនបានពិភាក្សាជាមួយ អ៊ឹង ច្រើននោះទេ ។

សហព្រះរាជអាជ្ញា លាង បានអានសេចក្តីសម្រង់ពីបទសម្ភាសន៍របស់ អ៊ឹង ។ នៅត្រង់ចំណុចនេះលោកចៅក្រម ឡាវ៉ែញ បានបដិសេធចំពោះសម្រង់នោះ និងសួររកឯកសារយោងរបស់វា ។ សម្រង់នោះសំដៅលើសំបុត្រផ្ញើ ។

អង្គជំនុំជម្រះត្រូវបានផ្តល់ឲ្យសហព្រះរាជអាជ្ញាអន្តរជាតិលោក នីកូឡាស គាំចាន់ ។ សាក្សីបានបន្តថា មានទាហានចំនួន១២០នាក់ នៅក្រោមការបញ្ជារបស់គាត់ ហើយគាត់គឺជាទាហាននៅក្នុងកងវរសេនាធំ ប៉ុន្តែគាត់មិនមែនជាសមាជិកបក្សនោះទេ ។

សាក្សីក៏បានបន្តថា មានការដោះដូររវាងកម្ពុជាក្រោម និងកម្ពុជាផងដែរ ហើយត្រង់ចំណុចនេះ សាក្សីបានបញ្ជាក់ថា គាត់មិនមែនសំដៅលើការដោះដូរប្រជាជននោះទេ ប៉ុន្តែជាការដោះដូរសេដ្ឋកិច្ចទៅវិញទេ ។

សហព្រះរាជអាជ្ញា គាំចាន់ បានសួរបន្តថា តើនៅអង្គភាពរបស់សាក្សីមានវិទ្យុដែរឬទេ? សាក្សីបានឆ្លើយថា មុនពេលដែលមានរដ្ឋប្រហារកើតឡើងក្នុងឆ្នាំ១៩៧៨ គ្មានវិទ្យុយោធានៅមន្ទីរពេទ្យនោះទេ ។

សហព្រះរាជអាជ្ញា គាំចាន់ បានបន្តសួរថា តើសាក្សីបានដឹងពីគោលនយោបាយខ្លះដែរឬទេ? សាក្សីបានស្រាយបំភ្លឺថា អង្គភាពរបស់គាត់ គឺសម្រាប់ជួយសង្គ្រោះជីវិត ដូច្នេះពួកគាត់មិនដែលបានទទួលទស្សនាវដ្តីអ្វីនោះទេ ។ សាក្សីក៏មិនធ្លាប់នៅមូលដ្ឋានស្វាយរៀងដែរ ហើយនៅមុនឆ្នាំ១៩៧៧ សាក្សីឈរជើងនៅភូមិឡ ខេត្តត្បូងឃ្មុំ ។

ពួកគេព្យាបាលទាហានដែលមានរបួសស្រាលនៅសមរភូមិ ហើយនឹងទាហានដែលមានរបួសធ្ងន់នៅមន្ទីរពេទ្យ ។

ទាហានវៀតណាមឈរជើងនៅបន្ទាយទាហានលេខ២៧ ។ សាក្សីត្រូវបានដឹកដោយខ្ទម្ភាគចក្រទៅកាន់ទីក្រុងហូជីមិញនៅខែវិច្ឆិកា ឆ្នាំ១៩៧៨ ។

សហព្រះរាជអាជ្ញា គាំចាន់ បានបន្តសួរពីមនុស្សម្នាក់ឈ្មោះ ឡាយ ឡេង ប៉ុន្តែសាក្សីមិនស្គាល់ម្នាក់នោះទេ ។ សហព្រះរាជអាជ្ញា គាំចាន់ បានអានសម្រង់ដែលដកស្រង់ពីការផ្តល់សក្ខីកម្មរបស់សាក្សី ដែលសាក្សីបាននិយាយថា ពួកគេបានដុតផ្ទះរបស់វៀតណាម ហើយវាយប្រហារពេទ្យយោធាវៀតណាមថែមទៀតផង ។ បន្ទាយទាហាន២៧ មានទីតាំងនៅឆ្ងាយពីភូមិ ហើយសាក្សីមិនបានដឹងថា កងកម្លាំងទិសនិរតីណាមួយ ជាអ្នកវាយប្រហារវៀតណាមនោះទេ ។

មានទាហានជាច្រើនត្រូវរបួសនៅសមរភូមិ ប៉ុន្តែគ្មាននរណាម្នាក់ស្លាប់នោះទេ ។

## ការបោសសម្អាតភូមិភាគបូព៌ា

សហព្រះរាជអាជ្ញា គាំចាន់ បានលើកឡើងអំពីការចាប់ខ្លួនទាហានជាច្រើននាក់នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៨ ។

សាក្សីបានឆ្លើយថា អ្នកដែលត្រូវបានចាប់ខ្លួនទាំងនោះសុទ្ធតែជាមេបញ្ជាការយោធាភូមិភាគបូព៌ា ។ បើសិនជាមេបញ្ជាការត្រូវបានចាប់ខ្លួន កងកម្លាំងនឹងចុះខ្សោយ ។ សហព្រះរាជអាជ្ញា គាំចាន់ បានបន្តសួរថា តើសាក្សីមានន័យដូចម្តេចនៅពេលសាក្សីរៀបរាប់ថ្ងៃទី២៥ ខែឧសភា ជាថ្ងៃធ្វើរដ្ឋប្រហារ ហើយចាត់ទុក ប៉ុល ពត ជាជនក្បត់នោះ? សាក្សីបានពន្យល់ថាពួកគេបានបញ្ជូនទាហានមជ្ឈិមដែលដឹកនាំដោយ កែ ពក ដើម្បីចាប់ខ្លួនមនុស្សជាច្រើន នេះហើយជាមូលហេតុដែលធ្វើឲ្យគាត់ចាត់ទុក ប៉ុល ពត ជាជនក្បត់ ។

ដំបូងឡើយ កងកម្លាំងភូមិភាគបូព៌ាត្រូវបានចាត់ឲ្យឈរជើងនៅព្រំដែនដើម្បីប្រយុទ្ធជាមួយទាហានវៀតណាម ។ ទាហានរបស់ កែ ពក ឈរជើងនៅស្ទឹង និងកន្លែង២ផ្សេងទៀត ។ ពួកគេត្រូវបញ្ជូនទៅទីនោះដើម្បីជាជំនួយដល់កម្លាំងភូមិភាគបូព៌ា ប៉ុន្តែពួកគេទាំងនោះបែរជាចាប់មនុស្សទៅវិញ ។ ការចាប់ខ្លួនកម្មាភិបាលនេះ គឺនៅក្នុងឆ្នាំ១៩៧៨ ។

សោ ភឹម បានសួរសាក្សីអំពីស្ថានការណ៍នៅព្រំដែនមុខ ហើយសាក្សីបានតបទៅ សោ ភឹម វិញថា ស្ថានការណ៍មិនល្អនោះទេ ។ សាក្សីបានពន្យល់ថា គាត់ចង់បញ្ចុះបញ្ចូលទាហានរបស់គាត់ដោយនិយាយថា ខ្យល់បកមិនខ្លាំងប៉ុន្មាននោះទេ ប៉ុន្តែមានដើមឈើដួលរលំ ព្រមទាំងព្យុះនៅប្រទេសចិនថែមទៀតផង ។


កងទ័ពបដិវត្តន៍ខ្មែរក្រហម កំពុងយាមការពារនៅតាមឆ្នេរសមុទ្រ

នៅពេលដែលសាក្សីចាកចេញពីសមរភូមិ គឺនៅរដូវកាលព្រះចន្ទពេញវង់ សាក្សីបានប្រាប់ សោ ភឹម ពីស្ថានការណ៍យោធានាពេលនោះ ហើយសាក្សីមិនធ្លាប់ឮ សោ ភឹម និយាយពីការផ្តួលរំលំ ប៉ុល ពត នោះទេ ។ សាក្សីមិនបានរៀបរាប់ពីភាពស្មោះត្រង់របស់ សោ ភឹម ចំពោះគាត់នោះទេ ។ សហព្រះរាជអាជ្ញា គាំចាន់ បានសួរបន្តទៀតថា តើ សោ ភឹម មានធ្លាប់ព្យាយាមជ្រើសរើសគាត់ដែរឬទេ ដោយគាត់ជាទាហាននៅភូមិភាគបូព៌ា ព្រមទាំងជាសាច់ញាតិនឹងគ្នាទៀតផង ។ សាក្សី បានឆ្លើយថា គាត់មិនធ្លាប់បានដឹងឮចំពោះរឿងនេះនោះទេ ។

តាមចម្លើយរបស់សាក្សី សាក្សីមិនដែលបានឃើញការចាប់ខ្លួននោះទេ ។ នៅពេលដែលសហព្រះរាជអាជ្ញា គាំចាន់ សួរអំពីទាហានធីវគី ដែលបានរត់ភៀសខ្លួនតាមព្រំដែន ។ លោកប្រធានបានធ្វើការបដិសេធ ហើយបន្តថា នៅក្នុងការបកប្រែគឺមិនមែនទាហានទួរគីនោះទេ ។ សាក្សីបានយល់ស្របថា ពិតជាមានទាហានធីវគីនៅក្នុងសម័យខ្មែរក្រហមមែន ប៉ុន្តែសាក្សីពុំបានដឹងថា ទាហានធីវគីនេះ មកតំបន់របស់គាត់នោះទេ ។

មេបញ្ជាការត្រូវបានកោះហៅឲ្យចូលរួមអង្គប្រជុំនៅក្រាំង ហើយមានតែសាក្សីម្នាក់ប៉ុណ្ណោះដែលមិនបានទៅចូលរួមក្នុងអង្គប្រជុំនាពេលនោះ ពីព្រោះគាត់ត្រូវនៅសមរភូមិមុខ ។

ការកោះហៅទៅប្រជុំមិនមែនជាការពិតនោះទេ មេបញ្ជាការទាំងនោះត្រូវបានចាប់ខ្លួន ។ សម ដែលមកពីអនុសេនាតូចត្រូវបានគេបញ្ជាឲ្យលុតជង្គង់នៅក្នុងអណ្តូង ហើយគាត់បានផ្ទះអណ្តូង និងរត់គេចខ្លួនបាត់ទៅ ។ សំ ត្រូវបានគេបាញ់ឲ្យរបួសត្រង់ដៃ ហើយគាត់បានមករកខ្ញុំនឹងប្រាប់ខ្ញុំពីរឿងដែលមនុស្សទាំងអស់ត្រូវបានគេសម្លាប់ ។ ក្រោយមក សាក្សីបានហៅអ្នកនៅក្រោមបង្គាប់របស់គាត់មកចូលរួមប្រជុំ ។ ទាហានកងវរសេនាតូចខ្លះមិនព្រមចូលរួមក្នុងការប្រយុទ្ធនោះទេ ។ ខ្ញុំបញ្ចុះបញ្ចូលពួកគេឲ្យចូលរួមប្រយុទ្ធជាមួយនឹងទាហានមជ្ឈិម ហើយមានតែទាហាន៣០០នាក់ប៉ុណ្ណោះដែលព្រមមកជាមួយខ្ញុំ ។

**ការរស់នៅក្នុងព្រៃ**

សាក្សីបានបាត់បង់ការទាក់ទង ហើយអ្នកដែលទៅជាមួយគាត់សុទ្ធតែជាទាហានដែលមកពីសមរភូមិ ។ សហព្រះរាជអាជ្ញា

គាំទ្រ បានសួរថា តើគាត់យល់ច្បាស់ដែរឬទេ ដែលថាអត្តភាពរបស់គាត់មានបំណងការពារប្រជាជនស៊ីវិល? សាក្សីបានឆ្លើយថា ប្រជាជនស៊ីវិលខ្លះបានរត់គេចខ្លួនមកនៅក្នុងព្រៃ ។ បើសិនខ្ញុំមិនប្រយុទ្ធ ខ្ញុំនឹងគ្មានអ្វីទាំងអស់ ។ ពួកយើងត្រូវតែចូលរួមប្រយុទ្ធប្រឆាំង ប៉ុល ពត ដើម្បីទទួលបានអង្ករ អំបិល និងថ្នាំពេទ្យ ។

ពួកគេត្រូវរត់ភៀសខ្លួន ដើម្បីគេចពីការចាប់ខ្លួន ដូច្នេះសាក្សីត្រូវជួយពួកគេ ត្រូវផ្គត់ផ្គង់អាហារដល់ពួកគេ ។ កងកម្លាំងមជ្ឈិមត្រូវបញ្ជូនមកឲ្យចាប់ខ្លួនទាហាន និងប្រជាជនស៊ីវិល ។ ទាហាន និងប្រជាជនស៊ីវិល បានរត់ភៀសខ្លួន ពីព្រោះតែការតាមចាប់ខ្លួន ។ សាក្សីបានឃើញរណ្តៅ និងផ្នូរ ប៉ុន្តែគាត់មិនបានឃើញសាកសពនោះទេ ហើយរណ្តៅ និង ផ្នូរនោះគឺនៅទីវាលមួយកន្លែងនៃស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ។

កូនរបស់សាក្សីត្រូវបានបញ្ជូនទៅរស់នៅភូមិភាគ ។ យាយក្មេក, ប្រពន្ធ ព្រមទាំងកូនទាំងបីរបស់សាក្សី គឺមានមុខងារធ្វើកសិកម្មនៅក្នុងភូមិភាគ ។ ពួកគេទាំងអស់គ្នា បានរត់ភៀសខ្លួនទៅកាន់ស្វាយរៀង ដើម្បីបានជួបជុំជាមួយឪពុកសាក្សី ។ ពួកគេត្រូវបាននាំយកទៅលាច នៅពោធិ៍សាត់ ហើយពួកគេត្រូវបានគេសម្លាប់ ។ អ្នកដែលមកពីភូមិភាគបូព៌ាគឺត្រូវគេប្រហារជីវិតចោលទាំងអស់ មិនថាប្រជាជនស៊ីវិល ឬមិនស៊ីវិលនោះទេ ។

នៅពេលដែល វៀតណាមបញ្ជូនទាហានមកទាក់ទងជាមួយសាក្សី សាក្សីកំពុងស្ថិតនៅក្នុងព្រៃនៅឡើយ ពីព្រោះ ប៉ុល ពត នៅតែបន្តសម្លាប់មនុស្ស ។ សាក្សីនៅក្នុងព្រៃ គឺដើម្បីវាយប្រហារ ប៉ុល ពត ។ បើសិនសាក្សីមិនសហការជាមួយវៀតណាមនោះទេ ប៉ុល ពត នឹងសម្លាប់មនុស្សទាំងអស់ ។

### បច្ចុប្បន្ន និងអតីតអ្នកនយោបាយ

ក្រុមមេធាវីការពារក្តី នួន ជា លោក វិកទ័រ កូប៉េ មិនរំពឹងបន្តធ្វើការសួរចម្លើយរហូតដល់ថ្ងៃច័ន្ទនោះទេ ។ លោកមេធាវី វិកទ័រ កូប៉េ បានសួរទៅកាន់សាក្សីថា តើគាត់ស្គាល់ ហេង សំកៃ ដែរឬទេ ដែលសាក្សីបានឆ្លើយថា ស្គាល់ ។ ហេង សំកៃ ជាបងប្រុសរបស់ ហេង សំរិន ហើយ ហេង សំកៃ បានចូលរួមរណសិរ្សជាមួយសាក្សី ប៉ុន្តែសាក្សីមិនបានដឹងពីមុខងារ និងតួនាទីច្បាស់លាស់របស់ សំកៃ នោះទេ ។

លោកមេធាវី វិកទ័រ កូប៉េ បានរៀបរាបថា សំកៃ ជាប្រធានគ្រប់គ្រងភូមិភាគបូព៌ា ។ សាក្សីបានបន្តថា គាត់មិនមានទំនាក់ទំនងជាមួយយោធានៅក្នុងភូមិភាគនោះទេ ហើយសាក្សីបានជួប សំកៃ តែនៅក្នុងព្រៃប៉ុណ្ណោះ ដូច្នេះហើយគាត់មិនបានដឹងពីតួនាទី ឬមុខងាររបស់ សំកៃ នោះទេ ។

លោកមេធាវី កូប៉េ បានបន្តថា ជនជាតិអាមេរិកធ្លាប់បានសម្ភាសជាមួយ ហេង សំកៃ នៅឆ្នាំ១៩៨១ ។ សំកៃ បាននិយាយថា វាមិនមែនជារឿងងាយទេដែលពួកយើងអាចផ្តួលរំលំ ប៉ុល ពត បានដោយខ្លួនឯង ដូច្នេះហើយ ទើបពួកយើងត្រូវការការគាំទ្រពីវៀតណាម ។ សាក្សីបានឆ្លើយតបថា គាត់បានជួប សំកៃ ក្នុងរយៈពេលខ្លីប៉ុណ្ណោះ ហើយនៅក្នុងព្រៃ ពួកគេមានតែឆ្ងាំងបាយទេ ។

សាក្សីបន្តថា គាត់មិនមានទាហានច្រើនទេនាពេលនោះ ហើយគាត់រត់ភៀសខ្លួនដើម្បីបានរស់ប៉ុណ្ណោះ ។ លោកមេធាវី កូប៉េ បានសាកសួរបន្តទៀតថា តើសាក្សីមានធ្លាប់បានឮពីការប៉ុនប៉ងចង់ផ្តួលរំលំ ប៉ុល ពត ដែរឬទេនៅឆ្នាំ១៩៧៨? សាក្សីបានឆ្លើយថា វាជាពាក្យរបស់ សំកៃ ខ្លួនឯងនោះទេ ។ ទោះបីជាយ៉ាងណាក៏ដោយ សាក្សីជាអ្នកទាក់ទងជាមួយវៀតណាមនៅភូមិកន្ទួត ។ រណសិរ្សត្រូវបានបង្កើតឡើងដោយមានជំនួយពីទីក្រុងហូជីមិញ ។

លោកមេធាវី កូប៉េ បានបន្តថា សាក្សីធ្លាប់បានលើកឡើងពីឈ្មោះ ប៉ុល សារឿន តើ ប៉ុល សារឿន ជានរណា? សាក្សីបានបន្តថា គាត់មិនបានដឹងពីតួនាទីរបស់ ប៉ុល សារឿន នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះទេ ហើយគាត់បានជួប ប៉ុល សារឿន តែនៅក្នុងព្រៃប៉ុណ្ណោះ ។ សាក្សីមិនបានដឹងថា ប៉ុល សារឿន នៅអត្តភាពយោធាមួយណានោះទេ ហើយបច្ចុប្បន្ន ប៉ុល សារឿន ធ្វើការជាមួយយោធា ។

លោកមេធាវី កូប៉េ បានសួរបន្តទៀតថា តើសាក្សីស្គាល់ គន់គីម ដែរឬទេ? សាក្សីបានឆ្លើយថា គាត់បានស្គាល់ គន់គីម នៅពេលដែលគាត់រស់នៅក្នុងវត្ត ក្រោយពីពេលរំដោះរួច ។ សាក្សីមិនបានជួប គន់ គីម នៅក្នុងឆ្នាំ១៩៧៨ នោះទេ ហើយសាក្សីក៏មិនធ្លាប់ស្គាល់ ហែម សាមីន ដែរ ។ សាក្សីធ្លាប់បានជួប ប៉ែន សុវណ្ណ តែម្តងគត់នៅមេមត់ ដែលក្នុងពេលនោះ សាក្សីបាន

ឃើញ ប៉ែន សុវណ្ណ កំពុងបើកបរយានយន្ត ហើយសាក្សីក៏បានសួរឈ្មោះរបស់គាត់ ។

លោកប្រធានបានសួរថា តើសាក្សីស្គាល់ យុក ពៅ ដែរឬទេ? សាក្សីបានឆ្លើយថាគាត់ធ្លាប់ឮឈ្មោះនេះ ប៉ុន្តែគាត់មិនដែលបានជួបនោះទេ ។ សាក្សីក៏ធ្លាប់ឮឈ្មោះ ប៊ូ ថង ដែរ ប៉ុន្តែគាត់មិនធ្លាប់បានជួបដូចគ្នា ។ សាក្សីស្គាល់ ជា ស៊ីម ។ ខ្ញុំស្គាល់ ជា ស៊ីម ច្បាស់ណាស់ ឈ្មោះកំណើតរបស់គាត់គឺ ជា សាឡាត់ ហើយគាត់ជាអធិការវត្តស្រុក ។ ជា ស៊ីម ត្រូវបានគេស្គាល់ថាជាតាថ្មោងស ហើយក្រោយមកទៀតឈ្មោះ ជា ស៊ីម ។ លោកប្រធានបានសួរអំពីប្រពន្ធរបស់ ជា ស៊ីម ហើយសាក្សីបានឆ្លើយថា ប្រពន្ធ ជា ស៊ីម មិនមានអ្វីទាក់ទងជាមួយ សោ ភឹម នោះទេ ។

លោកមេធាវី កូប៉េ បានសួរបន្តថា តើគាត់ស្គាល់ កែវ ចិន្តា ដែរឬទេ? សាក្សីបានឆ្លើយថា គាត់ធ្លាប់បានឮឈ្មោះនេះនៅក្រោយការរំដោះ ប៉ុន្តែគាត់មិនដែលបានជួប កែវ ចិន្តា នោះទេ ។ លោកមេធាវី កូប៉េ បានសួរបន្តទៀតថា តើគាត់គឺជាប្រធាននៅក្នុងសវនាការកំបាំងមុខ ប្រឆាំង ប៉ុល ពត និង អៀង សារី មែនទេ? សាក្សីស្គាល់ អ៊ុក ប៊ុនឈឿន ច្បាស់ណាស់ ។ ពួកគេនៅព្រៃជាមួយគ្នា និងធ្វើការរួមគ្នា ។ នៅពេលដែលសាក្សីជិះទូកម្តាកចក្រទៅបង្កើតទាហាន អ៊ុក ប៊ុនឈឿន ក៏ទៅជាមួយគាត់ដែរ ។ សាក្សីស្គាល់ ម៉ាត់ លី ប៉ុន្តែគាត់គ្មានទំនាក់ទំនងជាមួយគ្នានោះទេ ។ ម៉ាត់ លី ជាជនជាតិចាម នឹងជាអតីតសមាជិកសភា ប៉ុន្តែគាត់បានស្លាប់បាត់ហើយ ។

លោកមេធាវី កូប៉េ បានបន្តសួរអំពីអង្គប្រជុំរបស់ពួកគេក្នុងការបង្កើតរណសិរ្ស ។ សាក្សីបានឆ្លើយថា ភាគីទាំង២ កម្ពុជា និងវៀតណាមបានព្រមព្រៀងគ្នា ។ លោកមេធាវី កូប៉េ បានសួរបន្តថា តើមានកិច្ចប្រជុំពីរមែនទេ? ដែលមួយនៅស្នួល និងមួយទៀតនៅទីក្រុងហូជីមិញ? សាក្សីបានបន្តថា អង្គប្រជុំនៅទីក្រុងហូជីមិញ គឺដើម្បីរៀបចំយុទ្ធសាស្ត្ររណសិរ្ស ហើយអង្គប្រជុំនៅស្នួល គឺមានព្រះសង្ឃ និងប្រជាជនស៊ីវិល ដែលគាំទ្ររណសិរ្ស ២ធ្នូ ។

កិច្ចប្រជុំនៅទីក្រុងភ្នំពេញសំខាន់ ផ្តោតទៅលើការព្រមព្រៀងគ្នារវាងភាគីទាំងពីរ កម្ពុជា និងវៀតណាម ។ លោកមេធាវី កូប៉េ បានសួរថា តើមនុស្សដែលបានរៀបរាប់ឈ្មោះពីខាងដើមមានបានចូលរួមក្នុងអង្គប្រជុំនៅទីក្រុងហូជីមិញដែរឬទេ? សាក្សីបានបន្តថា អ្នកដែលចូលរួមក្នុងរណសិរ្ស២ធ្នូនៅស្នួល គឺដើម្បីផ្សព្វផ្សាយព័ត៌មាន ។ នៅពេលនោះមានមនុស្សច្រើនណាស់បានចូលរួមរាប់រយរាប់ពាន់នាក់ ហើយអង្គប្រជុំនៅពេលនោះគឺធ្វើនៅក្នុងចម្ការកៅស៊ូ ។ នាពេលនោះ ភ្លេងជាតិថ្មីត្រូវបានគាត់តែងឡើងដោយ ចាន់ ដែលជាអ្នកសម្តែងសិល្បៈនៅភូមិភាគបូព៌ា ។ ពេលនោះក៏មានទង់ជាតិថ្មី និងមន្ត្រីដែលមានឋានៈខ្ពស់ជាច្រើន ប៉ុន្តែសាក្សីមិនបានស្គាល់ឈ្មោះពួកគាត់ទាំងនោះទេ ។

លោកមេធាវី កូប៉េ បានចោទសួរថា តើឈ្មោះ ឡេ ឌឹកថូ មានន័យអ្វីសម្រាប់គាត់ដែរឬទេ? សាក្សីបានឆ្លើយថា គាត់ធ្លាប់ឮឈ្មោះនេះ ហើយមនុស្សម្នាក់នេះជាជនជាតិវៀតណាម ប៉ុន្តែសាក្សីមិនធ្លាប់បានជួបជននេះនោះទេ ។

លោកមេធាវី កូប៉េ បានសួរថា តើសាក្សីធ្លាប់បានឃើញ ហ៊ុន សែន ដើរទៅអបអរសាទរ ឡេ ឌឹកថូ ដែរឬទេ? សាក្សីបានឆ្លើយថា គាត់មិនធ្លាប់ឃើញនោះទេ ។

បន្តទៅកាន់ប្រធានបទថ្មីមួយទៀត លោកមេធាវី កូប៉េ បានសួរអំពីសារទូរលេខដែលចុះហត្ថលេខាដោយ ឈុន ដែលអង្គជំនុំជម្រះបានបង្ហាញសាក្សីនាពេលមុននេះ ។ សាក្សីបានបដិសេធចំពោះឈ្មោះ ឈុន ជាឈ្មោះក្លែងក្លាយរបស់ សោ ភឹម ហើយសាក្សីបន្តថា ឈ្មោះក្លែងក្លាយរបស់ សោ ភឹម គឺ សោ ចាន់ ។ សាក្សីបាននិយាយថា ខ្ញុំមិនជឿអ្នកនោះទេ ។

លោកមេធាវី កូប៉េ បានសួរបន្តទៀតថា តើកម្មាភិបាលវៀតណាម ហៃ សូ មានន័យអ្វីសម្រាប់សាក្សីទេ ប៉ុន្តែសាក្សីបានបដិសេធ ។ សាក្សីមិនបាននិយាយថា ឃើញ សោ ភឹម និយាយជាមួយជនជាតិវៀតណាមណាម្នាក់នោះទេ ។ ត្រង់ចំនុចនេះ លោកប្រធានបានផ្អាកអង្គជំនុំជម្រះ ហើយនឹងបន្តអង្គជំនុំជម្រះនេះនៅថ្ងៃស្អែកទី២ ខែវិច្ឆិកា ឆ្នាំ២០១៦ ជាមួយនឹងការបង្ហាញឯកសារសំខាន់ ។

សាក្សីត្រូវត្រឡប់មកផ្តល់សក្ខីកម្មម្តងទៀតនៅថ្ងៃច័ន្ទទី៧ ខែវិច្ឆិកា ២០១៦ ។

**លីអូនី គីខេស្តី**

# ថ្ងៃដែលចងចាំ

បើយើងរំឭកអំពីរបបកម្ពុជាប្រជាធិបតេយ្យ ឬជាទូទៅហៅថា របបខ្មែរក្រហម មានព្រឹត្តិការណ៍ពីរដែលអ្នករស់រានពីរបបនេះនៅចងចាំ ។ ទីមួយ ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ជាថ្ងៃដែលខ្មែរក្រហមវាយរំដោះ និងគ្រប់គ្រងប្រទេសទាំងស្រុង និងទីពីរថ្ងៃ ៧ ខែមករា ឆ្នាំ១៩៧៩ ជាថ្ងៃដែលប្រជាជន និងប្រទេសកម្ពុជាត្រូវបានរំដោះចេញពីការកាប់សម្លាប់របស់ខ្មែរក្រហម ។

ខែមេសា (ឆ្នាំ១៩៧៥) ជាខែដែលប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស ប្រារព្ធបុណ្យចូលឆ្នាំប្រពៃណីជាតិ ។ ទោះបីជាអំឡុងពេលនោះមានការប្រយុទ្ធគ្នារវាងកងទ័ព លន់ នល់ និងកម្លាំងតស៊ូរបស់ខ្មែរក្រហមក៏ដោយ ក៏ប្រជាជនម្នាក់ៗរៀបចំពិធីទៅតាមប្រពៃណីជាតិរបស់ខ្លួនរហូតបញ្ចប់ ។ ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ កងទ័ពរំដោះខ្មែរក្រហមបានវាយរំដោះ និងគ្រប់គ្រងទីក្រុងភ្នំពេញ ។ ប្រជាជនរស់នៅទីក្រុង មានក្តីរីករាយយ៉ាងខ្លាំង ព្រោះអ្នកគ្រប់គ្នាគិតថា សង្គ្រាមត្រូវបានបញ្ចប់ហើយ ។ ម្នាក់ៗចេញមកឈរខាងមុខផ្ទះ និងប្របមាត់ផ្លូវប្រកបដោយទឹកមុខរីករាយ ដើម្បីទទួលស្វាគមន៍កងទ័ពរំដោះ ។ នៅមុខផ្ទះនីមួយៗមានចងទង់ជ័យស ជាសញ្ញានៃសន្តិភាព ។ ប៉ុន្មានម៉ោងក្រោយមក សំឡេងហ៊ោរកញ្ជ្រៀវប្រកបដោយក្តីរីករាយ ប្រែក្លាយជាសំឡេងនៃការសំឡុត គំរាមកំហែងពីសំណាក់យោធាខ្មែរក្រហមទៅលើប្រជាជន ។ ប្រជាជនម្នាក់ៗស្រឡាំងកាំងនឹងកាយវិការដាច់ណាត់ និងបញ្ជាឲ្យចាកចេញពីផ្ទះរយៈពេលខ្លី ។ ថ្ងៃ១៧ មេសា ១៩៧៥ ជាថ្ងៃដែលប្រជាជនរស់នៅទីក្រុង ក៏ដូចជានៅតាមទីប្រជុំជនទូទាំងប្រទេសចាកឆ្ងាយពីផ្ទះសម្បែង បែកបាក់គ្រួសារ និងមនុស្សជាទីស្រឡាញ់ ។ ប្រជាជនម្នាក់ៗត្រូវខ្មែរក្រហមបង្ខំឲ្យចេញពីផ្ទះ ទៅរស់នៅទីជនបទចុងកាត់មាត់ញកជាមួយនឹងជីវភាពមួយយ៉ាងលំបាក ។ ប្រជាជនបានបាត់បង់នូវសិទ្ធិសេរីភាព និងក្លាយជាទាសករក្នុងគុកឥតជញ្ជាំងរបស់ខ្មែរក្រហម ។

អស់រយៈពេល៣ឆ្នាំ ៨ខែ និង២០ថ្ងៃ ដែលប្រជាជនកម្ពុជារាប់លាន់នាក់ត្រូវបានខ្មែរក្រហមដាក់ឲ្យរស់នៅក្រោមលក្ខខណ្ឌជាមនុស្ស ។ ប្រជាជនស្លូតត្រង់ជាង២លាននាក់ត្រូវបានស្លាប់ដោយការធ្វើការហួសកម្លាំង ជំងឺ បរិភោគមិនគ្រប់គ្រាន់ និងសម្លាប់ ។

ក្រោយថ្ងៃ៧ មករា ឆ្នាំ១៩៧៩ ប្រទេសកម្ពុជា ក៏ដូចជាប្រជាជនកម្ពុជា ត្រូវបានរំដោះរួចផុតពីរបបវាលពិឃាតមួយនេះដោយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាម ។ ៣៨ឆ្នាំកន្លងមកនេះ ពីប្រទេសមួយដែលសល់តែគំនរផេះផង់ និងអំពើប្រល័យពូជសាសន៍ បានផ្លាស់ប្តូរ និងអភិវឌ្ឍគួរជាទីកត់សម្គាល់ ។ ទាំងអ្នកដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម និងអ្នកជំនាន់ក្រោយ សុទ្ធតែបានទទួលនូវការបាត់បង់របស់ខ្លួនមកវិញ ទោះតិច ឬច្រើនក្តី ។ ប្រជាជនមានសិទ្ធិកសាងគ្រួសារជាថ្មី រស់នៅជួបជុំគ្រួសារ ប្រកបរបរដែលខ្លួនចង់ធ្វើ និងគោរពប្រណិប័តន៍សាសនាផ្សេងៗ ហើយអ្វីៗទាំងអស់នេះ ដែលកន្លងមកត្រូវបានខ្មែរក្រហមដកហូតយកទាំងស្រុង សូម្បីតែភាពជាម្ចាស់នៃជីវិតខ្លួនឯង ។

ទោះបីជាបច្ចុប្បន្ននេះ មនុស្សមួយចំនួនបដិសេធមិនទទួលស្គាល់ថ្ងៃ៧មករា ព្រោះគិតថា ៧មករា ជាថ្ងៃដែលវៀតណាមចូលមកឈ្លានពានកម្ពុជាក៏ដោយ ទាំងនេះគ្រាន់តែជាទស្សនៈផ្ទាល់របស់អ្នកទាំងនោះដែលបានលើកឡើងក្រោមហេតុផលផ្សេងៗ ។ ប៉ុន្តែ អ្នកគ្រប់គ្នាមិនអាចបដិសេធថា គ្មានរបបប្រល័យពូជសាសន៍នៅកម្ពុជាទេ ។ ជាក់ស្តែង តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានកាត់ទោសមេដឹកនាំខ្មែរក្រហមបីនាក់រួចមកហើយ ។ កាំង ហ្កេកអ៊ាវ ហៅ ឌុច អតីតប្រធានមន្ទីរស-២១ ត្រូវបានតុលាការកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ហើយ ខៀវ សំផន និង នួន ជា ក៏ត្រូវបានតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចេញសាលដីកាសម្រេចចុងក្រោយ ដោយកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិតដូចគ្នា កាលពីថ្ងៃ២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កន្លងទៅនេះដែរ ។ **ធាន សារៈមុនិន្ទ**

# កេរដំណែលផេះផង់សល់ពីរបបខ្មែរក្រហម

***(តពីលេខមុន)***

***៣.កងចល័ត***

យុវជន និងយុវនារីភូមិថ្នល់តាសិត គេឲ្យសហការណ៍គ្នាធ្វើការងាររួមនៅក្នុងភូមិ មានដូចជា ដកសំណាប ស្ទូងស្រូវ ច្រូតកាត់ បោកបែនស្រូវ ។ល ។ មួយរយៈក្រោយមក បានធ្វើឲ្យមនុស្សស្គាល់គ្នាទៅវិញទៅមក ហើយក៏ឈានទៅដល់ការសាមគ្គីគ្នាក្នុងភាតរភាពទៀតផង ។ រដូវច្រូតកាត់បានចូលមកដល់ ពេលគឺក្រោយពីបានធ្វើការច្រូតកាត់ស្រូវក្នុងភូមិបានមួយចំនួនមក ទិសអង្គការបានតម្រូវឲ្យកងយុវជន និងយុវនារីភូមិធ្វើការចល័ត ជួយគ្នាពីភូមិមួយទៅភូមិមួយទៀត ច្រូតកាត់ស្រូវក្នុងទូទាំងសង្កាត់គោកធ្លកក្រោមទាំងមូល ។ ប្អូនស្រី សៀវ សុវុត្ថា បានសុំការអនុញ្ញាតពីម្តាយយើង ដោយសុំប្តូរឈ្មោះទៅជា សៀវ សុវុតថៃ ទៅវិញ ដើម្បីឲ្យជួនគ្នាជាមួយក្មេីម្រាក់របស់ខ្លួន ។ ទោះបីជាមានឈ្មោះថាជាកងចល័តសង្កាត់ក៏ពិតមែន តែការធ្វើការងារ ការស្នាក់នៅ និងការហូបចុកគឺនៅស្ទួនតួតាមភូមិដដែល ។ ទន្ទឹមគ្នានោះ គេមានប្រធាន និងអនុប្រធានចល័តសង្កាត់ដោយឡែកមួយទៀតសម្រាប់ត្រួតត្រា និងគ្រប់គ្រងពីលើកងយុវជនយុវនារីនៅតាមភូមិនីមួយៗ ។ ប្រសិនបើច្រូតកាត់នៅភូមិក្បែរគ្នា គឺយើងអាចដើរមកដេកនៅតាមផ្ទះរៀងៗខ្លួនវិញបាន ដុយទៅវិញ បើច្រូតនៅភូមិឆ្ងាយ គឺតម្រូវឲ្យយើងដេកនៅទីនោះតែម្តង ។ យុវជនគឺគេនាំគ្នាចងអង្រឹងដេកនៅតាមក្រោមផ្ទះអ្នកភូមិ និងចំណែកនារីៗ គឺពួកគេឡើងទៅសម្រាកនៅលើផ្ទះ ។ នៅពេលយប់ចូលមកដល់ គ្រប់ផ្ទះត្រូវបានបំភ្លឺដោយភ្លើងចន្លុះ ឬបើពុំដូចនោះទេ គឺគេដុតចំណាំងឈើដែលចាំងដោយពូថៅចេញមកពីខ្លឹមដើមឈើតាត្រាវក៏បានដែរ ។ កុំថាឡើយ ប្រេងម៉ាស៊ូតដុតបំភ្លឺនៅពេលយប់នោះ សូម្បីតែសាំងសម្រាប់ប្រើចាក់ដែកកេះក៏គ្មានដែរ គឺគេប្រើប្រេងកាតដីកម្រចាក់ដែកកេះជំនួសវិញ ហើយបើអ្នកនៅស្រុកទន្លេ គេអុជខ្លាញ់ត្រីបំភ្លឺនៅពេលយប់ ។ នៅឃុំកំពង់ឃ្លាំងក្នុងស្រុកសូទ្រនិគម គេយកខ្លាញ់ត្រីប្រើទាំងបន្ទុំទៅលើម៉ាស៊ីនកាណូត ជំនួសឲ្យប្រេងម៉ាស៊ូតបានដែរ ។ យុវជន និងយុវនារី មានភារកិច្ចជាអ្នកច្រូតកាត់តែប៉ុណ្ណោះ ឯចំណែកការដឹកជញ្ជូនកណ្តាប់ស្រូវ គឺជាការងាររបស់សហករណ៍សាម៉ីនៅតាមភូមិនីមួយៗជាអ្នកធ្វើ ។ ថ្វីត្បិតតែក្រខ្វត់ម្ហូប គឺផ្សៀតត្រីប្រាប្រៃប្រហៀមមួយកន្ទុយ ស្ងោរម្ជូរទម្ពូងមួយខ្ទះត្នោតជាប្រចាំព្រឹកល្ងាចបរិភោគមនុស្សរាប់សិបនាក់ក៏ពិតមែន តែយើងបានបាយខ្ទះត្នោតបរិភោគឆ្អែត ។ ពុំដែលស្គាល់ជាតិស្ករ ខ្ទឹមម្រេច សម្រាប់បង់សម្លនោះឡើយ ។ នេះគឺយើងមិន និយាយដល់មេ្យាស៊ីបនោះទេ ដែលហួសសមត្ថភាពយើងកាន់តែឆ្ងាយទៅទៀត ។ នៅឯសហករណ៍ ក៏គេធ្វើការច្រូតកាត់ស្រូវដូចគ្នាដែរ នៅក្បែរៗភូមិ ចំណែកកុមារាកុមារីនៅតាមបណ្តាភូមិ ក៏ត្រូវបានប្រមូលផ្តុំដោយចងក្រងជាកងចល័តកុមារ ។ ការកំណត់អាយុក្មេងៗឲ្យចូលជាកុមារ ឬចូលជាយុវជន យុវនារី គេគ្មានស្ថិតិមើលទេ គឺអាស្រ័យដោយប្រធានសហករណ៍ជាអ្នកកំណត់ គឺពុំអាចប្រកែកបានឡើយ ។ កងកុមារ គឺមានមេកងគ្រប់គ្រង ដែលគេដាក់ឈ្មោះជាឡប់ឡែឲ្យថា គ្រូៗ ។ គ្រូនេះគឺពុំមែនជាគ្រូបង្រៀន លេខ អក្សរ នព្វន្តអ្វីឡើយ គឺគេបង្រៀនឲ្យកុមារា និងកុមារី ដើររើសអាចម៍គោនៅតាមវាលស្រែ ចិញ្ច្រាំដីដើមទន្ទ្រានខែត្រ ឬដើររើសកួរស្រូវជាដើម ព្រោះពួកគេពុំដែលឃើញមានសៀវភៅមើល និងសៀវភៅសរសេរឡើយ ។ ប្អូនស្រី សៀវ សុវុត្ថន បានស្ម័គ្រចិត្តចូលកងចល័តកងកុមារដោយខ្លួនឯង ព្រោះមានកុមារីពីរនាក់ជាពួកម៉ាកគេស្រាប់ គឺម្នាក់ឈ្មោះ លីង និងម្នាក់ទៀតឈ្មោះ ហ៊ាក ចូលក្នុងកងកុមារមុន ។ ក្រោយពីការច្រូតកាត់ស្រូវវស្សាត្រូវបានបញ្ចប់ គេឲ្យបន្តទៅច្រូតកាត់ស្រូវវារនៅវាលព្រៃនាមខាងក្រោមថ្នល់ជាតិបន្តទៀត ។ ការច្រូតកាត់ស្រូវវស្សា និងការច្រូតកាត់ស្រូវឡើងទឹកគឺរយៈកាលនេះ ធាតុអាកាសត្រជាក់ ហើយយើងទាំងអស់គ្នាពុំមានសម្លៀកបំពាក់ក្រាស់ៗស្លៀកពាក់ទេ តែដោយមានការបញ្ចេញកម្លាំងខ្លាំងនោះ ធ្វើឲ្យយើងទប់ទល់នឹងធាតុអាកាសត្រជាក់បាន

មួយកម្រិតដែរ ។ ការចល័តទៅច្រូតកាត់ស្រូវវារនេះ គឺយើងត្រូវច្រូតស្រូវដែលស្ថិតនៅក្នុងភូមិសាស្ត្ររបស់បណ្តាភូមិដែលនៅក្នុងទឹកដីរបស់ឃុំគោកធ្លកក្រោមតែប៉ុណ្ណោះ ។ ដោយឡែក មហាជនដែលស្ថិតនៅក្នុងភូមិថ្នល់តាសិតប្រុសស្រីមួយចំនួនធំក៏បានចុះទៅជួយសម្រុកក្នុងការច្រូតកាត់នេះដែរ ដែលមានចម្ងាយពីភូមិថ្នល់តាសិត មិនតិចជាង១០គីឡូម៉ែត្រនោះឡើយ ។

យុវជន និងយុវនារីភូមិថ្នល់តាសិត បានស្នាក់នៅក្នុងរោងជាមួយចាស់ៗដែលមកពីភូមិជាមួយគ្នា ចំណែក យុវជន និងយុវនារីដែលមកពីភូមិដទៃទៀតក៏រស់នៅជាមួយអ្នកដែលមកពីភូមិរបស់ខ្លួនដែរ ។ មានភូមិជាច្រើន ដែលតាំងជារោងស្នាក់នៅជុំវិញត្រពាំងគ្រោះគី និងត្រពាំងស្នែងក្តាន់ដែលស្ថិតនៅក្នុងផ្ទៃដីស្រូវវារនោះដែរ ។ ត្រពាំងទាំងពីរនេះ នៅឆ្ងាយពីគ្នាបន្តិច ហើយសម្បូរទៅដោយត្រីគ្រប់ប្រភេទប្រកបដោយរសជាតិឆ្ងាញ់ពិសា ដែលអាចចិញ្ចឹមយើងបានរហូតដល់ការច្រូតកាត់ត្រូវបានបញ្ចប់ ។ ចំណែកក្រុមចល័តកុមារពីបណ្តាភូមិ ក៏ត្រូវបានគេបញ្ជូនមកកាន់វាលស្រែវារនេះដែរដើម្បីឲ្យរើសកួរស្រូវវារ ហើយមានថ្ងៃមួយប្អូនស្រី សៀវសុវុត្ថន ចាប់បានអណ្តើកស្រែមេមួយក្បាលដែលស្ថិតនៅក្រោមជញ្ជ្រាំងស្រូវវារ ។ ប៉ុន្មានថ្ងៃមកទៀត រូបខ្ញុំជាមួយ លោក សាំង សួន (ត្រូវជាប្អូនប្រុសបង្កើតបន្ទាប់ពីសម្លាញ់ សាំង ស៊ាន) បានសុំអនុញ្ញាតពីមេកងដើម្បីទៅលេងផ្ទះមួយថ្ងៃ ហើយខ្ញុំក៏បានយួរអណ្តើកមេមួយក្បាលនោះមានទម្ងន់ជិតមួយគីឡូក្រាម យកទៅជាមួយផង ។ លុះដល់គម្រប់ថ្ងៃត្រូវវិលត្រឡប់ទៅកាន់វាលស្រូវវារវិញ ពីរនាក់លោក សាំង សួន យើងបានចេញដំណើរពីភូមិទៅប្រហែលជាម៉ោងជិតមួយរសៀល ។ យើងដើរកាត់វាល លិចចូលព្រៃចុះឡើងប្រហែលជា៨គីឡូម៉ែត្រ ទើបបានមកដល់គោកតាត្រាវឬមាត់វាលស្រែស្រូវវារ ។ នៅខាងស្តាំដៃយើង ឃើញមានទួលមួយពីចម្ងាយ ដែលលាតសន្ធឹងពីជើង (ជិតភូមិបាក់អង្រុត) ទៅត្បូង ព្រមទាំងមានដើមដូងលៃដុះនៅក្បាលទួល និងចុងទួល ឬដុះនៅក្បាល និងកន្ទុយមានសណ្ឋានដូចជាទូកអុំយ៉ាងដូច្នេះដែរ ដែលគេឲ្យឈ្មោះទួលនេះថា ទួលទូក-ង ។ ចំណែកនៅខាងឆ្វេងដៃយើងឯណោះវិញ ក៏មានទួលមួយផ្សេងទៀតដែរ តែមានទំហំធំជាង និងមានដើមឈើតូចធំដុះនៅជាច្រើន បានលេចឡើងនៅកណ្តាលវាលគេហៅថា ទួលពាក់យាម ។ រីឯកន្លែងដែលយើងទាំងពីរនាក់ កំពុងតែដើរនេះ ឃើញមានដំបូកអាចម៍មៀមដុះនៅរកេតរកូត នៅជិតនិងនៅឆ្ងាយពីគ្នា ហើយក៏មានវាលទំនេរជាច្រើនដែរ តែធ្វើស្រែពុំកើតទេ ដែលបុរាណនិយមហៅថា ស្រែគក់ទ្រូង ។ ដែលហៅថា ស្រែគក់ទ្រូង គឺជាតំបន់ដែលគ្មានទឹក ពោលគឺទឹកជំនន់មកពីលើក៏ធ្លាក់មកពុំដល់ និងទឹកទន្លេមកពីក្រោមក៏ឡើងមកពុំដល់ដែរ ។ កាលពីមិនទាន់រួមភូមិនៅឡើយ គឺនៅឆ្នាំ១៩៧៥ ដែលទឹកទន្លេទើបចូលមកដល់ និងលិចដើមស្រូវវារពាក់កណ្តាលភ្លៅនោះ បង លាន ណូរួមជាមួយនឹងបងប្អូនផ្ទះជិតខាង បានបរទេះគោមករាយមងត្រីស្លាតនៅឯនាយពីទីនេះបន្តិច ។ យប់នោះបង ណូ បានចងមុងសម្រាន្តនៅលើរទេះ ដោយលើកទូករទេះដាក់គងពីលើដំបូកអាចម៍មៀមមួយ ហើយក៏និទ្រាលង់លក់ម្នាក់ឯងទៅ ។ លុះដល់យប់ជ្រៅបន្តិច ស្រាប់តែគាត់យល់សប្តិឃើញក្នុងរស់ដោយឃើញនារីបាំម្នាក់ទ្រង់គ្រឿងអម្ពរពស្ត្រាល្អវិចិត្រផុសខ្លួនចេញមកពីដំបូកអាចម៍មៀមដែលដាក់រទេះគោពីលើនោះ ដើររាំទៅមកនៅលើទូករទេះនោះយ៉ាងរស់រវើក ។ នៅឆ្នាំដដែល គឺក្រោមនេះបន្តិច ខ្ញុំ និង បងណូ ដដែលបានបររទេះគោមួយពីរនាក់មករាយមងយកត្រីស្លាតនៅមាត់វាលស្រែស្រូវវារដែលសម្បូរទៅដោយសត្វមូស ។ យើងចងមុងមួយដេកនៅលើរទេះពីរនាក់ ព្រមទាំងយកកៅស៊ូការពារភ្លៀងពណ៌បៃតងធំមួយគ្របពីលើមុង ព្រោះនៅយប់នោះមានភ្លៀងធ្លាក់មកយ៉ាងខ្លាំង ។ លុះជិតភ្លឺ ខ្ញុំមានអារម្មណ៍ស្ពឹកដៃម្ខាងលើកពុំរួច ព្រោះដៃម្ខាងនោះនៅជាប់នឹងជើងមុង ហើយក៏នៅជាប់នឹងកៅស៊ូភ្លៀងដែលដក់ទឹកភ្លៀងទល់ភ្លឺត្រជាក់ដូចទឹកកកយ៉ាងដូច្នោះដែរ ។ នៅវាលស្រូវវារដែលទឹកទន្លេទើបហូរចូលមកលិចស្រូវថ្មីៗនេះ សម្បូរត្រីគួរសម គេអាចរាយមង ឬស្ទូចនៅកន្លែងសំបុកត្រីស្លាតក៏អាចបានត្រីយកទៅបរិភោគបានដែរ ។ ជំឈានដើរបកថយក្រោយរយៈពេល ៣ឆ្នាំ ៨ខែ និង២០ថ្ងៃរបស់ខ្មែរក្រហម គឺបានបន្សល់ទុកធនធានធម្មជាតិនៅក្នុងទឹក លើដី និងក្រោមដីតែប៉ុណ្ណោះ និងក្រៅពីនោះពួកគេបំផ្លាញខ្ទេចខ្ទីដល់ឫសគល់របស់មាតុភូមិនៃយើងឲ្យក្លាយទៅជាគំនរផេះផង់ ។

ពីរនាក់លោក សាំង សួន យើងដើរផងព្រមទាំងជជែកគ្នាលេងពីនេះពីនោះផង ក្នុងទិសដៅឆ្ពោះទៅកាន់ទួលពាក់យាមដើម្បី

រកម្លប់ជ្រក ព្រោះនៅតាមផ្លូវគ្មានដើមឈើដុះទេ ។ ពេលទៅដល់ទួលពាក់យាម យើងផ្តើមដើរឡើងពីទិសខាងជើងទួលតាមផ្លូវដើងមួយខ្សែក្រវេចក្រវៀន កាត់លើទួលទៅទិសខាងត្បូងបានបន្តិច នៅខាងឆ្វេងដៃមានស្រះឈូកមួយនៅក្បែរផ្លូវ ។ ទួលពាក់យាម មានរាងបួនជ្រុងទ្រវែង និងមានសណ្ឋានដីឡើងទួល ចុះទួលព្រមទាំងនៅចុងខាងត្បូងទួលមានដើមសំរោងធំមួយដើម ហើយក៏មានខ្ទមអ្នកតាមួយនៅពីក្រោមដើមឈើនោះដែរ ។ យើងឡើងចម្រាក់ដើរបានពាក់កណ្តាលទួល នៅខាងស្តាំដៃនៅមិនឆ្ងាយប៉ុន្មានពីផ្លូវ ឃើញមានដើមឈើមួយធំខ្ពស់ចោលម្លប់មក សមល្មមអាចឲ្យយើងអាចឈប់សម្រាកបាននៅទីនោះ ។ ដោយថ្ងៃខ្ពស់នៅឡើយបានធ្វើឲ្យយើងស្ទាក់ស្ទើរ និងប្រញាប់ប្រញាល់រួតរះបន្តដំណើរទៅមុខទៀតនោះ ក៏ប្រះខ្លួនដេកទន្ទឹមគ្នានៅលើស្លឹកឈើដោយយកសម្ពាយខោអាវរៀងៗខ្លួនធ្វើជាខ្នើយកើយ ។ ក្បាលយើងទាំងពីរនាក់ស្ថិតនៅទិសខាងត្បូង ចំណែកជើងយើងសំយុងចុះពីលើទួលបន្តិចបីដូចជាទម្រេតនៅលើកៅអីដែលមានបង្អែកយ៉ាងដូច្នេះដែរ ។

ក្រោយពីដេកលង់លក់យ៉ាងស្កប់ស្កល់មួយស្របក់មក យើងក៏ភ្ញាក់ដឹងខ្លួនឡើងវិញប្រដំប្រសងគ្នា នៅក្នុងស្ថានភាពចម្លែកនៅក្នុងចិត្តរៀងៗខ្លួន ព្រោះអម្បាញ់មិញយើងយល់សប្តិដាន់គ្នាស្ទើរតែទាំងស្រុងក្នុងហេតុការណ៍ដ៏កម្រជួបប្រទះមួយ ។ ការយល់សប្តិឃើញដូចភ្នែករស់ ក្នុងពេលតែមួយដូចគ្នានោះ គឺរូបខ្ញុំបានមើលឃើញសកម្មភាពទាំងអស់របស់លោក សាំង សួន ហើយចំណែកឯលោក សាំង សួន វិញ ក៏យល់សប្តិឃើញខ្លួនគាត់ធ្វើសកម្មភាពដូចដែលខ្ញុំយល់សប្តិឃើញនោះដែរ ។ តែខ្ញុំពុំបានឮសំឡេងលោក សាំង សួន គាត់និយាយឆ្លងឆ្លើយជាមួយមនុស្សទីពម្នាក់ផ្សេងទៀតទេ ។ មនុស្សចំណូលថ្មីដែលយើងឃើញនោះ គឺជាមនុស្សប្រុសវ័យចំណាស់ម្នាក់ មានសម្បុរខ្មៅមាឌធំដំបង អត់អាវក្បាលពោះកំប៉ោង ស្លៀកខោចេវថ្មេរប្រាំ ពណ៌សំពត់លោកសង្ឃជើងខោស្រុងនៅក្រោមក្បាលជង្គង់បន្តិច ។ មនុស្សខាងលើនេះបានដើរបែកចេញពីផ្លូវជើងលើទួលនោះមកឈរនៅទន្ទឹមគ្នានឹងក្បាលដំណេកលោក សាំង សួន សម្លឹងរង់ចាំមើលលោក សាំង សួន កំពុងស្រាយសំពាយខោអាវដើម្បីយករបស់អ្វីមួយចេញមកក្រៅ ។ វត្ថុដែលលោក សាំង សួន យកចេញមកនោះ បើតាមខ្ញុំមើលឃើញក្នុងយល់សប្តិ គឺជាកញ្ចប់ស្លឹកចេកដែលមានផ្អកត្រីប្រឡាក់លក្ខពណ៌ក្រហមយ៉ាងជាក់ច្បាស់ ។ ស្ថិតនៅក្នុងស្ថានភាពបែបនោះ យើងទាំងពីរនាក់មិនបង្អង់យូរឡើយ គឺនាំគ្នាប្រញាប់ប្រញាល់លើកសំពាយខោអាវដាក់នៅលើស្មា និងចាកចេញពីទីនោះទាំងទទឹងទិសដោយដើរសំដៅទៅកាន់កន្លែងស្នាក់នៅច្រូតស្រូវវាវវិញក្នុងក្តីភិតភ័យតក្កមា ។ នៅពេលកំពុងដើរតាមផ្លូវលោក សាំង សួន បាននិយាយមកកាន់ខ្ញុំថា គាត់ភ័យណាស់ដោយតាចាស់នោះចង់ទទួលទានបាយទ្រាប ហើយគាត់ផ្តើមនិយាយដោយពាក្យបែបគំរាមថា ក្នុងសំពាយខោអាវនេះ មានទំបាយទ្រាបស៊ីទេ? តែលោក សាំង សួន និយាយប្រកែកតបវិញដាច់អហង្ការ ។ លុះពេលលោក សាំង សួន ស្រាយបង្ខិចខោអាវស្របតាមបញ្ជារបស់មនុស្សចម្លែកនោះទៅ ស្រាប់តែឃើញមានបាយទ្រាបខ្ចប់ស្លឹកចេកមួយកញ្ចប់ដូចតានោះថាមែន ទើបបណ្តាលឲ្យលោក សាំង សួន មានការភិតភ័យគ្មានទីបញ្ចប់ ។ ខ្ញុំក៏បានប្រាប់ទៅលោក សាំង សួន ថា សុបិន្តដែលប្រកបដោយអមូតហេតុដែលកម្រនឹងកើតមានមកនេះ យើងមើលឃើញគ្នាទៅវិញទៅមកទាំងអស់គឺខុសគ្នាត្រង់តែរបស់នៅក្នុងកញ្ចប់ស្លឹកចេកប៉ុណ្ណោះ ។ ពេលដែលមកដល់កន្លែងស្នាក់នៅនាមាត់ត្រពាំងគ្រោះកីវិញ យប់បន្តិចយើងបានយករឿងពីថ្ងៃនោះនិយាយប្រាប់ចាស់ទុំនៅក្នុងភូមិដែលស្នាក់នៅក្បែរខាងគ្នា ។ ពួកគាត់បានប្រាប់មកយើងវិញថា មនុស្សប្រុសមាឌធំម្នាក់នោះ គឺគ្មានអ្នកណាក្រៅពីអ្នកតានៅទួលពាក់យាមនោះឡើយ ព្រោះយើងទៅដេកកន្លែងគេមិនបានប្រាប់ម្ចាស់អ្នកថែរក្សានៅទីនោះឲ្យគេបានដឹងជាមុន ទើបបានជាមានរឿងហេតុយ៉ាងដូច្នេះកើតឡើង ។ ពាក្យសម្តីទាំងនេះ គឺដូចជាការគិតរបស់ពួកយើងទាំងពីរនាក់ដែរ គឺក្រោយពេលដែលពួកយើងចាកចេញពីទួលពាក់យាមបានបន្តិចមក ។ ការច្រូតកាត់ស្រូវវាវប្រចាំឃុំគោកធ្លកក្រោមទាំងមូល ត្រូវបានបញ្ចប់ហើយក្រោយពេលឡើងមកដល់ភូមិវិញ កម្លាំងយុវជន និងយុវនារី គេឲ្យទៅលើកប្រព័ន្ធភ្លឺស្រែនៅតាមបណ្តាភូមិក្នុងឃុំគោកធ្លកក្រោមបន្តទៀត ។ ភ្លឺស្រែចាស់ គឺជាព្រំប្រទល់ដីស្រែកម្មសិទ្ធិតាមគ្រួសារនីមួយៗដែលមានតាំងពីយូរលង់មកហើយ ។ អង្គការខ្មែរក្រហម

បានផ្តើមធ្វើការរំលាយភ្លឺស្រែចាស់ ដោយរៀបចំភ្លឺស្រែថ្មីទៅជា
ប្រព័ន្ធភ្លឺស្រែក្រឡាចត្រង្គ និងមានប្រព័ន្ធប្រឡាយទឹកអមទៅ
ជាមួយផង ។ ការវាស់ដីស្រែបែងចែកជាក្រឡាចត្រង្គនេះ កុំថា
ឡើយម៉ាស៊ីនតូប៉ូ សូម្បីតែខ្សែម៉ែត្ររ៉ូឡូក៏គ្មានដែរ គឺគេប្រើខ្សែគោ
ឬខ្សែក្របីដើម្បីធ្វើការវាស់វែងតែប៉ុណ្ណោះ ។ ការលើកប្រព័ន្ធភ្លឺ
ស្រែស្រូវវស្សានេះ ជួនកាលដើរទៅលើកឆ្ងាយពីភូមិ តែយប់
ឡើងត្រូវវិលមកសម្រាកនៅកន្លែងដើមវិញ ដោយពុំអនុញ្ញាតឲ្យ
យើងដើរដេកពាសវាលពាសកាលបានឡើយ ។ នៅពេលធ្វើការ
ផ្លាស់ប្តូរការដ្ឋានម្តងៗ គេប្រើប្រាស់រទេះគោដើម្បីដឹកសម្ភារ
ចល័តទៅកាន់កន្លែងថ្មី និងចំណែកពួកយើងគឺស្ពាយសម្ពាយខោ
អាវដើរតាមពីក្រោយរទេះ ។ បើយើងទៅដល់កន្លែងថ្មីយឺតយ៉ាវ
ជាងគេ គឺត្រូវប្រឈមនឹងបានចបកាប់អស់ជម្រើសក្រោយគេ ។
ខ្ញុំធ្លាប់បានជួបប្រទះមួយដងដែរ គឺប៉ះចំចបកាប់មុខស្តឹកអត់មុត
ទទឹងមុខចបតូច ដៃវែងក្រាស់ហើយធ្ងន់ លើកភ្លឺស្រែដែលគេវាស់
ម៉ែត្រចែកគ្នាតាមបុគ្គលម្នាក់ៗ គឺពុំដែលរួចទាន់គេបានម្តងណា
ឡើយ ហើយថែមទាំងហេវហត់ខ្លាំងទៀតផង ។ កាលនោះ ប្រធាន
កងគឺជាក្រមុំចាស់ម្នាក់ឈ្មោះ ម៉ៅ រស់នៅភូមិទ័ពសៀម ។ ដោយ
ឡែក នៅខាងលើ (ទិសខាងជើង) ថ្នល់ជាតិលេខ៦តែបន្តិចទេ គេ
លើកភ្លឺធំ ហើយខ្ពស់ខុសគេ ស្របតាមដងផ្លូវជាតិ មានគម្លាតពី
គ្នា៤០ម៉ែត្រ ដែលគេនាំគ្នាហៅថា ភ្លឺ៤០ម៉ែត្រ ឬភ្លឺសែសិប ។
កាលនោះមានក្រុមចល័តចាស់ក្មេងមកពីឃុំល្វែងឫស្សីក្នុងស្រុកជី
ក្រែង មកលើកភ្លឺស្រែនិងស្នាក់នៅមួយរយៈខ្លីនៅក្នុងភូមិថ្នល់
គាសិតយើង ។ ក្នុងនោះ មានអ៊ំប្រុសម្នាក់ឈ្មោះ ម៉ៅ កាលពី
សម័យសង្គមរាស្ត្រនិយម គាត់ធ្លាប់បើកបរឡានឈ្នួលទៅមក
ពីដំដែកទៅឃុំកំពង់ឃ្លាំង (មានឡានពីរគ្រឿងទៅមកម៉ៅផ្តាច់) ។
នៅសម័យ លន់ នល់ ខ្ញុំធ្លាប់ឃើញអ៊ំ ម៉ៅ បើកបរឡានរបស់ក្រុម
ហ៊ុនស្បែកជើងផ្ទាត់ជីបតុង និងស្បែកជើងផ្ទាត់សញ្ញារូបក្តាន់នៅ
ក្នុងទីក្រុងភ្នំពេញ ដោយមានរូបសំណាកគំរូស្បែកជើងផ្ទាត់មួយ
សម្រាប់ធំដាក់តាំងនៅពីលើដំបូលឡានគាត់ទៀតផង ។ គ្រួសារ
របស់អ៊ំប្រុស ម៉ៅ ត្រូវបានគេជម្លៀសចេញពីទីក្រុងភ្នំពេញឲ្យមក
រស់នៅក្នុងឃុំល្វែងឫស្សី ស្រុកជីក្រែង ។ នៅពេលនោះ អ៊ំ ម៉ៅ
បានជួបឪពុកយើង ហើយពួកគាត់បានធ្វើការស្គាល់គ្នាទៅវិញទៅ
មកដោយក្តីនឹករឮកគ្នាពន់ពេកក្រៃ ព្រោះពួកគាត់បានបែកគ្នាជា
យូរមកហើយ ។ ក្រោយឆ្នាំ១៩៧៩ អ៊ំប្រុស ម៉ៅ និងក្រុមគ្រួសារ
ត្រូវបានបាត់ខ្លួននៅលើទឹកដីឃុំល្វែងឫស្សី ក្នុងស្រុកជីក្រែង ។
ក្នុងនោះដែរ កូនប្រុសរបស់អ៊ំម៉ៅឈ្មោះ រ៉េត បានធ្វើអត្តឃាត
ចង់សម្លាប់ខ្លួនពីរនាក់សង្សារសំណព្វចិត្តរបស់គេនៅក្នុងមូលដ្ឋាន
ដែលពួកគាត់រស់នៅ ។ នៅតាមបណ្តាភូមិ សុទ្ធសឹងតែមានក្រុម
អ្នកឡើងត្នោតរម្ងាស់ធ្វើស្ករដែរ តែពួកយើងកម្រដែលមានភ័ព្វ
វាសនាបានទទួលទានបង្អែមជាសមូហភាពបានម្តងណាឡើយ សូម្បី
តែសម្លនៅក្នុងខ្ទះត្នោតក៏គ្មានស្ករបង់ចូលឲ្យមានឱជារសដែរ ។
ដូច្នេះ នៅក្នុងខ្លួនមនុស្សយើងម្នាក់ៗមានជាតិស្ករតិចបំផុត ដែល
ជាហេតុនាំឲ្យជះឥទ្ធិពលទៅដល់ជាតិពន្ធុរបស់មនុស្ស យើងកាលពី
ជំនាន់ដ៏ខ្មៅងងឹតនោះ ។ យើងបានស្គាល់មុខគ្នាទៅវិញទៅមក
ពីភូមិមួយទៅភូមិមួយទៀតនៅក្នុងឃុំ តែពុំបានរាក់ទាក់គ្នាទេ
ព្រោះការងាររមមាញឹករៀងៗខ្លួននៅតាមបណ្តាភូមិដោយឡែកៗ
ពីគ្នា ។ យើងសង្កេតឃើញយុវជនអ្នកថ្មី១៧ មេសា មួយចំនួនត្រូវ
បានរងគ្រោះផ្លូវកាយ និងផ្លូវចិត្តធ្ងន់ធ្ងរពេករហូតដល់ស៊ូទ្រាំអត់
ធ្មត់តទៅទៀតពុំបាន ក៏បញ្ចេញនូវចំណេះដឹងទាំងអម្បាលម៉ាន
ដែលខ្លួនមានដើម្បីទាក់ទាញសមានចិត្តពីអ្នករស់នៅជុំវិញខ្លួន
ដូចជានិយាយភាសាបារាំង ឬអង់គ្លេស ព្រមទាំងបញ្ចេញក្បាច់តែ
ខ្វាន់ដូជាដើម ។ល ។ ក្រោយពីលើកភ្លឺស្រែបានមួយរយៈមក ទិស
អង្គការបានតម្រូវឲ្យយើងទៅជីកប្រឡាយលើកធ្វើជាទំនប់ដែល
ជាដៃរបស់ទំនប់ម្កាក់ ក្នុងឃុំគោកធ្លកលើ ដោយវាស់ដីចែកគ្នា
ទៅតាមភូមិ ។ ក្នុងការតម្រង់ទិសដៅរបស់ប្រឡាយទឹកនៅមុន
ពេលជីក គឺគ្មានប្រើអ្វីក្រៅពីភ្នែកទទេទាំងពីររបស់មនុស្សផ្ទាល់
នោះឡើយ ។ បើការជីកប្រឡាយលើកទំនប់នេះ ប៉ះចំក្នុងព្រៃ គឺ
គេឡើងទៅលើចុងឈើ និងមើលដោយភ្នែកទទេទៅកាន់ដើមឈើ
មួយទៀតដែលជាគោលដៅនៅឯនាយ ដែលមានដោតឈើតម្រុយ
មួយនៅខាងចុងដែរ ។ ក្រៅពីនេះគឺមានក្រុមអ្នកត្រាយព្រៃ៣-៤
នាក់ទៀត ជាអ្នកកាប់ឆ្ការព្រៃធ្វើជាគន្លង ទៅតាមការស្រែកបញ្ជា
ឆ្លងស្តាំពីមនុស្សដែលនៅលើចុងឈើ ។

**(តទៅលេខក្រោយ)**

**សៀង សុផុន**

# «សល់មួយគ្រាប់»

## រឿងរ៉ាវ គ្រួសារខ្ញុំ ក្នុងរបបដឹកនាំខ្មៅងងឹត

**(តពីលេខមុន)**

ពេលល្ងាច ម្ដាយខ្ញុំបានរៀបចំអាហារពេលល្ងាច ដូចសព្វដង ។ កូនៗទាំងអស់ រង់ចាំឪពុកត្រឡប់មកផ្ទះវិញ ដើម្បីញ៉ាំអាហារពេលល្ងាចជុំគ្នា ។ ជាធម្មតារៀងរាល់ពេលល្ងាច ប៉ាតែងត្រឡប់មកផ្ទះវិញ ប្រហែលម៉ោង៥ល្ងាច ។ ខ្ញុំគិតថា បងប្អូនប្រុសស្រីរបស់ខ្ញុំ ហាក់មិនទាន់បានចាប់ភ្លឹកអ្វីដែលកំពុងកើតឡើងនាពេលនោះទេ ។ យើងបានរង់ចាំឪពុកដោយអន្ទះសារបំផុត ចាំហើយចាំទៀតៗ ចាំរហូតដល់ថ្នាក់ម្ដាយខ្ញុំប្រាប់មកយើងទាំងអស់គ្នាឲ្យញ៉ាំអាហារ ដោយគ្មានវត្តមានរបស់ឪពុកខ្ញុំ ។ នេះជាលើកទីមួយសម្រាប់បងប្អូនប្រុសស្រីរបស់ខ្ញុំ ញ៉ាំអាហារដោយគ្មានវត្តមានឪពុកជាទីស្រឡាញ់ ។

ពេលយប់នោះ គ្មានភ្លើងអគ្គិសនីប្រើប្រាស់ទេ ។ សភាពការណ៍ក្នុងភូមិក៏ស្ងាត់ជ្រងំ ។ ម្ដាយខ្ញុំយកចង្កៀងប្រេងកាត ឬហៅថា ចង្កៀងម៉ាំងសុងពីរធំៗ មកដុតបំភ្លឺ ។ អ្នកជិតខាងមកបបួលម្ដាយខ្ញុំឲ្យចាកចេញជាមួយគេ ។ អ៊ុំស្រីខ្ញុំក៏មកប្រាប់ម្ដាយខ្ញុំម្ដងជាពីរដងឲ្យចាកចេញទៅស្រុកខាងគ្រួសារប្ដីរបស់គាត់ ។ តែម៉ាក់នៅតែនិយាយចាំប៉ាត្រឡប់មកសិន ។ អ៊ុំស្រីខ្ញុំមានកូនសរុប ៧នាក់ ។

អ្នកជិតខាងខ្លះបានចាប់ផ្ដើមចាកចេញតាំងពីថ្ងៃម្ស៉ិះ ។ ក្នុងចំណោមអ្នកជិតខាងទាំងប្រាំបីគ្រួសារ មានតែប៉ាខ្ញុំទេដែលធ្វើទាហាន ។ ក្រៅពីនោះគេធ្វើជាគ្រូបង្រៀន ធ្វើការផ្សារខាងរថភ្លើង និងប្រកបមុខរបរផ្សេងៗ ។

ខ្ញុំចាប់មានអារម្មណ៍កាន់តែសោកសៅទៅៗ គិតថារឿងអាក្រក់ហ្នឹង មុខជាកើតឡើងមិនខាន ។ ខ្ញុំមានការក្ដុកក្ដួល និងព្រួយជាខ្លាំង ។ ខ្ញុំមិនគិតថា ឪពុកខ្ញុំអាចនឹងមិនត្រឡប់មកវិញទេ ។ ប៉ុន្តែ ខ្ញុំគិតថា គាត់ប្រហែលជាជួបរឿងអាក្រក់ណាមួយ ឬត្រូវគេចាប់ដាក់ឃុំឃាំងផងក៏មិនដឹង ។

ម្ដាយ និងបងស្រីខ្ញុំទាំងពីរ បានចាប់ផ្ដើមរៀបចំអីវ៉ាន់ខ្លះៗដាក់ចូលវ៉ាលិស និងម្ហូបអាហារ អង្ករមួយចំនួន ។ បន្ទាប់មក បងប្អូនរបស់ខ្ញុំទាំងអស់ក៏នាំគ្នាចូលគេងអស់ ។ ម្ដាយខ្ញុំចាប់ផ្ដើមព្រួយបារម្ភជាខ្លាំង ។ ខ្ញុំដឹងថាគាត់មិនបានគេងមួយវិនាទីណាទេក្នុងយប់នោះ ហើយខ្ញុំក៏ដូចគាត់ដែរ ។ ខ្ញុំបានដើរចូលទៅឱបគាត់ ។ ខ្ញុំសង្កេតមើលទឹកមុខគាត់ក្នុងយប់នោះ ខ្ញុំមានការក្ដុកក្ដួល និងអាណិតម្ដាយខ្ញុំជាខ្លាំង ។ ខ្ញុំចង់ឲ្យការលំបាកក្ដុកក្ដួលទាំងនោះ កុំឲ្យធ្លាក់លើម្ដាយជាទីស្រឡាញ់របស់ខ្ញុំ ។ ខ្ញុំចង់ទទួលការរំលែកការលំបាកក្ដុកក្ដួល ។ នេះជាលើកទីមួយហើយ ដែលខ្ញុំឃើញម្ដាយខ្ញុំមានការក្រៀមក្រំ និងទុក្ខព្រួយដោយសាររង់ចាំឪពុកខ្ញុំ ។ តែឪពុកខ្ញុំក៏ឥតឃើញត្រលប់មកវិញជារៀងរហូត ។ ខ្ញុំចាំសម្ដីប៉ាប្រាប់ថា កូនប្រុសត្រូវរឹងមាំ មិនត្រូវយំ ហើយត្រូវដឹកនាំគ្រួសារ ពេលប៉ាមិននៅ ។ ខ្ញុំប្រឹងប្រែងធ្វើកិច្ចការទាំងនោះ តែទៅមិនរួច ។

### ក្រោយថ្ងៃ២០ មេសា ១៩៧៥

នៅថ្ងៃទី២១ ខែមេសា នៅតាមផ្លូវយើងបានឮស្ទូរគេនិយាយខ្សឹបខ្សៀវថា មានការសម្លាប់អតីតមន្ត្រីរាជការ និងនាយទាហាន ខេត្តពោធិ៍សាត់ នៃរបប លន់ នល់ ជាច្រើននៅបន្ទាយមួយទីតាំងទួលពោធិ៍ជ្រៃ ក្នុងស្រុកកណ្ដៀង ដោយពួកខ្មែរក្រហម ។ នាពេលនោះ ខ្ញុំហាក់ជឿក៏ដូចជាមិនជឿនូវអ្វីដែលគេនិយាយនៅតាមផ្លូវ ។ ខ្ញុំនៅតែគិតថា ឪពុកខ្ញុំនឹងត្រឡប់មកវិញឥឡូវនេះ ។ ខ្ញុំយករឿងគេនិយាយនៅតាមផ្លូវទាំងប៉ុន្មានទៅប្រាប់ម្ដាយខ្ញុំ ម្ដាយខ្ញុំក៏គិតអ៊ីចឹងដែរ ។ គាត់ស្រក់ទឹកភ្នែកមិនដឹងខ្លួន ។ សំណួរកើតឡើងមួយរំពេចសម្រាប់ខ្ញុំថា ហេតុអ្វីក៏ពួកគេត្រូវសម្លាប់មនុស្សដោយគ្មានហេតុផលមួយប៉ព្រិចភ្នែកយ៉ាងសាហាវដូច្នេះ ហើយដោយមិនអាណិតអាសូរយ៉ាងនេះ? តើពួកគេទាំងនោះជាជន

ជាតិអ្វី? សង្គ្រាមចប់ហើយ ខ្ញុំគិតពេញខួរក្បាលរបស់ខ្ញុំ ។ គ្មានចម្លើយ ។

អតីតមន្ត្រីរាជការដូចជាឪពុកខ្ញុំជាដើមបានទៅចូលរួមក្នុងពិធីប្រជុំផ្ទេរអំណាចនោះដោយស្មោះត្រង់ ទាំងដៃទទេ គ្មានអាវុធ គ្មានអ្វីទាំងអស់ ។ ដោយសម្អាងច្បាប់ជាតិ និងច្បាប់អន្តរជាតិជាធំ ។ គាត់គិតថានឹងទទួលបានសន្តិភាព ព្រោះសង្គ្រាមក៏បានបញ្ចប់ហើយដែរ ។

ខ្ញុំបានឃើញកាំភ្លើងវែងមួយដើម និងកាំភ្លើងខ្លីមួយដើមទុកចោលក្នុងបន្ទប់ឪពុកខ្ញុំ ។ កាលពីជំនាន់ លន់ នល់ ឪពុកខ្ញុំបានរៀបរាប់រឿងរ៉ាវល្អៗខ្លះ ដែលទាក់ទងទៅនឹងមេដឹកនាំខ្មែរក្រហមមួយចំនួនដូច លោក ខៀវ សំផន ថា គាត់ជាបញ្ញវន្តម្នាក់ ស្មោះត្រង់ គាត់បានធ្វើការសិក្សានៅប្រទេសបារាំង ដែលជាប្រទេសជឿនលឿន មានអរិយធម៌ខ្ពស់ ។ ឪពុកខ្ញុំមានគំនិតគិតឃើញតែអ្វីៗដែលល្អៗពី ខៀវ សំផន ។ ឪពុកខ្ញុំនិយាយប្រាប់អ្នកជិតខាងថា គ្រួសារគាត់ត្រៀមបរិច្ចាគទ្រព្យធនគ្រប់បែបយ៉ាងសម្រាប់អ្នកខ្វះខាត និងសង្គម ដោយមិនស្តាយទេ ដូចដែលគាត់ធ្លាប់ធ្វើកន្លងមកក្នុងពិធីបុណ្យទានម្តងៗ ។ វាក៏ប្រហែលជាដោយសារហេតុផលសម្អាងទៅលើច្បាប់ ទៅលើការជឿជាក់ទុកចិត្តទាំងអស់នោះហើយ ដែលធ្វើឲ្យឪពុកខ្ញុំ គាត់សម្រេចចិត្តដោយមិនរួញរាទៅចូលរួមក្នុងពិធីនោះទាំងមានជំនឿទុកចិត្តខ្លាំង និងទទួលខុសត្រូវ ។ បើទោះបីជាម្តាយខ្ញុំ និងអ្នកជិតខាងបានប្រាប់គាត់ និងផ្តល់យោបល់យ៉ាងណាក៏ដោយ ។

ពេលយប់ ភាគច្រើនឪពុកខ្ញុំឧស្សាហ៍ស្តាប់វិទ្យុសំឡេងខ្មែរក្រហម ដែលធ្វើការផ្សាយចេញពីទីក្រុងប៉េកាំង ។ ម្តាយខ្ញុំហាក់មិនចាប់អារម្មណ៍ព័ត៌មានទាំងនោះប៉ុន្មានទេ ។ ឪពុកខ្ញុំហាក់ដូចពេញចិត្ត និងគាំទ្រសកម្មភាពរបស់សម្តេច សីហនុ ណាស់ និងមានជំនឿលើអ្នកដឹកនាំ ខ្មែរក្រហម ដូចជា ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម ជាដើម ។

បើទោះបី ជាក្នុងរបប លន់ នល់ ក្តី ក៏នៅក្នុងបន្ទប់ទទួលភ្ញៀវ ក៏នៅមានព្យួរតាំងរូបថតធំៗពីរផ្ទាំងរបស់សម្តេច សីហនុ និងមាតាព្រះអង្គដែរ ។

ថ្ងៃដែលខ្មែរក្រហមបានចូលមកដល់ក្រុងពោធិ៍សាត់ ។ ចាប់ពីម៉ោងប្រហែល១១ព្រឹក ខ្ញុំបានឃើញ និងឮសូរសំឡេងទាហានខ្មែរក្រហមស្រែកតាមផ្លូវឲ្យប្រជាជនចាកចេញពីផ្ទះជាបន្ទាន់ ។ យុវជនខ្មែរក្រហមតូចៗទាំងនោះ មានអាយុប្រហែលពី ១៦ ទៅ២០ឆ្នាំ កាន់អាវុធគ្រប់ដៃ ខ្លះដើរ និងខ្លះបើកឡានឃីតៗ ហើយប្រកាសដាក់បញ្ជាដាច់ខាតតាមមេក្រូ ។ បញ្ជាឲ្យមនុស្សទាំងឡាយចាកចេញពីផ្ទះ ។ ខ្មែរក្រហមនិយាយថា ប្រជាជនត្រូវតែចាកចេញពីផ្ទះមួយរយៈសិន ។

គ្រួសាររបស់ខ្ញុំគ្មានបានរៀបចំអ្វីច្រើនទេ ក្រៅពីរបស់របរបន្តិចបន្តួចប៉ុណ្ណោះ ព្រោះយើងមិនបានត្រៀមខ្លួនអ្វីសោះ ហើយម្យ៉ាងទៀត យើងគ្មានមធ្យោបាយដឹកជញ្ជូនឲ្យសមរម្យ ។ រថយន្តមិនអាចធ្វើចរាចរតាមផ្លូវបានទៀតទេ ដោយហ្វូងមនុស្សដើរតាន់តាប់ ។ មនុស្សម្នា ចាស់ ក្មេង ចាប់ផ្តើមឆ្ងល់ស្រឡាំងកាំង និងតក់ស្លុត ។

ប្រហែលពីរម៉ោងក្រោយពេលខ្មែរក្រហមបានធ្វើការប្រកាស យើងបានឃើញមនុស្សម្នាកុះករ ដើរឆ្លងកាត់មុខផ្ទះរបស់យើង ទាំងទឹកមុខស្រងូតស្រងាត់ជាខ្លាំង ។ អ្នកទាំងអស់គ្នា មកពីទិសខាងកើតដើរឆ្ពោះទៅកាន់ទិសដៅខាងលិចតាមផ្លូវទៅខេត្តបាត់ដំបង ។ ខ្ញុំរត់យកទឹកភ្លៀងត្រជាក់ពីក្នុងពាង ដែលសម្រិតសម្រាំងទុកពីរដូវភ្លៀងសម្រាប់ដឹក ជូនអ្នកដំណើរទាំងនោះ ។

ខ្ញុំបានសួរអំពីមូលហេតុដែលនាំឲ្យប្រជាជនត្រូវចាកចេញយ៉ាងនេះ ។ អ្នកទាំងនោះបាន ឆ្លើយមកខ្ញុំវិញថាពួកគាត់ត្រូវបានខ្មែរក្រហមបញ្ជាឲ្យចាកចេញ ។ ទាំងអស់នេះបានកើតឡើងក្នុងរយៈពេលពីរ ឬបីម៉ោងយ៉ាងប្រញាប់ជាទីបំផុត ។

ខ្ញុំបានឃើញយោធាខ្មែរក្រហមក្មេងៗខ្លះ ភ្ជង់ចុងកាំភ្លើងទៅអ្នកជម្លៀស ដើម្បីកុំឲ្យអ្នកទាំងនោះឈប់ ឬត្រឡប់ថយក្រោយវិញ ។ យោធាខ្មែរក្រហម បង្ខំឲ្យក្បួនដំណើររបស់ប្រជាជន ដាច់ខាតត្រូវបន្តដំណើរទៅមុខទៀត ដោយមិនឲ្យឈប់ ។ មួយសន្ទុះក្រោយមក ខ្ញុំបានឃើញមិត្តភក្តិខ្ញុំម្នាក់ដែលរៀនសាលាជាមួយគ្នា និងជាអ្នករស់នៅក្នុងទីក្រុងពោធិ៍សាត់ នៅពេលដែលពួកគេបានធ្វើដំណើរឆ្លងកាត់មុខផ្ទះរបស់យើង ។ ពួកគេបានរ៉ាយរ៉ាប់ថាអ្នកដែលឃឹតយ៉ាវ និងមិនព្រមចាកចេញពីផ្ទះ ត្រូវយោធាខ្មែរក្រហមបញ្ជាឲ្យបាញ់សម្លាប់ចោល ។

ខ្ញុំក៏បានយល់ថា ប្រសិនបើយើងបដិសេធមិនចេញ យើងក៏មុខជានឹងត្រូវគេបាញ់សម្លាប់ជាមិនខាន ។ ម្តាយខ្ញុំមានការស្ទើរស្ទាក់ក្នុងការចាកចេញនៅឡើយ ដោយសារមិនទាន់ឃើញឪពុកខ្ញុំត្រឡប់មកវិញ ។

នៅពេលដែលខ្ញុំបានឃើញហ្វូងមនុស្សច្រើនកុះករតាមផ្លូវ ខ្ញុំក៏បានទៅប្រាប់ម្តាយខ្ញុំឲ្យបានដឹងពីរឿងនេះ ។ អ្នកជិតខាងដែលមិនទាន់ចេញដែរនោះ ក៏បានបន្តមកប្រាប់ម្តាយថា យើងត្រូវតែចាកចេញជាដាច់ខាត ។ ម្តាយខ្ញុំមិនមែនមានស្រុកកំណើតខេត្តពោធិ៍សាត់ទេ គាត់មានស្រុកកំណើតកើតនៅភ្នំពេញ ។ ដូច្នេះ គាត់ពិបាកសម្រេចចិត្តថា ត្រូវចេញទៅខាងណាណាស់ ។ ឪពុកខ្ញុំមានស្រុកកំណើតនៅខេត្តពោធិសាត់ ។ ភូមិកំណើតគាត់នៅចម្ងាយប្រមាណជា២០ ឬ២៥គ.ម ពីផ្ទះដែលយើងរស់នៅ ។ ដូច្នេះ ពេលនោះម្តាយខ្ញុំក៏សម្រេចចិត្តធ្វើដំណើរទៅកាន់ស្រុកកំណើតរបស់ឪពុក ដោយសង្ឃឹមថា ប្រសិនណាបើឪពុកខ្ញុំត្រឡប់មកវិញ ហើយគាត់រកយើងនៅផ្ទះមិនឃើញ គាត់ប្រាកដជានឹងទៅភូមិកំណើតរបស់គាត់មិនខាន ។

យើងក៏បានយករទេះធំគ្រាន់បើមួយចេញពីឃ្លាំង ដើម្បីដឹកអង្ករនិងសម្ភារខ្លះៗ ។ វាជារទេះមួយដែលយើងធ្លាប់ប្រើប្រាស់សម្រាប់ដឹកដើមចេកយកទៅដាំ និងដឹកស្រូវទៅកិននៅរោងម៉ាស៊ីនកិនស្រូវម្តងម្កាល ។ ថ្ងៃនោះយើងបានយកវាមកប្រើដើម្បីដឹកអីវ៉ាន់ម្តង ។ ម្តាយខ្ញុំមិនបានយករបស់របរអ្វីច្រើនទេ ដោយសារខ្មែរក្រហមបានប្រកាសប្រាប់ថា បងប្អូនយើងនឹងត្រឡប់មកផ្ទះវិញក្នុងរយៈពេលត្រឹមតែពីរ ឬបីថ្ងៃប៉ុណ្ណោះ គាត់ក៏ជឿទាំងស្រុង ។ របស់របរប្រើប្រាស់មានតម្លៃទាំងអស់ ត្រូវទុកចោលក្នុងផ្ទះ រួមទាំងរថយន្ត ម៉ូតូ កង់ ។ល ។ រួចហើយយើងក៏បានចាកចេញទៅ ។ «មែនទែនទៅ វាមិនមែន ២ ឬ ៣ ថ្ងៃឯណា ប៉ុន្តែ ៣ឆ្នាំជាង ទៅវិញទេ» ។ នេះជាល្បិចភូតកុហកដ៏ប៉ិនប្រសប់របស់ខ្មែរក្រហម។

**(តទៅលេខក្រោយ)** **ហែម សុខណ្ណារិទ្ធិ**

# ដំណឹងស្វែងរកគ្រួសារ



មិត្តភក្តិរបស់ខ្ញុំជាជនជាតិខ្មែរកាត់ចិនរស់នៅសហរដ្ឋអាមេរិក ចង់ស្វែងរកគ្រួសាររបស់គាត់ដែលបានបែកគ្នាជាង៤០ឆ្នាំមកហើយ ។ គាត់មានឈ្មោះអាមេរិកាំងថា ស៊ីម៉ុន គួច ដែលត្រកូលរបស់គាត់ ឡុង ឬ ឡេង ជាភាសាចិន ។ ស៊ីម៉ុន កើតនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៥៥ ។ គាត់បានបែកចេញពីគ្រួសារនៅថ្ងៃទី១៧ ឆ្នាំ១៩៧២ នៅពេលដែលរដ្ឋាភិបាលជ្រើសរើសទាហាន ។ ស៊ីម៉ុន ជាកូនច្បងក្នុងចំណោមបងប្អូន៧នាក់ (ស្រី៣នាក់ និងប្រុស៤នាក់) ។ ឪពុករបស់គាត់ជាអ្នកគ្រប់គ្រងរោងភាពយន្តមួយដែលនៅជិតផ្ទះ ។ ស៊ីមុន មិនចាំអាសយដ្ឋានរបស់គាត់ទេ ដោយគាត់គ្រាន់តែដឹងថា ផ្ទះរបស់គាត់នៅជាន់ទី៣ នៃមហាវិថីសាល់ដឺហ្គោល និងមានចម្ងាយដើរប្រមាណ៥នាទីពី រោងភាពយន្ត ។

បើបងប្អូនណាបានឮ ឬទទួលដំណឹងនេះហើយ សូមទាក់ មកខ្ញុំតាមរយៈអាសយដ្ឋាន ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ, ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥ ។ ***សូមអរគុណ!***

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ វ៉ាន់ថាន់ពៅដារ៉ា ទូរសព្ទលេខ ០១២ ៨៤៦ ៥២៦ ឬ អ៊ីម៉ែល ៖ *truthpdara@dccam.org* ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

**សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 205, 2017 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.